PRIMERICA
A Citi Company
Chanthy Sek &
Shawn Dougherty
Bus: 1-866-582-3172
Cell: 267-984-8554
e-mail: 8665823172@primerica.gosolo.com

- Life Insurance
- Car Insurance
- Refinance Your Debts
- Investments
- Office or Home Appointment.
We also provide translation and interpretation services.
Primerica Financial Services, 1035 Virginia Dr., Ste 100H, Ft. Washington, Pa 19034

# ខ្មែរប៉ុស្តិ៍
# The Khmer Post

ហាងមាសរស្មី
SUNSHINE JEWELRY INC
មានលក់គ្រឿង អលង្ការ យ៉ាងប្រណិតបំផុត ចេញសញ្ញាប័ត្រឈើពេជ្រអាច ផ្លាក់ ឬ ខ្សែ មាស ព្រាក់ ពេជ្រ ជូនបាន តាមបំណង ។
702 Washington Avenue
Philadelphia, Pa 19147
Phone: (215) 271-2950
Fax : (215) 271-2962
Email: colorofsunshine@yahoo.com

KHMER BILINGUAL BIWEEKLY NEWSPAPER
VOLUME 02 | ISSUE 24 | November 01st-15th 2008 | ADVERTISING (267) 253-3947 | WWW.THEKHMERPOST.COM

# ថ្ងៃទី4 ខែវិច្ឆិកា ឆ្នាំ2008 វេលាម៉ោង 9យប់




**ដោយ : ពិន សំខុន**

●●●គេអាចដឹងថា នរណាជាប្រធានាធិបតេយ្យអាមេរិកាំងថ្មី ?

បារ៉ាក់ អូបាម៉ា-បាយដិន គណបក្សប្រជាធិបតេយ្យ បោះឆ្នោតប្រជែងគ្នានឹង ចន ម៉ាកេន-បាលីន គណបក្សសាធារណរដ្ឋ ដើម្បីឱ្យបានជាប្រធានាធិបតី នៃសហរដ្ឋអាមេរិក ដែលជាមហាប្រទេស មានអំណាចជាងគេលើសកលលោកនាពេលនេះ ។ ប្រជាពលរដ្ឋអាមេរិកាំង មានប្រមាណ 130នាក់ នឹងសំដៅទៅហិបឆ្នោត នាថ្ងៃអង្គារ ទី4 ខាងមុខ ។ នៅលើចំណុចនេះ មានអាមេរិកាំង ដែលទើបនឹងបោះឆ្នោតជាលើកដំបូង ចំនួន 8.5 លានថ្មីទៀត ត្រូវទៅកាន់ហិបឆ្នោតដែរ ។

នៅ 10ថ្ងៃ មុនការបោះឆ្នោតនេះ ការស្ទង់មតិបានមើលឃើញថា លោក បារ៉ាក់ អូបាម៉ា

(តទៅទំព័រទី១៦)

Exercise your rights as a United States citizen!
Remember to...
VOTE!
Tuesday, November 4th, 2008
If you vote for the first time, don't forget to bring your I.D.or proof of address!
For information on your voting booth location, please contact Voter Registration Administration office at (215) 686-1509 or CAGP at (215) 324-4070.
ប្រើសិទ្ធិរបស់អ្នកក្នុងនាមជាប្រជាពលរដ្ឋអាមេរិក
សូមកុំភ្លេចទៅ
បោះឆ្នោត
នៅថ្ងៃអង្គារ ទី៤ ខែវិច្ឆិកា ឆ្នាំ២០០៨
បើលោកអ្នកបោះឆ្នោតលើកទីមួយ សូមកុំភ្លេចយកប័ណ្ណសំគាល់ខ្លួន ឬក៏សំបុត្របញ្ជាក់អាស័យដ្ឋាន ដូចជាសំបុត្រទឹក ភ្លើង ឬហ្គាស ទៅជាមួយ
បើលោកអ្នកមិនដឹងពីទីតាំងបោះឆ្នោត សូមទាក់ទងមក ការិយាល័យបោះឆ្នោតលេខ ២១៥-៦៨៦-១៥០៩ ឬសមាគមខ្មែរលេខ ២១៥-៣២៤-៤០៧០ ។
ការរំលឹកនេះធ្វើឡើងដោយ សមាគមខ្មែរតំបន់ហ្វីឡាដែលហ្វៀ និង សមាគម Asian Pacific Islander American Vote, and Southeast Asia Resource Action Center
This reminder has been brought to you by the Cambodian Association of Greater Philadelphia, Asian Pacific Islander American Vote, and Southeast Asia Resource Action Center.
APIA Vote
The Center FOR CIVIC PARTICIPATION
CAMBODIAN ASSOCIATION OF GREATER PHILADELPHIA, INC.

## ពុះផ្ទះចែកគ្នាព្រោះអស់ជំនឿនឹងតុលាការ

**ព្រៃវែង, ខ្មែរប៉ុស្តិ៍ : គីម សារឿន**

●●●ទាក់ទិនទៅនឹងបញ្ហាពុះផ្ទះចែកគ្នានេះ ប្រជាពលរដ្ឋជាច្រើន ដែលបាននិយាយប្រហាក់ប្រហែលគ្នាថា មកពីពួកគាត់អស់ជំនឿទៅនឹង តុលាការ ទើបសុខចិត្តធ្វើតុលាការដោយខ្លួនឯងបែបនេះ ។

(តទៅទំព័រទី១៦)


បំណែកផ្ទះ ដែលប្តីប្រពន្ធពុះចែកគ្នា

## ប្រវត្តិនៃបុណ្យកឋិនទាន

**ដោយ : អ៊ុំ លឿម**

●●●តាមលំអានរបស់ព្រះពុទ្ធសាសនា បុណ្យកឋិនទាន ជាពិធីបុណ្យដ៏ពិសេសមួយ ដែលត្រូវបានប្រារព្ធធ្វើឡើងក្នុងរយៈពេលមួយខែ ចាប់ពីថ្ងៃ1រោជ ខែតុលា រហូតដល់ថ្ងៃពេញបូណ៌មីខែវិច្ឆិកា ។ បើសំអាងតាមឯកសារពុទ្ធសាសនានានា មានការបរិយាយស្រដៀងគ្នាថា : កឋិនទាន គេធ្វើឡើងដើម្បីប្រគេនត្រៃចីវរ និងវត្ថុប្រើប្រាស់ប្រចាំថ្ងៃមួយចំនួន ចំពោះព្រះសង្ឃ ដែលលោកបានគង់ចាំព្រះវស្សាអស់ត្រីមាស (បីខែ)

(តទៅទំព័រទី១៥)


តុក្កតាក្រុមឆៃយ៉ាំ

សូមអញ្ជើញស្តាប់វិទ្យុសម្លេងខ្មែរអាមេរិកាំង នៅ ហ្វីឡាដែលហ្វីយ៉ា AM1540 នៅរៀងរាល់ថ្ងៃសៅរ៍ ពីម៉ោង ៣ ដល់ ៤ រសៀល

# ហេតុអ្វីយើងគួរបោះឆ្នោត?

**ដោយ រ៉ង សន នាយកសមាគមខ្មែរ**



●●●ការបោះឆ្នោតមានសារសំខាន់ណាស់សំរាប់ខ្មែរ-អាមេរិកាំងយើង។ ជាដំបូងការបោះឆ្នោត គឺជាសិទ្ធិដែលបានមកដោយកំរជាពិសេស ចំពោះស្ត្រី និងជនជាតិភាគតិចដូចជាខ្មែរ-អាមេរិកាំងយើង។ វាជាគោលជំហរដ៏សំខាន់នៃលទ្ធិប្រជាធិបតេយ្យ ។ ព្រោះថា : មានមនុស្សនៅលើពិភពលោករាប់លានអ្នកដែលគ្មានសិទ្ធិនេះ។ ម្លោះហើយយើងគួរតែប្រើសិទ្ធិដ៏កំរនេះកុំឱ្យខាន។

មួយទៀត ការបោះឆ្នោតគឺជាភារកិច្ចរបស់យើងគ្រប់រូបដែលជាជនជាតិអាមេរិកាំង។ ប្រសិនបើយើងម្នាក់ៗមិនចូលរួមក្នុងការបោះឆ្នោតនោះទេ គោលជំហរនៃលទ្ធិប្រជាធិបតេយ្យក៏មិនអាចនៅគង់វង់ដែរ ។ ពេលនោះអ្វីៗ គឺសម្រេចដោយមនុស្សមួយក្រុម ដែលមានអំណាច ហើយអ្នកទាំងនោះមិនធានាថានឹងនាំផលប្រយោជន៍ដល់យើងដែលគ្មានចំណែកក្នុងការបោះឆ្នោតនោះទេ។

ដើម្បីអោយសហគមន៍យើងមានសំឡេង និងមានការទទួលស្គាល់ពីសំណាក់អ្នកនយោបាយទាំងឡាយយើងម្នាក់ៗដែលជាសញ្ជាតិអាមរិកាំង ហើយបានចុះឈ្មោះបោះឆ្នោតរួចហើយ គួរតែចាំបាច់ចេញទៅបោះឆ្នោតកុំអោយខានអោយសោះ។ យើងបោះឆ្នោតដើម្បីការពារសិទ្ធិរបស់យើងបំពេញភារកិច្ចយើងដែលជាសញ្ជាតិអាមេរិកាំង ហើយជាពិសេសជាងនេះ ទៅទៀតគឺដើម្បីអោយយើងមានសំឡេងក្នុងឱកាសជ្រើសរើសអ្នកនយោបាយណាដែលមានគំនិត និងគោលជំហរធ្វើការបំរើផលប្រយោជន៍របស់យើង។ ពេលយើងមានសំឡេងយើងអាចទាមទារឱ្យអ្នកនយោបាយទាំងនោះ ស្តាប់យើងគិតដល់អនាគតយើង និងអនាគតកូនចៅរបស់យើង ។ ពេលណាយើងមានការចូលរួមកាន់តែច្រើន យើងកាន់តែមានឱកាសនៃទទួលផលប្រយោជន៍កាន់តែច្រើន។

ហេតុនេះ ដើម្បីឱ្យសហគមន៍យើងមានការរីកចំរើនទៅអនាគត សូមកុំភ្លេចចេញទៅបោះឆ្នោត។ **ថ្ងៃបោះឆ្នោត គឺនៅថ្ងៃ អង្គារ ទី ៤ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ខាងមុខនេះ។**

បើលោកអ្នកមានសំណួរអ្វី សូមអញ្ជើញទាក់ទងមកនាងខ្ញុំ រ៉ង សន តាមទូរស័ព្ទលេខ ២១៥-៣២៤-៤០៧០ ៕ **សូមអរគុណ !**

# បុណ្យផ្កាប្រាក់សំរាប់ជួយដល់យុវជនសមរភូមិមុខ

**ដោយ អ៊ុម លឿម**



ពុទ្ធបរិស័ទកំពុងចូលរួមក្នុងពិធីបុណ្យផ្កាប្រាក់

●●●ពលរដ្ឋខ្មែរស្នេហាជាតិមាតុភូមិមួយក្រុមនៅទីក្រុង ហ្វីឡាដែលហ្វីយ៉ា បានសហការណ៍គ្នាធ្វើពិធីបុណ្យផ្កាមួយ នៅថ្ងៃសៅរ៍ ទី25 និង ថ្ងៃអាទិត្យ ទី26 ខែតុលា ថ្មីៗនេះ នៅឯបរិវេណវត្ត "បាលិលេយ្យ" ( ដឺប៊ី ) ដើម្បីប្រមូលថវិកាជួយឧបត្ថម្ភគាំទ្រដល់យុវជន ដែលកំពុងបំពេញបេសកម្មការពារជាតិមាតុភូមិប្រកបដោយគ្រោះថ្នាក់នៅតាមបណ្តោយព្រំដែនខ្មែរ-សៀម នាខេត្តឧត្តរ-មានជ័យ និងខេត្តព្រះវិហារ ។

ទោះបីជាព្រះភិរុន្ទ បានបង្អោរស្ទើរតែពុំដាច់គ្រាប់ក្តី ក៏ភ្ញៀវកិត្តិយស ដែលបានអញ្ជើញមកចូលរួមហាក់ពុំចុះញ៉មនឹងភាពទទឹករបស់ព្រះភិរុន្ទនេះឡើយ ដោយម្នាក់ៗទ្រាំឈរស្តាប់ការប្រគំតន្ត្រីពីសំណាក់ក្រុមភ្លេងចម្រុះប្រចាំក្រុងហ្វីឡាដែលហ្វីយ៉ា ដោយក្តីសប្បាយរីករាយ ។ ចំណែកថ្ងៃបន្ទាប់ គឺថ្ងៃអាទិត្យទី26 អាកាសធាតុមានលក្ខណៈល្អប្រសើរណាស់ ។

លោក ហ៊ូ សូត្រ ជាសមាជិកម្នាក់ ក្នុងចំណោមគណៈកម្មាការរៀបចំពិធីបានប្រាប់ខ្មែរប៉ុស្តិ៍ថា : ក្នុងនាមលោកជាកូនខ្មែរ ចាំបាច់ត្រូវតែមានភារកិច្ចមួយទោះតូចក្តីធំក្តី គឺការរៃអង្គាសថវិកាសំរាប់ជួយដល់កងទ័ពដែលកំពុងមានការខ្វះខាតនៅឯកសមរភូមិ។

លោកបានផ្តាំផ្ញើថា ទោះជាការជួយពីសំណាក់បងប្អូនខ្មែរយើងមានទ្រង់ទ្រាយតូចក្តីក៏វាអាចមានន័យទូលំទូលាយណាស់ក្នុងខណៈដែលមាន គេកំពុងឈ្លានពានដល់ប្រទេសជាតិយើង ។

ចំណែកលោក រស់ ហ៊ាន អតីតអ្នកតំណាងរាស្ត្រសភាធម្មនុញ្ញមកពីកូតាគណបក្សហ៊្វុនស៊ិនប៊ិច ក្នុងខេត្តព្រៃវែង សម្តែងទស្សនៈផ្ទាល់ខ្លួន ប្រាប់ខ្មែរប៉ុស្តិ៍ថា នេះពុំមែនជារឿងនយោបាយរវាង គណបក្សប្រឆាំង និងរដ្ឋាភិបាលឡើយ តែជារឿងអាយុជីវិតប្រទេសជាតិយើង ដូច្នេះយើងត្រូវងើបឈរដើម្បីការពារបូរណភាពទឹកដីកុំឱ្យដីរបស់យើងរួញទៅទៀត។

សូមជម្រាបប្រាក់ឧបត្ថម្ភកើតចេញពីបុណ្យផ្កានេះត្រូវបានលោក មាស ជា គណៈកម្មការរៀបចំកម្មវិធីថ្លែងថា នឹងយកទៅចែករំលែកដល់យុទ្ធជនតាមរយៈលោក ម៉ម សុណង់ដូ អគ្គនាយកវិទ្យុសំបុកឃ្មុំនៅឯប្រទេសកម្ពុជា រីឯ លោក ញ៉យ ចំរើន អតីតជាប្រធានចលនានិស្សិត ដើម្បីប្រជាធិបតេយ្យនឹងជាអ្នកផ្តួចផ្តើមបង្កើតកម្មវិធីរៃអង្គាសប្រាក់នេះ បានថ្លែងជាចំហរលើវេទិកាកិត្តិយសថា : ជាការលើទឹកចិត្តដល់យុទ្ធជន និងជាការបង្ហាញពីសាមគ្គីភាពរវាងខ្មែរ និងខ្មែរទាំងអស់។

នៅក្នុងទីធ្លាដ៏ធំគ្មានសំណង់អ្វីនៅឡើយនៃវត្តបាលិលេយ្យ គណៈកម្មាធិការបុណ្យប្រមូលបច្ច័យពីសប្បុរជនខ្មែរ នៅហ្វីឡាដែលហ្វីយ៉ានេះ បានចំនួនជាងប្រាំបីពាន់ដុល្លារ ៕




ADAMS DENTAL CENTER

801 ADAMS AVENUE. PHILADELPHIA, PA 19124. TEL: 215-744-8300

សូមអញ្ជើញមកមជ្ឈមណ្ឌលធ្វើធ្មេញ "អាដាម" យើងធ្វើចុនពីដើមដល់ចប់បានយើង មានក្រុមទន្តបណ្ឌិត៥រូប ដែលមានជំនាញក្រប់ជ្រុងជ្រោយនៃវិជ្ជាធ្វើធ្មេញ ។





មណ្ឌលធ្មេញឯកទេស ខាងការពារលំអរ

ឯកទេសខាង
- ✓ Crowns,
- ✓ Braces,
- ✓ Bridges,
- ✓ Veneers,
- ✓ Inlay,
- ✓ Gold Caps,
- ✓ Implants,
- ✓ Full & Partial Dentures.

យើងជាមជ្ឈមណ្ឌលនៅហ្វី ឡាដែលហ្វៀតែមួយ ដែលមានបន្ទប់ពិសោធន៍នៅជាមួយគ្នានេះទីនោះ លោក-អ្នកអាចប្តូរធ្មេញជំនួស ដែលផលិតឡើងតាមគុណភាព ដែលលោកអ្នកចង់បាន ទាំងអស់សុទ្ធតែដំណើរការណ៍ដោយបច្ចេកទេសវិជ្ជាជាន់ខ្ពស់ ហើយប្រើលំនាំប្រព័ន្ធ OSHA ជាក្បួន។

ទន្តសាស្ត្រទូទៅ
- -ដកធ្មេញ
- -បំពេញធ្មេញប្រហោង
- -ព្យាបាលប្រហោងដល់ឫសធ្មេញ
- -ផ្លិតចន្លោះធ្មេញមុខ-ធ្មេញបាក់ ធ្មេញស្រោម ឬធ្មេញដង្កូវស៊ី
- -សំអាតធ្មេញឱ្យស្អាតៈ ដោយធ្វើដោយឡេស៊័រមួយម៉ោង ឬយកប្រដាប់ទៅសំអាតនៅផ្ទះ
- -យើងក៏មានធ្វើការសំអាតដោយ "អុលត្រាសោន" ដែលធ្វើមិនឱ្យយើងឈឺ

បើកមជ្ឈមណ្ឌល

| | |
|---|---|
| ថ្ងៃ ច័ន្ទ | : 10am-6pm |
| ថ្ងៃ អង្គារ | : 10am-6pm |
| ថ្ងៃ ពុធ | : 10am-7pm. |
| ថ្ងៃ ព្រហស្បតិ៍ | : 10am-6pm |
| ថ្ងៃ សុក្រ | : 10am-6pm. |
| ថ្ងៃ សៅរ៍ | : 10am-7pm |

យើងទទួលយកផែនការណ៍ជួយធ្វើធ្មេញស្ទើរតែទាំងអស់

Cigna Dental, 1201 Dental Plan, Delta Dental, DHA, Guardian,Aetna,PPO, Ameri-Health, United Concordia Flex, MetLife, Unicare.

ចុះថ្លៃ 10% ដល់អ្នកគ្មានបណ្ណសុខភាព

អាចធ្វើផែនការណ៍ចេញថ្លៃរាល់ខែ

# យើងសូមអញ្ជើញលោកអ្នកមកចូលរួមផ្តល់ការគាំទ្រដល់ព្រឹទ្ធសមាជិក បារ៉ាក់ អូបាម៉ា ដើម្បីតំណែងជាប្រធានាធិបតីនៃសហរដ្ឋអាមេរិក

គាំទ្រលោកព្រឹទ្ធសមាជិក អូបាម៉ា ? គឺជាកិត្តិយសដ៏ថ្លៃថ្លានៃការទទួលឧទ្ទិសនាមនៅក្នុងបញ្ជី "Pan Asian Leaders " នៃការទទួលយល់ព្រមទៅលើប័ណ្ណ អូបាម៉ា បាយដិន សូមប្រញាប់អញ្ជើញចូលរួមដោយផ្ញើអ៊ីមែលទៅដេវីដសេង DAVID SENG : dseng2002@msn.com

(1) គាំទ្រគោលជំហររបស់បារ៉ាក់អូបាម៉ា : គឺលោកធ្លាប់បានបង្ហាញយ៉ាងច្បាស់រួចមកហើយថា លោកជាមគ្គុទេសដ៏រឹងមាំមួយរូបដោយសារលោកអាចប្រមូលពលរដ្ឋឱ្យរួបរួមគ្នាបានយ៉ាងច្រើន-លោកយល់ថា ភាពចម្រុះពណ៌ គឺជាបំណងនឹងគោលដៅរបស់សហគមន៍មិនឌីយ៉ាន-អាមេរិកផងដែរ ។

(2) លោក បារ៉ាក់ អូបាម៉ា នឹងធ្វើការដោះស្រាយលើបញ្ហាសំខាន់ៗរបស់អាស៊ានអាមេរិកាំងមកពីអាស៊ីអាគ្នេយ៍ ( មានខ្មែរអាមេរិកាំងដែរ) លោក បារ៉ាក់ អូបាម៉ា នឹងជួសជុលប្រព័ន្ធហិរញ្ញវត្ថុ ដែលបានខូចខាត-លោកនឹងតម្រែតម្រង់ផ្លូវអភិវឌ្ឍសេដ្ឋកិច្ច រយៈពេលវែង-បង្កើតការងារថ្មីៗបន្ទូរទម្ងន់នៃពន្ធដារ-គាំទ្រដល់សហគ្រាសខ្នាតតូច-ដល់ម្ចាស់ហាងដែលជាជនជាតិភាគតិច នឹងគាំទ្រដល់អ្នកដែលជាម្ចាស់ផ្ទះសព្វថ្ងៃនេះផង ។

(3) ដើម្បីគំរោងបង្កើតការងារច្រើន លោក អូបាម៉ា នឹងជួយដល់ការសិក្សានូវតាក់ក្រេឌីតប្រចាំឆ្នាំ ( Tax Credit) តម្លៃ 4 ពាន់ដុល្លារ កម្មវិធីថ្មីចូលរួមជាមួយមហាវិទ្យាល័យ ហើយនឹងបង្កើតឱកាសអ្នកធ្វើការអាចត្រឡប់ទៅសិក្សាវិញបាន ។

(4) លោក អូបាម៉ា នឹងរ៉ាប់រងឱ្យសហគមន៍ទាំងអស់អាចទទួលបាននូវការថែទាំសុខភាព ដែលបន្ថយការលំបាកក្នុងការប្រើភាសាបន្ថយរនាំងវប្បធម៌ដែលជាហេតុធ្វើឱ្យសហគមន៍លំបាកនឹងទទួលប្រព័ន្ធសុខភាពបាន ។

(5) គំរោងការណ៍ធានារ៉ាប់រងសុខភាពពលរដ្ឋរបស់លោក អូបាម៉ា គឺជាគំរោងដែលធ្វើឱ្យយើងទទួលភាគចំណេញច្រើនផ្ទុយគ្នានឹងគម្រោងការណ៍របស់លោក ម៉ា កេន ។ គម្រោងរបស់លោក ម៉ា កេន គឺចេញថ្លៃថែទាំសុខភាពដោយបន្ថយថ្លៃជំនួសពីថ្នាំពេទ្យ Medicare និង Medicaid ហើយលើកដំបូងក្នុងប្រវត្តិសាស្ត្រ លោក ម៉ា កេន ឱ្យតម្លៃថា អ្នកទទួលការថែទាំសុខភាពទាល់តែធ្វើការ ។

(6) លោក អូបាម៉ា ទទួលស្គាល់ថា ពួកអាស៊ាន អាមេរិកាំង និងពួកប្រជុំកោះ កំពុងតែកើនចំនួន គួរឱ្យកត់សំគាល់ ឥឡូវនេះប្រហែល ២៦ % នៃអ្នកដែលមានកំណើតនៅក្រៅទឹកដី គឺមកពីអាស៊ី ហើយពួកនោះចូលសញ្ជាតិអាមេរិកាំងច្រើនជាងស្រុកឯទៀតៗ ។

លោក អូបាម៉ា គ្រោងនឹងកែទម្រង់ច្បាប់អន្តោប្រវេសន៍ ដើម្បីឱ្យជនអន្តោប្រវេសន៍អាចប្រមូលផ្តុំក្រុមគ្រួសារជាច្រើនដែលម្ចាស់សហគ្រាសរកមនុស្សទៅធ្វើការមិនបាន ។




## យើងយល់ស្របតាម បារ៉ាក់ អូបាម៉ា

| | |
|---|---|
| David O.Seng | - Vice President of Cambodian American Senior Association |
| Chen Heng | - President of United Cambodian American Youth Association |
| Thann Prum | - Migrant Education Counselor / Community Leader |
| Chris Keo | - Executive Director of United Cambodian American Youth Association |
| Robert Kock | - Vice President of Khmer Buddhist Humanitarian Association Cambodian Buddhist Temple |
| Rorng Sorn | - Executive Director of Cambodian Association of Creater Philadelphia |
| Vutha Chin | - Former President of Cambodian Association of Creater Philadelphia |













ការបោះឆ្នោតលើកនេះ មានសារៈសំខាន់ណាស់ សម្លេងរបស់ អាស៊ាន អាមេរិកាំង ពីអាស៊ីអាគ្នេយ៍ ( មានខ្មែរអាមេរិកាំង) ត្រូវតែធ្វើឱ្យឮឡើង ! យើងសូមឱ្យលោកអ្នកប្រញាប់ប្រញាល់មកចូលរួមជាមួយយើងខ្ញុំ ដើម្បីបោះឆ្នោតឱ្យ បារ៉ាក់ អូបាម៉ា នៅថ្ងៃ

## អង្គារ៍ ទី 04 វិច្ឆិកា 2008

សូមកុំភ្លេចនាំទាំងក្រុមគ្រួសារនឹងមិត្តភ័ក្រ្តលោកអ្នកសំដៅទៅកន្លែងបោះឆ្នោត ហើយបោះឆ្នោតឱ្យឈ្មោះ បារ៉ាក់ អូបាម៉ា កុំខាន !

# នាវាចម្បាំងពិឃាតអាមេរិក ចូលបោះយុថ្កានៅក្នុងដែនសមុទ្រកម្ពុជា

**ក្រុងព្រះសីហនុ, ខ្មែរប៉ុស្តិ៍ ៖ គឹម សុជាតិ**

●●●ចូលសំចតបង្ហាញខ្លួនយ៉ាងធំស្កឹមស្កៃ នៅចំងាយ2គីឡូម៉ែត្រ ពីកំពង់ផែកំពង់សោម លើផ្ទៃសមុទ្រកម្ពុជា នៅម៉ោង9និង15នាទីព្រឹក នាវាចម្បាំងពិឃាត MUSTIN ដែលមានទំហំទទឹង20ម៉ែត្រ ជាមួយនឹងបណ្តោយប្រវែង 155 ម៉ែត្រ និងទម្ងន់សរុប9200តោន MUSTIN គឺជាប្រភេទនាវារបស់អាមេរិកទី3 ហើយដែលបានចូលសំចតនៅលើសមុទ្រកម្ពុជា នៅក្នុងឆ្នាំនេះ បន្ទាប់ពីមានការចូលចតជាបន្តបន្ទាប់នូវនាវាអាមេរិកាំងចំនួនពីរគ្រឿងរួចមក ។

បំពាក់ទៅដោយគ្រឿងអាវុធយុទ្ធភ័ណ្ឌទំនើបៗដូចជា កាំភ្លើងធំកាណុងទំហំ142មីលី-



នាវាចម្បាំងពិឃាតរបស់អាមេរិក ចូលចតនៅកំពង់ផែកំពង់សោម លើផ្ទៃសមុទ្រកម្ពុជា



យន្តហោះចម្បាំងអាមេរិកចុះចតលើកប៉ាល់

ម៉ែត្រ កាំភ្លើងយន្តធុនស្រាលបាញ់ចម្ងាយបានដល់ទៅ24គីឡូម៉ែត្រ ដោយបញ្ចេញគ្រាប់បាន 10ទៅ16គ្រាប់ក្នុងមួយនាទី ព្រមទាំងមានផ្ទុកនូវយន្តហោះប្រភេទចម្បាំងចំនួន2គ្រឿងផងដែរនោះ នាវាចម្បាំងពិឃាតរបស់អាមេរិកមួយគ្រឿងដែលមានឈ្មោះថា USS MUSTIN បានបណ្តែតខ្លួនបោះយុថ្កាចូលសំចតនៅលើផ្ទៃសមុទ្ររបស់កម្ពុជា ដែលមានចម្ងាយជាង 2 គីឡូម៉ែត្រពីកំពង់ផែកំពង់សោម នៅក្រុងព្រះសីហនុ កាលពីព្រឹកថ្ងៃទី11 ខែតុលា កន្លងទៅនេះ ។

គឺជាប្រភេទនាវាពិឃាតលំដាប់ថ្នាក់លេខ23 ក្នុងផ្នែកទី3នៃកងនាវារបស់អាមេរិក ដែលមានបេសកកម្មច្រើនយ៉ាងក្នុងការវាយប្រហារទៅលើសត្រូវទាំងនៅលើគោក និងនៅលើផ្ទៃសមុទ្របានយ៉ាងមានប្រសិទ្ធភាព ។ នាវានេះមានប្រព័ន្ធអាវុធបាញ់ត្រង់ឡើងទៅលើនូវមីស៊ីលប្រភេទ SM-2, SM-3, ESSM Tomanawk ព្រមទាំងមានប្រព័ន្ធអាវុធបាញ់ជិត ដែលមានឈ្មោះថា Phalanx Blox 1B Close-In ហើយ ដែលអាចបាញ់ចំនួនគ្រាប់4500គ្រាប់ក្នុង1នាទី ។ ក្រៅពីមានប្រព័ន្ធអាវុធទំនើបៗបំពាក់នៅលើនាវាពិឃាតនេះ ក៏នៅមានប្រព័ន្ធរ៉ាដាទំនើបស្វ័យប្រវត្តិ AN/SPY-1D ដែលមានមុខងារច្រើនក្នុងការតាមចាប់ទីតាំងកន្លែងបំពេញបេសកកម្មចម្រុះ ផ្នែកបញ្ជាការការសម្រេចចិត្ត និងប្រព័ន្ធគ្រប់គ្រងអាវុធ ។

គេអាចមើលឃើញនាវានេះ បានយ៉ាងច្បាស់ពីទីតាំងកំពង់ផែកំពង់សោមទៅនូវដងអង់តែនរ៉ាដាយ៉ាងខ្ពស់ត្រដែត ជាមួយនឹងកាណុងកាំភ្លើងធំរបស់នាវាដែលតំរង់ត្រង់ទៅរកទីកំពង់ផែកំពង់សោម ដែលក្រុមអ្នកសារព័ត៌មាន ទើបតែនឹងចាកចេញជាមួយនឹងកាណុងធន់មធ្យមមួយដើម្បីធ្វើដំណើរឆ្ពោះមករកនាវានេះ ដោយមានចាំងពន្លឺថ្ងៃផ្លេកៗនៃរលកសមុទ្រដែលបោករត់ប្រដេញគ្នាប៉ះទៅនឹងនាវា ដោយមិនចេះហត់នឿយឡើយ ។ ប៉ុន្តែ រលកទាំងនេះ មិនមានឥទ្ធិពលធ្វើឱ្យនាវាពិឃាតនេះរង្គើបន្តិចសោះឡើយ ។

ថ្វីត្បិតតែនាវានេះ បំពាក់ទៅដោយយុទ្ធោបករណ៍ទំនើបៗយ៉ាងណាក៏ដោយ ក៏ប៉ុន្តែការចូលសំចតរបស់នាវានេះ នៅលើសមុទ្រខ្មែរ នៅពេលនេះ មិនមែនជាការធ្វើសង្គ្រាមនោះទេ គឺជាការចូលសំចតជួយដល់ផ្នែកមនុស្សធម៌ប៉ុណ្ណោះរបស់កងនាវិកសហរដ្ឋអាមេរិក ។

នៅពេលដែលគេទៅដល់ជិតនាវា គេបានឮសំឡេងម៉ាស៊ីនដែលមានបញ្ជោះដោយនាវាយ៉ាងរងំ ប៉ុន្តែនាវាមិនបានរំកិលខ្លួនឆ្ពោះទៅ

(តទៅទំព័រទី២០)

ភោជនីយដ្ឋាន ណាម វ៉ាង (ភ្នំពេញ)
Nam Vang Restaurant
571 Unit # 1 Adams Avenue. Philadelphia, Pa 19120
(inside Hong Kong Market)
(215) 742-9488
Open 7 days a week from 9 a.m. – 9 p.m.
បើក 7 ថ្ងៃក្នុងមួយអាទិត្យពីម៉ោង 9 ព្រឹក ដល់ 9 ល្ងាច
១_មុខជំនាញខាងម្ហូបខ្មែរយ៉ាងចំណាន ដូចជា:
- គុយទាវភ្នំពេញ
- គុយទាវ ឬមី-ខគោ
- មីកន្ទាំង ឆារសាច់គោ
- មីកន្ទាំងឆារគ្រឿងសមុទ្រ
- បាយឆារគ្រប់មុខ
- សាច់គោអាំង ចង្កាក់ ជាមួយជ្រក់ល្ហុង
២_មុខជំនាញម្ហូបវៀតណាមឈ្ងុយឆ្ងាញ់ ដូចជា:
- នំបញ្ចុកទឹកត្រីពិសេស
- នំប៉ុងបាតេ ឬសាច់គោអាំង
- ខគោ នំប៉ុង ឬមី និងគុយទាវ
- បាយសរសាច់ជ្រូកអាំង ឬសាច់មាន់អាំង



រៀងរាល់ថ្ងៃលោកអ្នកអាចពិសាទឹកក្រឡុកគ្រប់រស់ជាតិផ្លែឈើ ដូចជា : ទុរេន ឬ អាវូកាដូ ហើយជាពិសេស មានទឹកអំពៅកិនស្រស់ៗ

ទៅណាទៀត ?
បន្ទាប់ពីជួបវេជ្ជបណ្ឌិតរួចហើយ
ឱសថស្ថានWASHINGTON AVENUE
នឹងជួយដល់តម្លៃទិញថ្នាំពេទ្យ ជាពិសេសចំពោះគ្រួសារ ដែលមានប្រាក់ចំណូលតិចតួច
កុំភ្លេចយក
រង្វាន់ដោយឥតគិតថ្លៃ
៣០ សីហា



កាតាបធ្វើដំណើរ
នៅមានរង្វាន់ទីពីរទៀត



ដបវីតាមីនមួយ
វីតាមីន D
វីតាមីន C
វីតាមីនសំរាប់ស្ត្រី
វីតាមីនសំរាប់បុរស
ពិសេសសំរាប់អ្នកមានជំងឺទឹកនោមផ្អែម
ប្រដាប់ខាស់ស្ទង់ឈាមដោយឥតគិតថ្លៃ




* ស្រួលប្រើ
* លឿន
* ត្រឹមត្រូវ
* ឥតឈឺ
Washington Ave
ឱសថស្ថាន
215-755-5100
600 Washington ave, Unit 18E Phila, PA - phone: 215-755-5100

# ផ្ទុះអាវុធលើកទី2 សៀមរបួស 5 ចាប់ខ្លួនបាន10នាក់_ខ្មែរស្លាប់ 3របួស2

**ភ្នំពេញ, ខ្មែរប៉ុស្តិ៍ : គឹម សារឿន, មាជ សុវណ្ណារ៉ា**

●●●ក្នុងព្រឹត្តិការណ៍ផ្ទុះអាវុធនៅចំណុចវាលឥន្ទ្រីយ៍ តំបន់ប្រាសាទព្រះវិហារកាលពីថ្ងៃទី 15 ខែតុលា វេលាម៉ោង 1រសៀល បានបណ្តាលឱ្យកងទ័ពសៀមរបួស5នាក់ចាប់ខ្លួន បាន10នាក់ និងខ្មែរស្លាប់3 និងរបួស2នាក់ ។

ក្នុងព្រឹត្តិការណ៍ផ្ទុះអាវុធចាប់ផ្តើមពីម៉ោង2 និង15នាទីនោះ បើតាមព័ត៌មានច្បាស់ការគឺ បណ្តាលមកពីទាហាន សៀមជាអ្នកបង្កមុន ចំណែកភាគីខ្មែរយើងក៏បានធ្វើការបាញ់តទល់ ដើម្បីការពារខ្លួន ។

អ្នករាយការណ៍ព័ត៌មានខ្មែរប៉ុស្តិ៍ បានឱ្យដឹងថា នៅតាមបន្ទាត់ព្រំដែនខ្មែរ-សៀម ពួកទាហានសៀម បានបង្កើនកងទ័ពនិងចល័តរថយន្តពាសដែក និងដឹកអាវុធទំនើបៗ សម្លៀងដាក់ទាហានខ្មែរយើងយ៉ាងខ្លាំង ។

ទាហានសៀមបានបញ្ជូនយន្តហោះស៊ើបការណ៍សំងាត់មកលើដែនអាកាសខ្មែរទាំងថ្ងៃទាំងយប់ ដែលជាហេតុធ្វើឱ្យភាគីកម្ពុជាយើងមិនអាចអត់ទ្រាំបាន ។ ចំណែកទ័ពរបស់កម្ពុជាយើងបានប្រុងប្រៀបនឹងត្រៀមលក្ខណៈជាស្រេច ដើម្បីធ្វើការប្រយុទ្ធជាមួយពួកសៀម ។

តាមសេចក្តីរាយការណ៍របស់អ្នកយកព័ត៌មាន " ខ្មែរប៉ុស្តិ៍ " បានឱ្យដឹងថា ការផ្ទុះអាវុធនោះ គឺផ្តើម ចេញពីចំណុចវាលឥន្ទ្រីយ៍ ភ្នំទ្រព្យ និងក្បែរចង្កេះភ្នំប្រាសាទព្រះវិហារ ។ ក្នុងពេលប្រយុទ្ធនោះកងទ័ពខ្មែរយើងបានចូលកាន់កាប់ភូមិស្វាយរបស់សៀមនៅមុខប្រាសាទព្រះវិហារ និងចាប់បានឈ្លើយសឹកសង្គ្រាមចំនួន15នាក់ ។

បើតាមប្រសាសន៍របស់លោក ទួន ជ្រឿន មេបញ្ជាការរងកងពលតូចថ្មើរជើងលេខ42 បានឱ្យដឹងថា នៅក្នុងហេតុការណ៍នោះទាហានខ្មែរយើងបានធ្វើការសំរុកទៅមុខ និងកាន់កាប់តំបន់មួយចំនួន ។ ប៉ុន្តែ ដោយមានការចរចាពីភាគីសៀមសូមឱ្យផ្អាកនោះ ភាគីខ្មែរយើងក៏យល់ព្រមធ្វើការចរចាបន្តទៀត តែទោះជាយ៉ាងណាពលទាហានយើងស្ថិតនៅក្នុងការប្រុងប្រយ័ត្នជានិច្ច ។

លោក ហោ ណាំហុង រដ្ឋមន្ត្រីក្រសួងការបរទេសបានថ្លែងក្នុងសន្និសីទកាសែតថា ឧបទ្ទវហេតុនេះ គឺកើតឡើងដោយចៃដន្យក្នុងទ្រង់ទ្រាយតូច ពុំមែនជាការផ្ទុះអាវុធដាក់គ្នានោះទេ ។ ចំពោះភាគីខ្មែរដែលបាញ់នៅពេលនេះ វាជាសិទ្ធិការពារខ្លួន ក្នុងនាមជាម្ចាស់ទឹកដីម្ចាស់ប្រទេសប៉ុណ្ណោះ ។

លោក ហោ ណាំហុង បានបន្តថា នៅថ្ងៃ ទី17 ខែតុលា អគ្គរដ្ឋទូតខ្មែរប្រចាំនៅអង្គការសហប្រជាជាតិ និងសរសេរលិខិតជូនដំណឹងទៅក្រុមប្រឹក្សាអង្គការសហប្រជាជាតិ ដែលធ្វើជាភស្តុតាងសំរាប់ប្តឹងផងដែរ ។ លើសពីនេះ ទៅទៀត នៅពេលខាងមុខនេះ មេទ័ពខ្មែរ-សៀម នឹងជួបប្រជុំគ្នានៅលើទឹកដីសៀម ដើម្បីដោះស្រាយស្ថានភាពតានតឹងដែលកើតឡើងពេល កន្លងមក និងទៅថ្ងៃអនាគត ។

កាលពីថ្ងៃទី14 តុលា នាយករដ្ឋមន្ត្រីខ្មែរ ហ៊ុន សែន បានព្រមានជាថ្មីដល់កងទ័ពសៀម ដែលទន្ទ្រានយកទឹកដីខ្មែរត្រង់ចំណុចវាលឥន្ទ្រីយ៍នោះ រយៈពេល24ម៉ោង សំរាប់ការដកកងទ័ពចេញ ដើម្បីបញ្ចៀសការប្រយុទ្ធគ្នា ក្នុងទ្រង់ទ្រាយធំ ។ យើងមិនអាចឱ្យបាត់បង់ ចំណុចវាលឥន្ទ្រីយ៍បានទេ ការបាត់បង់ចំណុចនេះ មានន័យថា យើងបាត់បង់ប្រាសាទព្រះវិហារ ហើយយើងទាមទារឱ្យសៀមដកកងទ័ពឱ្យខានតែបាន ។

នៅក្នុងជំនួបការចរចារយៈពេលខ្លី រវាងមេទ័ពខ្មែរ-សៀម នៅវត្តកែវសិក្ខាគិរីស្វារៈ គឺជាជំនួបដ៏តក់ក្រហល់ ហើយការជជែកគ្នានេះមិនត្រូវរ៉ូវគ្នាទេ ។ ការដកថយរបស់កងទ័ពសៀមនេះ តែចំងាយប្រមាណ100ម៉ែត្រ ហាក់ដូចជាការដកថយដើម្បីរៀបចំសមយុទ្ធប៉ុណ្ណោះ ។

នៅក្នុងហេតុការណ៍ផ្ទុះអាវុធនោះ ប្រជាជនដែលរស់នៅតាមព្រំដែន បានរត់ចាកចេញពីទីផ្សារ និងលំនៅឋានប្រសេកប្រសាចឆ្ពោះមកកាន់ខេត្តមួយចំនួនដែលមានសុវត្ថិភាពទៅតាមសមត្ថភាពរៀងៗខ្លួន ។

ប្រជាជននៅតំបន់ភូមិគ.1 តំបន់ប្រាសាទព្រះវិហារ បានដឹកឥវ៉ាន់ចាកចេញពីលំនៅឋានរបស់ខ្លួនតាំងពីថ្ងៃទី14-15 ឆ្ពោះមកទីប្រជុំជនខេត្តព្រះវិហារ ។


ការផ្ទុះអាវុធជាលើកទី2 នៅចំណុចវាលឥន្ទ្រីយ៍



អ្នករាយការណ៍ព័ត៌មាន **"ខ្មែរប៉ុស្តិ៍"** ប្រចាំនៅច្រកជាំស្រងាំ ខេត្តឧត្តរមានជ័យ បានឱ្យដឹងថា ប្រជាពលរដ្ឋដែលប្រកបមុខរបរនៅផ្សារសៀម និងអ្នករស់នៅតាមព្រំដែនបាននាំគ្នាមកតាំងលំនៅឋាននៅតំបន់ស្រុកអន្លង់វែង អូរស្មាច់ អ្នកខ្លះទៀតឆ្ពោះទៅកាន់ខេត្តឧត្តរមានជ័យ និង ខេត្តសៀមរាប ។

ចំណែកប្រជាពលរដ្ឋនៅខេត្តបន្ទាយមានជ័យ តំបន់ប៉ោយប៉ែត ដែលភាគច្រើនឆ្លងដែនទៅប្រកបមុខរបរលក់ដូរនៅផ្សាររុងក្បឿ ប្រទេសសៀម បានបង្ខំចិត្តបញ្ឈប់ការលក់ដូរឆ្លងដែនមកផ្ទះសម្បែងវិញ យ៉ាងពពាក់ពពូន ពីព្រោះខ្លាចមានគ្រោះថ្នាក់ដោយចៃដន្យ ។

តាមប្រភពព័ត៌មានពីប្រជាពលរដ្ឋដែលរស់នៅតំបន់ជាយដែន បានអះអាងថា ទិដ្ឋភាពនៃការចាកចេញពីលំនៅឋាននៅពេលនេះ គឺមិនខុសប្លែកពីប្រជាជន (តទៅទំព័រទី០៦)



(តមកពីទំព័រទី០៥)

# ផ្ទុះអាវុធលើកទី2 សៀមរបួស5...

ដែលគេចពីសង្គ្រាមនៅ តាមជំរំជាយដែនអំឡុងទសវត្សឆ្នាំ៨០ឡើយ ។

តាមប្រភពព័ត៌មានពីកាសែតបាងកកប៉ុស្តិ៍ សៀម បានសរសេរថា កងទ័ពសៀមបានដកខ្លួនចេញពីចំណុចឥន្ទ្រីយ៍ហើយ ប៉ុន្តែទ័ពរបស់ខ្លួនមិនបានដកចេញពីចំណុចផ្សេងៗឡើយនេះមានសុវត្ថិភាពថែមទៀត ។ បន្ទាប់ពីមានហេតុការណ៍នេះ អាជ្ញាធរសៀមគ្រោងនឹងដឹកប្រជាជនរបស់ខ្លួនចេញពីទីក្រុងភ្នំពេញ និងខេត្តសៀមរាប ដែលកំពុងប្រកបអាជីវកម្ម និងដំណើរទេសចរ ។

តាមប្រភពព័ត៌មានច្បាស់ការនៅថ្ងៃទី14 ហ៊ុន សែន បានបន្តថា ទាហានសៀម៨4នាក់កំពុងបោះជំរំចម្ងាយ30ម៉ែត្រពីកម្ពុជា ដែលបង្ហាញអំពីសភាពការណ៍ក្តៅគគុក បើសិនជាមិនព្រមដកទេនោះ ប្រាកដជាផ្ទុះសង្គ្រាមហើយ ។

លោក ហោ ណាំហុង រដ្ឋមន្ត្រីក្រសួងការបរទេសខ្មែរ បានប្រាប់សន្និសីទកាសែតថា ខ្ញុំបាន

ចំណែកលោក សំពង់ បន្ទាប់ពីចាកចេញក្នុងកិច្ចប្រជុំភ្លាមមិនបានផ្តល់កិច្ចសម្ភាសន៍ដល់ក្រុមអ្នកសារព័ត៌មានទេ ហើយបានធ្វើដំណើរទៅទីក្រុងបាងកក យ៉ាងប្រញាប់ប្រញាល់បំផុត ។

ការផ្ទុះអាវុធដាក់គ្នាមួយប្រាវរវាងកងទាហាន





កាំភ្លើងធំ តំរង់ទៅពួកខ្មាំងនៅក្នុងការផ្ទុះអាវុធ

បើតាមការអះអាងរបស់លោក សំពង់ អាម៉នវីវ៉ាត់ រដ្ឋមន្ត្រីការបរទេសសៀម ចំណែកលោកនាយករដ្ឋមន្ត្រីសៀម ស៊ុមឆាយ បាននិយាយប្រាប់កាសែតបរទេសថា ភាគីសៀមមិនដកទ័ពចេញពីតំបន់ចំរូងចំរាស់នោះជាដាច់ខាតហើយ បើយើងដកទ័ពចេញនោះ មានន័យថា យើង លក់ទឹកដីឱ្យខ្មែរហើយ ។

នាយករដ្ឋមន្ត្រីសៀមរូបនោះ បានបញ្ជាក់ថា អ្វីដែលចាំបាច់នៅចំពោះមុខយើងមានតែបង្កើនទ័ពដើម្បីការពារតំបន់ជម្លោះឱ្យកាន់តែតុលា វេលាម៉ោង 12 ថ្ងៃត្រង់ កងទ័ពសៀម បានយល់ព្រមចាកចេញពីចំណុចវាលឥន្ទ្រីយ៍ទាំងកំហឹង ។

កាលពីថ្ងៃទី13 តុលា ហ៊ុន សែន បានធ្វើការព្រមានចំពោះភាគីសៀម ក្នុងជំនួបជាមួយលោក សំពង់ អាម៉នវីវ៉ាត់ រដ្ឋមន្ត្រីការបរទេសសៀមថា កងទ័ពសៀមត្រូវតែដកចេញពីទឹកដីកម្ពុជា ចំណុចវាលឥន្ទ្រីយរយៈពេល24ម៉ោង បើពុំនោះទេ យើងនឹងមិនអនុញ្ញាតឱ្យនៅជាដាច់ខាត ។

ប្រាប់ទៅរដ្ឋមន្ត្រីក្រសួងការបរទេសសៀម រួចហើយ ការបន្ថែមកងទ័ពនៅតាមព្រំដែនអាចនាំឱ្យមានគ្រោះថ្នាក់ និងបង្កជម្លោះកាន់តែធ្ងន់ធ្ងរ ។

លោក ហោ ណាំហុង បានបញ្ជាក់ថា លោកបានស្នើទៅកងទ័ពខ្មែរ-សៀម ឱ្យជួបប្រជុំគ្នានៅថ្ងៃទី21 និង24 តុលា នៅខេត្តសៀមរាប ពិភាក្សាពីការដកទ័ពនៅតាមព្រំដែន និងកិច្ចប្រជុំមួយទៀតនៅប្រទេសសៀមថ្នាក់រដ្ឋមន្ត្រីការបរទេស ថ្ងៃទី19 និង 20 វិច្ឆិកា ។

ឈុតខ្មៅសៀម និងកងទាហានកម្ពុជា ជាលើកដំបូងនៅវេលាម៉ោងប្រមាណជាង3និង45នាទីរសៀល កាលពីថ្ងៃទី3 ខែតុលា កន្លងទៅ នៅចំណុចវាលឥន្ទ្រីយ៍ក្បែរប្រាសាទព្រះវិហារ បន្ទាប់ពីកងទ័ពទាំងសងខាងបានប្រឈមមុខដាក់គ្នាដ៏តានតឹងអស់រយៈពេលជាងពីរខែទៅហើយនោះ ។

ការផ្ទុះអាវុធដាក់គ្នាជាលើកដំបូងនេះ បានកើតឡើងបន្ទាប់ពីកងទ័ពទាហានឈុតខ្មៅសៀមប្រមាណជាង10នាក់ បានព្យាយាមចូល


ចង់ចេញពីភាពទ្រុឌទ្រោម? RELIV អាចប្តូររូបរាងកាយឱ្យមាំទាំបាន



Dr. Earleen Ong, Fellow of Geriatric Medicine, Certified Family Physician

Dr. John Harold Ong, Orthomolecular Medicine, Associate of Geriatric Medicine

**Reliv: Nutrition for the 21st Century**

Today's modern processing techniques rob essential nutrients from much of our food. Reliv restores the balance by delivering a unique blend of the vitamins, antioxidants, minerals, proteins, amino acids and phytonutrients the body needs to restore energy, fight off infections and feel great — every day.




WWW.RELIV.COM

☞ ពិសារ Reliv រាល់ថ្ងៃ គឺនាំឱ្យមានកម្លាំងកាយ រូបរាងមាំមួនសម្ផស្សស្រស់បស់ឡើងបាន

☞ Reliv អាចទប់ស្កាត់នូវជំងឺមួយចំនួនធំ ដែលកើតមកពីការពិសារចំណីអាហារខ្វះជីវជាតិ ធ្វើឱ្យសរីរាង្គគាំងដំណើរ

☞ ពិសារ Reliv លោក-អ្នកនឹងដឹងពីប្រសិទ្ធភាពចាប់តាំងពីថ្ងៃដំបូង ដែលលោក-អ្នកប្រើ Reliv នេះភ្លាម ។

សូមទូរស័ព្ទជាវនៅលេខ : (636) 537 9715
. ដោយផ្តល់លេខសំគាល់ : RNC .7070 438001
បញ្ជាទិញ 1. RELIV CLAASIC មួយកំប៉ុង
2. Reliv INNERGINE មួយកំប៉ុង ដែលជាចំណីជីវជាតិ
លាយ RELIV 1 និង RELIV 2 ម្នាងមួយស្លាបព្រាក្នុងទឹកផ្លែឈើហើយពិសារម្តងឬពីរដងក្នុងមួយថ្ងៃ ទៅតាមភាពទ្រុឌទ្រោមនៃរូបរាងកាយ
" ភាពរឹងមាំកើតឡើងស្ទើរជឿមិនបាន "

ម្យ៉ាងវិញទៀត : នៅពេលឃើញប្រសិទ្ធភាពនៃ Reliv លោកអ្នកនឹងមានជំនឿថាអាចចែកចាយឱ្យមនុស្សច្រើនទៀតបាន

សូមទាក់ទងមកយើងខ្ញុំ ដើម្បីចុះឈ្មោះជា RELIV DISTRIBUTOR បន្តទៅទៀត លោកអ្នកអាចនឹងចំណេញប្រាក់ច្រើន ដោយសារតែបានជួយអ្នកដទៃឱ្យមានសុខភាពល្អដូចលោកអ្នកបាន

ទូរស័ព្ទនៅ Philadelphia : (267) 254 8758 នៅ VIRGINIA 703 415- 6257

មកក្នុងទឹកដីកម្ពុជាក្បែរតំបន់ប្រាសាទព្រះវិហារ ដែលត្រូវបានកងទាហានកម្ពុជារារាំងមិនឱ្យចូល រួចក៏បានបញ្ជាឱ្យត្រឡប់ទៅក្រោយវិញ ។ ពេលនោះកងទាហានឈុតខ្មៅសៀមបានធ្វើការបាញ់រះមកលើកងទាហានកម្ពុជាទាំងកំរោល ជាហេតុធ្វើឱ្យកងទាហានកម្ពុជាធ្វើការបាញ់តបតទៅវិញ ដើម្បីការពារខ្លួន ។

ហេតុការណ៍បាញ់តគ្នានោះ ភ្លាម១មានសេចក្តីរាយការណ៍ថា មានកងទាហានឈុតខ្មៅចំនួនពីរនាក់រងរបួសធ្ងន់ ចំណែកកងទ័ពកម្ពុជាត្រូវរបួសចំដៃឆ្វេងម្នាក់ ។

កងទាហានឈុតខ្មៅសៀមដែលបានព្យាយាមចូលមកក្នុងទឹកដីខ្មែរក្បែរតំបន់ព្រះវិហារនោះ គឺក្នុងគោលបំណងដើម្បីកាន់កាប់តំបន់ព្រលានឥន្ទ្រីយ៍ ជាចំណុចមួយស្ថិតនៅលើជំរាលភ្នំទ្រព្យ ដែលមានចម្ងាយប្រមាណជាង3គីឡូម៉ែត្រពីប្រាសាទព្រះវិហារ ។

ពួកគេបានអះអាងថា តំបន់នេះជារបស់ពួកគេ នេះបើតាមការបញ្ជាក់របស់លោកឧត្តមសេនីយ៍ត្រី ជា កែវ បញ្ជាការរងភូមិភាគ 4 ទទួលបន្ទុកឈរជើងនៅតំបន់ប្រាសាទព្រះវិហារ ។

ការផ្ទុះអាវុធដែលមិនធ្លាប់កើតមានពីមុនមកនោះ បានធ្វើឱ្យកងទ័ពជួរមុខទាំងកងទ័ពកម្ពុជា និងកងទាហានសៀម បានត្រៀមប្រយុទ្ធយ៉ាងប្រុងប្រយ័ត្នបន្ទាប់ពីឮស្នូរផ្ទុះអាវុធរួចមក ។

ឧត្តមសេនីយ៍ត្រី ជា កែវ បានឱ្យដឹងថា ស្នូរផ្ទុះអាវុធនោះ មិនមែនជាសំលេងផ្ទុះមីនទេ តែជាការបាញ់ចេញពីសំណាក់ទាហានឈុតខ្មៅសៀមមុន ។ លោកឧត្តមសេនីយ៍ត្រី បាននិយាយសំរាលស្ថានការណ៍ក្រោយពីបាញ់គ្នានោះភ្លាម១ថា ការផ្ទុះអាវុធនោះមិនមានសភាពធ្ងន់ធ្ងរទេ ហើយការស៊ើបអង្កេតជាក់លាក់មួយជុំវិញហេតុការណ៍នោះ កំពុងធ្វើឡើងហើយ ។

ក្រោយពីហេតុការណ៍ផ្ទុះអាវុធដាក់គ្នាភ្លាម១នោះរួចមក នៅថ្ងៃបន្ទាប់ក្រសួងការបរទេសកម្ពុជា បានផ្ញើកំណត់ទូតមួយច្បាប់ជូនឯកអគ្គរដ្ឋទូតសៀមប្រចាំនៅកម្ពុជាឱ្យបានជ្រាបពីរឿងនេះ ។ នៅក្នុងកំណត់ហេតុនោះរដ្ឋាភិបាលកម្ពុជា បានប្រកាសយ៉ាងដាច់អហង្ការប្រឆាំងនឹងការបង្កហេតុដ៏អាក្រក់ ដែលបង្កឡើងដោយកងទាហានសៀម ។

# បញ្ហាវិបត្តិកម្ពុជា មើលពីប្រទេសថៃ

### ដោយៈ ម៉ម យិន

វិបត្តិនយោបាយនៅក្នុងប្រទេសថៃ បានចាប់ផ្តើមកើតមានមកប្រមាណជាង 4ឆ្នាំមកហើយ ដោយសារតែក្រុមប្រឆាំងមួយក្រុម មានឈ្មោះថា ក្រុមសម្ព័ន្ធមិត្តប្រជាពលរដ្ឋ ដើម្បីប្រជាធិបតេយ្យ ។

ក្រុមប្រឆាំងនេះ មានគោលបំណងផ្តួលរំលំនាយករដ្ឋមន្ត្រី ឧត្តមសេនីយ៍តម្រួត តាក់ស៊ិន ជិនណាវ័ត្រ ដែលក្រុមនេះ ចោទថា ជានាយករដ្ឋមន្ត្រីប្រព្រឹត្តអំពើទុច្ចរិតពុករលួយ លក់ប្រទេសជាតិទៅឱ្យនាយទុនបរទេស កេងប្រវ័ញ្ចយកផលប្រយោជន៍ជាតិ មកបំរើផលប្រយោជន៍ផ្ទាល់ខ្លួន ។

ក្រុមប្រឆាំង បានជម្រុញឱ្យកងទ័ពជាតិថៃ ចេញមុខមកដកអំណាចនាយករដ្ឋមន្ត្រី កាលពីថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ2006 ដោយវិធីរដ្ឋប្រហារ ។

ក្រោយពីរដ្ឋប្រហារ ស្ថានភាពវិបត្តិនយោបាយបានធូរស្រាយបន្តិចមកវិញ រហូតមកដល់ចុងឆ្នាំ2007 រដ្ឋាភិបាលថ្មី បានចាប់ផ្តើមកើតមានឡើងវិញហើយ ដែលគណបក្សថ្មីមួយឈ្មោះ កម្លាំងប្រជាជនថៃ ហើយមានប្រធានបក្ស ដែលចេញមកពីគណបក្សចាស់ឈ្មោះ ថៃស្រឡាញ់ថៃ (ថៃរ័កថៃ) ជាគណបក្សអតីតនាយករដ្ឋមន្ត្រី តាក់ស៊ិន ។

នាយករដ្ឋមន្ត្រីថ្មីនោះ មានឈ្មោះថា សាម៉ាក ស៊ុនណាវែត ។ ក្រុមប្រឆាំង បានចាត់ទុកថា ជានាយករដ្ឋមន្ត្រីតំណាងឱ្យលោក តាក់ស៊ិន ក៏បានចាប់ផ្តើមប្រជុំតវ៉ាទាមទារឱ្យចុះចេញពីអំណាចម្តងទៀត ដោយចោទប្រកាន់ថា ជានាយករដ្ឋមន្ត្រីអាយ៉ង ។

មិនយូរប៉ុន្មាន នាយករដ្ឋមន្ត្រី សាម៉ាក់ ត្រូវបានតុលាការកំពូលកាត់ទោសឱ្យចាកចេញពីអំណាច ដោយសារតែប្រព្រឹត្តខុសវិន័យផ្ទៃក្នុងជានាយករដ្ឋមន្ត្រី ។

នាយករដ្ឋមន្ត្រីថ្មីមួយទៀត បានតែងតាំងឡើង គឺលោក សមឆាយ វង្សាវត្តិ ដែលត្រូវជាប្អូនថ្លៃរបស់លោក តាក់ស៊ិន ។ ក្រុមប្រឆាំងនៅតែបន្តការប្រជុំមហាជនទាំងថ្ងៃទាំងយប់ តវ៉ាទាមទារឱ្យលោក សមឆាយ នេះចុះចាកចេញពីតំណែងម្តងទៀត ។

បាតុកម្មនេះ បានរារាំងបិទផ្លូវខ្ទប់មន្ទីររដ្ឋសភា ដោយមិនព្រមឱ្យសមាជិកតំណាងរាស្ត្រ ព្រមទាំងគណរដ្ឋមន្ត្រីថ្មី ចូលទៅរួមប្រជុំ បណ្តាលឱ្យក្រុមតម្រួតរក្សាសន្តិសុខបាញ់គ្រាប់បែកផ្សែងពុល បង្ហូរទឹកភ្នែកបំបែកក្រុមបាតុករ ។ បាតុករចំនួន 3នាក់ត្រូវស្លាប់ និងរបួសជាង 400នាក់ ដោយសារតម្រួត ។

ឧប្បត្តិហេតុនេះ បានឈានដល់ការបង្ហូរឈាម ហើយបណ្តាលឱ្យក្រុមប្រឆាំង បង្កើតកំហឹងកាន់តែខ្លាំងឡើង ជាមួយនាយករដ្ឋមន្ត្រីថ្មី សមឆាយ រៀងរាល់ថ្ងៃ រហូតមកដល់វេលាថ្ងៃនេះ ។

ចំណែកឯបញ្ហាព្រំដែនប្រាសាទព្រះវិហារ ប្រាសាទតាមាន់ធំ-តូច ប្រាសាទតាក្របី បញ្ហាដែនដីនៅខេត្តកោះកុង និងដែនសមុទ្រប្រជុំកោះអាចមិសេះ (ប៉ូឡូវ៉ៃ) ដែលមានអណ្តូងប្រេងកាត និងឧស្ម័នធម្មជាតិ ។

ប្រទេសថៃ និងកងទ័ពថៃ បានបញ្ចេញប្រតិកម្មឱ្យឃើញយ៉ាងជាក់ស្តែងហើយថា ដរាបណាប្រទេសថៃ មិនបានទទួលនូវផលចំណេញអ្វីពីសកម្មភាពនោះបានទេ ដរាបនោះកងទ័ពថៃមិនអាចបញ្ចប់ដោយដកចេញទៅវិញ ដោយដៃទទេ ហើយដោយអាម៉ាស់បានទេ ។ ន័យម្យ៉ាងទៀត ប្រទេសថៃ បានចោទដោយចងកំហឹងថា រដ្ឋាភិបាលខ្មែរសព្វថ្ងៃ គឺជារដ្ឋាភិបាលនៅក្រោមអំណាច និងក្រោមបង្គាប់បញ្ជារបស់រដ្ឋាភិបាលយួនវៀតណាម នៅក្នុងគ្រប់កិច្ចការនៃប្រទេសខ្មែរទាំងមូលតែម្តង ។

ក្រុមប្រឆាំងនឹងរដ្ឋាភិបាលថៃនេះ ជាក្រុមមួយមានគោលជំហរខ្លាំងក្លាណាស់ ក្នុងការប្រើប្រាស់សិទ្ធិសេរីភាព ដើម្បីតវ៉ាទាមទារ និងប្តឹងចោទប្រកាន់ទៅលើនាយករដ្ឋមន្ត្រី និងមន្ត្រីសំខាន់ៗទាំងអស់ ដែលបានប្រព្រឹត្តអំពើទុច្ចរិតពុករលួយ រំលោភបំពានទៅលើច្បាប់នីតិរដ្ឋ ។

ក្រុមប្រឆាំង បានប្តឹងពីលោក តាក់ស៊ិន និងគ្រួសារ រួចហើយតុលាការជាន់កំពូល បានជំនុំជំរះកាលពីប៉ុន្មានខែកន្លងទៅ ឱ្យប្រពន្ធកូន និងបងប្អូន ត្រូវជាប់គុកពីរឆ្នាំ និងពិន័យរាប់ពាន់លានបាត បន្ទាប់មកថ្ងៃទី21 ខែតុលា ឆ្នាំ2007 នេះ តុលាការ កំពូលបានកាត់ទោសឱ្យលោក តាក់ស៊ិន ត្រូវជាប់គុកពីរឆ្នាំដែរ ។

សកម្មភាពដ៏ខ្លាំងក្លានៃក្រុមប្រឆាំងនេះ បានផ្សព្វផ្សាយចេញតាមរយៈបណ្តាញទូរទស្សន៍មួយឈ្មោះ AST NEWS 1 បានអញ្ជើញឱ្យបញ្ញាវ័នគ្រប់ជាន់ថ្នាក់ ទាំងចាស់ទាំងក្មេង ព្រមទាំងប្រជាពលរដ្ឋរាប់លាននាក់ចេញមកសំដែងការគាំទ្រ ទាំងកម្លាំងចិត្ត កម្លាំងកាយ និងលុយកាក់ទ្រព្យសម្បត្តិយ៉ាងគគ្រឹកគគ្រេងណាស់ ។ សកម្មភាពប្រឆាំងនេះ បានឈាមទៅដល់ស្ថានភាពដ៏មានវិបត្តិនយោបាយកាន់តែខ្លាំងឡើង ដែលជាបញ្ហាមួយបណ្តាលឱ្យមានគ្រោះថ្នាក់ទៅថ្ងៃអនាគតដ៏ខ្លីខាងមុខ ។

ចំណែកបញ្ហាវិបត្តិព្រំដែន និងប្រាសាទព្រះវិហារខ្មែរ ក្រុមប្រឆាំងនេះ ពុំដែលផ្តល់នូវវិធានការណាមួយសំរាប់ដោះស្រាយដោយសន្តិវិធី នៅលើគោលការណ៍យកច្បាប់ជាអាទិភាពទេ ។

ដូច្នេះក្រុមប្រឆាំងនៃសកម្មជនថៃនេះ កំពុងប្រើយុទ្ធសាស្ត្រមួយ ក្នុងគោលបំណងកំចាត់កំចាយរដ្ឋាភិបាលខ្លួនផង ដើម្បីសម្រេចគោលដៅរឹបអូសយកចំណុចតំបន់សំខាន់ៗ សម្បត្តិធម្មជាតិសំខាន់ៗ និងអណ្តូងប្រេងកាត ឱ្យបានទៅក្នុងកណ្តាប់ដៃនៃជនជាតិ និងប្រទេសថៃ ជាដាច់ខាត ៕


សពទាហានខ្មែរ ក្នុងសមរភូមិសង្គ្រាម


ទិដ្ឋភាពអ្នកលក់ដូរនៅផ្សាររុងក្លឿ

From :Philadelphia

ហាងខ្មែរជួសជុលរថយន្ត

បើចង់ឱ្យរថយន្តលោកអ្នករត់បានល្អ សូមអញ្ជើញ

Rathe`s Auto Service

State and Emission Inspection General Repairs and Maintenance

MON-SAT, 8:30AM -5:30PM
SUN. EMERGENCY ONLY




-ជាងមានបទពិសោធន៍ជាយូរឆ្នាំ -ជួសជុលរថយន្តគ្រប់ប្រភេទ
-មានដូរប្រេង ដូរហ្វ្រាំង ដូរកង់ និងករណីជាច្រើនទៀត ។
-មានត្រួតពិនិត្យគ្រឿងម៉ាស៊ីន DIAGNOSTICS ដោយឥតគិតថ្លៃ -មានចុះថ្លៃពិសេស ចាប់ពីខែកុម្ភៈ ២០០៨
ទៅ : -ដូរប្រេងកិរត ៥ក្វាត $22. - INSPECTIONS រថយន្តឆ្នាំ 96 up $49.99+ តាក់-មានជូនប័ណ្ណពិសេស សំរាប់ដូរប្រេង ចុះថ្លៃពាក់កណ្តាល នៅពេលយកមកជួសជុលអស់តម្លៃ $150.
-តម្លៃជួសជុលទូទៅ សមរម្យ ដោយទាបជាងហាងជួសជុលផ្សេងៗទៀត
- ប្តេជ្ញាចិត្តធ្វើជូនដោយហ្មត់ចត់ គុណភាពខ្ពស់ មិនឱ្យខុសបំណងលោកអ្នកឡើយ ។
ពិសេស ជួយទៅពិនិត្យដល់កន្លែងនូវរថយន្តណាដែលខូច STARTER ឬផុងអាគុយអស់ភ្លើងដោយឥតគិតថ្លៃ ។ *សូមអរគុណ !*

5105 N.2ND ST., PHILADELPHIA, PA 19120. TEL: (215) 329-2418
Fax: (215) 329-2419.Rath CELL: (215) 431-6376

# កំរៃបានលុយបាត

**និពន្ធដោយអ្នកស្រី ខុសុម អុង**

ទឹកមួយអម្រែកទុកក្បែរខ្ទម កាយម៉ែស្គាំងស្គមចិត្តរំជួល
យាត្រាស្កាត់សួរចិត្តជ្រើមជ្រួល ហៅចិនបបួលឱ្យទិញទឹក ។
បានលុយបាតគឺជាលុយថៃ ម៉ែបានកំរៃអាហារព្រឹក
ទិញបាយអាហារមិនសន្ទឹក ត្បិតថ្លៃប្រាក់ទឹកត្រឹមដប់បាត ។
ជីវិតម៉ែឪជួបទុក្ខធំ រស់មិនសុខំដូចសត្វធាតុ
ពេលស៊ីពេលដេកនៅខ្វះខាត ផ្ទែកគ្រឿងសំអាតខាងរាងកាយ
ដូចជាខោអាវបិទបាំងកាយ មានមួយសំពាយស្រោលមិនធូន់ ។

# បានត្រឹមតែឆី

**និពន្ធដោយអ្នកស្រី ខុសុម អុង**

ដៃចិតបន្លែដូរបាយឆី ក្រពិតក្រក្រីឥតលុយបាត
ម្ចាស់បាយឥតគិតឥតសង្វាត ត្រូវតែឱ្យខាតត្រឹមបាយពិត ។
មានសម្ល និងបាយឱ្យថ្ងៃ ម្ចាស់បាយលកលៃត្បិតអាណិត
រីឯលុយបាតឥតបើគិត ហត្ថាម៉ែចិតហាន់បន្លែ ។
ម្ចាស់បាយលក់បាយអ្នករត់ពន្ធ សោហ៊ុយបានគ្រាន់គួរសមដែរ
បើក្រឡេកមើលមុខម៉ែ កើតទុក្ខឥតល្ហែគ្មានលុយបាត ។

# កុំភ្លេចថ្ងៃទី17 ខែកុម្ភៈ ឆ្នាំ2009
## សម្រាប់អ្នកប្រើទូរទស្សន៍

•••នៅថ្ងៃទី17 ខែកុម្ភៈ ឆ្នាំ2009 ទូរទស្សន៍លោកអ្នកអាចនឹងត្រូវរលត់ បើលោកអ្នកមិនប្រើប្រព័ន្ធ DTV ទេនោះ ។

ច្បាប់ថ្មីនៃសហរដ្ឋអាមេរិក បានបង្គាប់ឱ្យមានការប្តូររលកធាតុអាកាសនៃការប្រើទូរទស្សន៍ ដើម្បីឱ្យទូទស្សនិកជនអាចទទួលបានរូបភាព និងសម្លេងបានច្បាស់ល្អប្រសើរ ។ តែម្យ៉ាងវិញទៀតនោះ រដ្ឋចង់ឱ្យមានរលកធាតុអាកាសមួយចំនួននោះ នៅទំនេរសម្រាប់ការប្រើសម្រាប់សង្គ្រោះជាបន្ទាន់ សម្រាប់ប៉ូលិសធ្វើការទាក់ទងគ្នា ។ល ។





ពេលឥឡូវនេះ ទូរទស្សន៍ប្រើរលកធាតុអាកាសពីរយ៉ាង ដែលគេហៅថា ANALOG ផង និង DIGITAL ផង ។ នៅបន្ទាប់ពីថ្ងៃទី17 កុម្ភៈ ឆ្នាំក្រោយនេះទៅ គឺអ្នកប្រើទូរទស្សន៍ ANALOG នឹងត្រូវប្តូរប្រើជា DIGITAL ទាំងអស់គ្នា ។ ពាក្យ DTV មានន័យថា DIGITAL TELEVISION ជាទូរទស្សន៍គំរូតែមួយ បន្ទាប់ពីថ្ងៃកំណត់នោះទៅ ។

តើលោកអ្នកដែលកំពុងប្រើប្រាស់ទូរទស្សន៍ ANALOG នោះត្រូវធ្វើយ៉ាងណា ?

1. លោកអ្នកត្រូវភ្ជាប់ទូរទស្សន៍ ANALOG របស់លោកអ្នកទៅនឹងប្រអប់ប្តូរ " DIGITAL-TO-ANALOG " មុននឹងភ្ជាប់ទៅអង់តែនវិញ "ប្រអប់ប្តូររលកធាតុអាកាស " នោះ លោកអ្នកអាចទិញយកមកដាក់ដោយខ្លួនឯងបាន ក្នុងតម្លៃពី 40-70ដុល្លារ ។ នៅខែមករា ឆ្នាំ2009 រដ្ឋនឹងសងលោកអ្នកដោយផ្តល់ជូននូវ គូប៉ុន តម្លៃ 40ដុល្លារ ចំនួនពីរសម្រាប់ផ្ទះនីមួយៗ ។ សូមទូរស័ព្ទទៅសួររក 1-888-388-2009 ឬ មើលនៅវេបសាយ www.dtv2009. gov ។

2. ទិញទូរទស្សន៍ថ្មី ដែលប្រើប្រព័ន្ធ DIGITAL ស្រាប់ ។

3. ទិញសេវាទូរទស្សន៍ ដូចជា " Cable " ឬ "ទូរទស្សន៍ SATELLITE ដោយទាក់ទងទៅអ្នកលក់សេវាទូរទស្សន៍ ។

សូមរំលឹកថា លោកអ្នកត្រូវប្រើប្រអប់ប្តូររលកធាតុអាកាស តែជាមួយទូរទស្សន៍ ANALOG តែប៉ុណ្ណោះ ពុំចាំបាច់ប្រើនៅទូរទស្សន៍ DIGITAL ទេ ៕

**Washington Wellness Care** មន្ទីរថែរក្សាខ្លួនប្រាណ "វ៉ាស៊ីនតុន"
Medical & Rehab.
ដោយវិជ្ជាពេទ្យ និងការបង្ហាត់រាងកាយឱ្យដើរឡើងវិញ

Medical & Rehab.
500 Washington Ave., 1st Fl.
Philadelphia, Pa 19147
Phone: 215.551.6838. Fax: 215.551.6718

**Dr. Scott C. Tran, D.C. Dr. Michael Barno, D.C. Dr. Zohar Stark, M.D.**

***We are specialized in treating:***

- Auto Accident Injuries - Work Related Injuries - Slip & Fall Injuries

**យើងមានជំនាញក្នុងការព្យាបាល :**

☞ របួសដោយគ្រោះថ្នាក់រថយន្ត ☞ របួសដោយទាក់ទងនឹងកន្លែងធ្វើការ ☞ របួសដោយរអិល ឬដួល

We have staffs who speaks Vietnamese, Chinese, and Cambodian
For Cambodian and Vietnamese Speaking Staff, please call Ricky Son at 215.380.1350
For English Speaking Staff, please call 215.551.6838

**យើងមានបុគ្គលិកដែលនិយាយភាសា វៀតណាម, ភាសាចិន , និងភាសាខ្មែរ**
ទាក់ទងជាមួយបុគ្គលិកខ្មែរ និងវៀតណាម សូមទូរស័ព្ទទៅ **រីគី សុន (215) 380-1350**
ទាក់ទងទៅបុគ្គលិកនិយាយភាសាអង់គ្លេស សូមទូរស័ព្ទទៅ **(215) 551-6838**

កំណាព្យ

# ចិត្ត និង គំនិត

ឧស្សាហៈវិស័យ

ដោយ : ម៉ម យិន





ចិត្ត និងគំនិតនៃមនុស្សលោក
សំរាប់ដឹកនាំជនទាំងឡាយ
តើចិត្តបានចេញមកពីណា
ដែលជាដួងកែវនៃជីវិត
ចិត្តនេះចែកចេញជាពីរផ្លូវ
នាំជីវិតឱ្យមានសុខា
ចិត្តទីពីរនោះជាចិត្តចោរ
នាំឱ្យជីវិតមានវិបត្តិ
ពេលខ្លះចិត្តចង់សាងក្តីល្អ
ចិត្តចង់ដើរតាមផ្លូវអ្នកប្រាជ្ញ
ចិត្តមិនវៀចវេមិនឃោឃៅ
ចិត្តសែនសប្បាយចិត្តអាណិត
ដោយក្តីក្រខ្សត់ក្តីលំបាក
ចិត្តសែនអាណិតហើយក្តួលក្តុក
នេះហើយជាចិត្តនៃបណ្ឌិត
ឱ្យមានជីវិតបានរួចរស់
មានចិត្តមួយទៀតសែនយង់ឃ្នង
នាំឱ្យជីវិតមានតែទុក្ខ
ចិត្តនេះខិតខំប្រព្រឹត្តធ្វើ
ចិត្តចង់ជិះជាន់ចង់ជម្រិត
ចិត្តធ្វើបំពានគ្មានប្រណី
ធ្វើទុក្ខបុកម្នេញចិត្តក្តួលក្តៅ
ចិត្តសែនកោងកាចកេងប្រវ័ញ្ច
តាំងចិត្តឱ្យធំហើយឧត្តុង្គ
ចិត្តនេះកើតចេញពីបេះដូង
ចិត្តស្មោគគ្រោកគ្រែចិត្តចង់លួច
គំនិតតាមពិតចេញមកពី
ដែលជាប្រាជ្ញាត្រួសត្រាយផ្លូវ
ពេលខ្លះគំនិតគិតឃើញត្រូវ
ពេលខ្លះគិតសុខធ្វើទុច្ចរិត
គំនិតគិតខុសព្រោះក្តីល្ងង់
គិតឃើញតែខ្លាំងទើបអស្ចារ្យ
គំនិតបែបនេះ អាក្រក់ណាស់
កុំយកគំនិតគិតភ្លីភ្លើ
ចិត្ត និងគំនិតជាអំណាច
បើចិត្ត គំនិតនៅរួមដៃ
បើសិនជាចិត្ត និងគំនិត
ពេលនោះជីវិតមានតែទុក្ខ
សូមចិត្ត គំនិតគិតឱ្យច្បាស់
ត្រូវចិត្ត គំនិតកុំនៅឈ្លក់
ចិត្ត និងគំនិតល្អពិសេស
ជីវិតបានសុខសាន្តពេកក្រៃ

បានជាប់មានមកគ្រប់រូបភាព
ដោយបានដោះស្រាយតាមចិត្តគិត ។
ឆ្លើយថាចេញពីបេះដូងពិត
ឱ្យរស់រានមានិតតាមធម្មតា ។
ចិត្តមួយត្រឹមត្រូវល្អថ្លៃថ្លា
សប្បាយជ្រះថ្លាសែនបរិសុទ្ធ ។
ចិត្តដ៏ពេញពោរអាក្រក់បំផុត
រងទុក្ខច្រើនក្តាត់គួរភ័យខ្លាច ។
ចិត្តសប្បុរសធមិមិនកោងកាច
នាំចិត្តអង់អាចទៀងត្រង់ពិត ។
ចង់ធ្វើត្រឹមត្រូវដ៏ពិសិដ្ឋ
ដល់ជនរួមរឹតដោយក្តីទុក្ខ ។
លំបិនឥតស្រាកចំពោះមុខ
ចិត្តហ៊ានចេញមុខជួយដោយស្មោះ ។
អ្នកប្រាជ្ញល្អពិតតែងសង្គ្រោះ
សុខសាន្តទាំងអស់គ្មានរើសមុខ ។
ចិត្តតែងប៉ុនប៉ងចង់អុកឡុក
យល់ថាផ្លូវសុខរបស់ចិត្ត ។
ទុច្ចរិតអំពើយ៉ាងជិតស្និទ
ចាប់ចងតាមចិត្តយ៉ាងឃោឃៅ ។
ចិត្តកាចអប្រិយ៍ចិត្តមួរម៉ៅ
ចិត្តល្អតែក្រៅតែក្តៅក្នុង ។
ចិត្តសែនឃ្នាន់ខ្នាញ់ចង់ប្រៀបប្រុង
ឱ្យខ្ពស់លើសលង់គ្មានអ្វីដូច ។
ស្ថិតនៅក្នុងទ្រូងនៃមនុស្សខូច
ចង់ជាន់អ្នកតូចកុំឱ្យនៅ ។
ខួរក្បាលជាទីតាំងគោលដៅ
ជីវិតត្រឹមត្រូវតាមគំនិត ។
នាំដើរសំដៅក្តីសុខពិត
នាំឱ្យជីវិតរងវេទនា ។
គិតឃើញខ្ពស់ខ្ពង់តាមប្រាថ្នា
គិតហើយយល់ថាត្រូវតែធ្វើ ។
ត្រូវគិតឱ្យច្បាស់ទើបប្រសើរ
គំនិតល្ងិល្ងើថោកទាបក្រៃ ។
ឆន្ទៈអង់អាចដ៏ថ្លៃថ្លា
ធ្វើឱ្យប្រពៃបានក្តីសុខ ។
ខំធ្វើប្រព្រឹត្តអបាយមុខ
ចិត្តគំនិតផុកតែអាក្រក់ ។
ជីវិតធំណាស់ ហើយគ្មានលក់
នាំឱ្យវិវក់កើតទុក្ខភ័យ ។
ទើបនាំឱ្យឈ្នះបានជោគជ័យ
សន្តិភាពលើផ្ទៃផែនដីអើយ ៕

**សូមអរគុណ !**

# Tax Cuts Cannot Overcome Job Losses

●●● លោក ស៊ីវិនឡូ ជាអ្នកអានម្នាក់ដែលចង់ផ្សព្វផ្សាយអំពីទស្សនៈបេក្ខជនប្រធានាធិបតីអាមេរិកាំង សំរាប់ថ្ងៃបោះឆ្នោតទី4 វិច្ឆិកា ខាងមុននេះ ។ លោក ឡូ បានធ្វើការទិទានអំពីការបាត់បង់ការងារយ៉ាងច្រើនរបស់ប្រជាពលរដ្ឋអាមេរិកាំង នៃរដ្ឋាភិបាលលោក ប៊ុស ហើយរបៀបកាត់តាក់របស់លោក ចន ម៉ាកេន នឹងដើរតាមនយោបាយរបស់លោក ប៊ុស ដដែល ។ រីឯលោក អូបាម៉ា លោក ឡូ យល់ថា នយោបាយបញ្ចប់សង្គ្រាមភ្លាម និងបន្ថយប្រាក់ចំណាយរបស់សហរដ្ឋអាមេរិក បានយ៉ាងសន្ទឹកសន្ទាប់ ។




With the U.S. Labor Department's announcement of the largest job loss in five years, undecided voters need to think long and hard about whether the Republican policies of John McCain and Sarah Palin will restore the economy.

After nine months of continuing job losses, McCain-Palin have only offered more tax cuts for the rich and general appeals to reduce government spending. What they fail to mention is that the richest 1% have been receiving the tax cuts for the last seven years, and the result is 9.5 million unemployed Americans. Another 6.1 million American are underemployed in part-time work, because full time work is unavailable. (U.S. Dept. of Labor News Release, 08-1367, 10/3/2008).

Keep in mind that this result would probably be worse were it not for the $66 billion stimulus package implemented in May. Of the 9.5 million unemployed, twenty- one percent (21%) have been unemployed more than 27 weeks.

McCain has said that the American workers are willing to work hard; and that therefore, the fundamentals of the economy are strong. American workers can't work hard if the employers receiving those tax cuts are laying them off. McCain and Palin have not explained where the money will come from to pay for their tax cuts much less continuing the $10 billion each month for the war in Iraq. Barack Obama has a plan that reduces wasteful outsourced contracts to pay for his green job creation program.

By responsibly ending the war in Iraq, Barack Obama will reduce the billions in interest payments every month to the Chinese and Saudi governments for their war loans. McCain and Palin want to continue the war for some mythical victory, which they have yet to define. As many have asked, "If the surge is working, why can't our troops come home?"

Instead, McCain and Palin will have us continuing to pay interest to other countries to finance the endless war. With nearly 10 million Americans out of work, U.S. companies closing or filing bankruptcy, McCain-Palin's policies of borrow and spend do not put "country first."

Folksy chatter and winks at the camera are not a substitute for serious economic programs to put Americans to work. It's time to get off the fence and support a viable plan that jump starts the U.S. economy by voting for Barack Obama and Joe Biden.
Tsiwen Law,

វិចារណកថា

# នេះហើយ ឬយុត្តិធម៌ សំរាប់ម្ចាស់ឆ្នោត?

**ភ្នំពេញ, ខ្មែរប៉ុស្តិ៍ : ស៊ុម សុភាឫទ្ធិ**

●●●មុនពេលបោះឆ្នោតអ្នកនយោបាយគ្រប់គណបក្សបានដើរអង្វររាស្ត្របោះឆ្នោតឱ្យគណបក្សរបស់ខ្លួន ដោយសន្យាថានឹងរកយុត្តិធម៌ដោះស្រាយទំនាស់ដីធ្លីជូនពួកគាត់វិញ គឺមិនឱ្យពួកឈ្មួញរំលោភបំពាន ឬដកហូតនោះទេ ។

ប៉ុន្តែបន្ទាប់ពីទទួលបានជោគជ័យក្នុងភាពមិនយុត្តិធម៌ពោរពេញទៅដោយការតវ៉ាទាមទាររបស់ម្ចាស់ឆ្នោតនោះ គណបក្សប្រជាជនកម្ពុជា (CCP ) ហាក់ដូចជាភ្លេចអស់នូវការសន្យារបស់ខ្លួនឈឹង ហើយបើកដៃឱ្យពួកឈ្មួញបង្ក្រាបព្យុះភ្លៀង ធ្វើបាបរាស្ត្រស្រេចតែអំពើចិត្ត ដូចជា បណ្តេញប្រជាជនពីលំនៅឋាន, ចាប់ដាក់គុក, បាញ់ប្រហារយ៉ាងសាហាវព្រៃផ្សៃខ្លាំងណាស់ ។

ទង្វើយ៉ាងឃោរឃៅរបស់ពួកឈ្មួញ ដែលបង្កបញ្ហាជាមួយអ្នកស្រុកស្ទើរគ្រប់ខេត្ត-ក្រុងនេះ ត្រូវបានគេមើលឃើញថា "មានខ្នងបង្អែកនៅពីក្រោយ" ហើយពួកគេជាអ្នកតំណាងរាស្ត្រ ឬជាភរិយាអ្នកតំណាងរាស្ត្រ និងរដ្ឋមន្ត្រី ក៏មានដែលភាគច្រើនជាបក្ខពួករបស់គណបក្សប្រជាជនកម្ពុជា ។

ជនពុករលួយទាំងនោះ ភាគច្រើនកើតចេញពីបក្ខពួកសាច់ញាតិ និងការសូកប៉ាន់ប្តូរយកតំណែងរាជការ ដើម្បីបានអំណាចធ្វើការគំរាមកំហែងប្រជាពលរដ្ឋស្លូតត្រង់ប៉ុណ្ណោះ ។ ពួកគេទាំងនោះមិន សូវខ្វល់ខ្វាយជាមួយនឹងសុខទុក្ខការឈឺចាប់របស់រាស្ត្រក្រីក្រនោះទេ ហើយរាល់សំណូមពររបស់ អ្នកស្រុកត្រូវបានគេជាន់ឈ្លី និងម៉ាក់ងាយថែមទៀត ។

ចំណែកប្រជាពលរដ្ឋបានត្រឹមតែទទួលការឈឺចាប់សំរែកទួញយំជាប់គុក និងបាត់បង់ទ្រព្យសម្បត្តិអាយុជីវិតប៉ុណ្ណោះ ហើយទង្វើនេះវាផ្ទុយពីជាតិសាសន៍ដទៃ ដែលគេសុខចិត្តបូជាអាយុជីវិត ដើម្បីប្រជាពលរដ្ឋ និងជាតិមាតុភូមិ ។

ប្រជាពលរដ្ឋខ្មែរគ្រប់វ័យតែងស្រមៃថាបន្ទាប់ពីបោះឆ្នោតរួចនឹងមានតំណាងរបស់ខ្លួនដ៏ល្អ ជួយការពារផលប្រយោជន៍តិតតូរពីសុខទុក្ខជួយរកយុត្តិធម៌ពេលមានរឿងកើតឡើងម្តងៗ ។

ប៉ុន្តែការគិតរបស់ពួកគាត់ខុស 180 ដឺក្រេ គឺត្រូវតំណាងរបស់ខ្លួនមួយចំនួនឃុបឃិតជាមួយ អាជ្ញាធរគ្រប់ជាន់ថ្នាក់គំរាមកំហែងដកហូតយកដីស្រែចំការរបស់ពួកគាត់ ដែលគាត់ធ្លាប់កាន់កាប់យ៉ាងយូរឆ្នាំមិនមានការអៀនខ្មាសបន្តិចសោះ ។

មុនពេលបោះឆ្នោត និងក្រោយពេលការបោះឆ្នោតសង្គ្រោមដីធ្លីរវាងប្រជាពលរដ្ឋជាមួយពួកឈ្មួញ ដែលមានអាជ្ញាធរ និងមន្ត្រីថ្នាក់ខ្ពស់នៅពីក្រោយខ្នងបានបង្កព្យុះភ្លៀងដោយគ្មានញញើតដៃ ក្នុងការបណ្តេញប្រជាពលរដ្ឋឱ្យចាកចេញពីផ្ទះក្រោមរូបភាពតំបន់អភិវឌ្ឍន៍ ។

គ្រប់កាលៈទេសៈអាជ្ញាធរគ្រប់ជាន់ថ្នាក់តែងឈរជាមួយពួកឈ្មួញម្នាក់ ឬពីរនាក់តែប៉ុណ្ណោះ ហើយសុខចិត្តរុញច្រានប្រជាពលរដ្ឋរាប់ពាន់គ្រួសារឱ្យស្រែកយំ និងខ្លះទៀតត្រូវគេចាប់ដាក់ គុកយ៉ាងអយុត្តិធម៌ ។ ជាក់ស្តែងការអនុវត្តសាលដីកាតុលាការខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី 21 មីនា 2005 ប៉ូលិស-ប៉េអឹម 240នាក់ ប្រដាប់ដោយអាវុធចុះទៅបង្ក្រាបពួកជនពិការនៅភូមិក្បាលស្ពានឃុំប៉ោយប៉ែត ស្រុកអូរជ្រៅគ្មានញញើតដៃ ។ ដោយគ្រាន់តែប្រើប្រាស់សិទ្ធិការពារខ្លួនសមត្ថកិច្ច បានបាញ់ជនពិការ6នាក់ ស្លាប់នឹងកន្លែងព្រមទាំងរបួស៧នាក់ រហូតមកដល់ពេលនេះ យុត្តិធម៌សំរាប់ពួកគាត់មិនទាន់ផ្តល់ជូននៅឡើយទេ ។

កាលពីថ្ងៃទី19 សីហា 2008 អ្នកស្រី តុង ស៊ាត រស់នៅភូមិជាំម្លូរ ឃុំរកាពប្រាំ ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម ដែលមានទំនាស់ដីធ្លីប្តីគាត់ត្រូវគេចាប់ដាក់គុក ចំណែកឯផ្ទះសំម្បែងរបស់គាត់ ត្រូវមេឃុំដុតចោលទៀតផង គួរឱ្យអនិច្ចាខ្លាំងណាស់ ។

នៅថ្ងៃទី 11 កញ្ញា 2008 តំណាងអ្នកស្រុក 2 នាក់ នៅភូមិឡពាង ឃុំតាជេស ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ដែលប្តឹងប្តល់រឿងដីធ្លីជាមួយក្រុមហ៊ុន ខេ ឌី ស៊ី ត្រូវតុលាការចាប់ដាក់គុក ដែរ ។

តាមរយៈសកម្មភាពខាងលើនេះគ្រាន់តែជាជ្រុងតូចមួយប៉ុណ្ណោះ គឺវានៅមានច្រើនថែមទៀត ហើយយើងមានអារម្មណ៍ក្តុកក្តួល និងសង្វេគក្នុងចិត្តយ៉ាងខ្លាំងនៅពេលឃើញអាជ្ញាធរសមត្ថកិច្ចយកច្បាប់ និងអំណាចដែលប្រជាពលរដ្ឋប្រគល់ឱ្យទៅការពារអ្នកមានលុយ និងមានអំណាចនោះ ។

ការបណ្តេញប្រជាពលរដ្ឋចេញពីលំនៅឋាន គំរាមកំហែងចាប់ដាក់គុក និងបាញ់ប្រហារ ដែលអាជ្ញាធរមួយចំនួនធ្វើជាខ្នងបង្អែករបស់ឈ្មួញបង្កព្យុះភ្លៀងដល់ប្រជាពលរដ្ឋនោះ វាជាទង្វើអាក្រក់ខ្លាំងណាស់ ដែលសង្គមមានការស្អប់ខ្ពើម បើពួកគេពុំកែប្រែនោះទេ នឹងត្រូវបណ្តាសាវិនាសហិនហោចទ្រព្យសម្បត្តិយសសក្តិ នៅថ្ងៃណាមួយមិនខានឡើយ ៕

## CAHRAD
**Cambodian Americans for Human Rights and Democracy**
**ខ្មែរ-អាមេរិកាំងដើម្បីសិទ្ធិមនុស្សនិងប្រជាធិបតេយ្យ**
http://www.CAHRAD.org

Press Release October 23, 2008

ព្រឹត្តិការណ៍ប្រវត្តិសាស្ត្រខ្មែរ ដ៏ធំមួយបានកើតឡើងនៅថ្ងៃទី23 ខែតុលា ឆ្នាំ1991 នៅពេលដែលកិច្ចប្រជុំមួយនៅទីក្រុងប៉ារីស បានសម្រេចឱ្យកម្ពុជា មានការបោះឆ្នោតដោយសេរី និងយុត្តិធម៌មួយ ដើម្បីបង្កើតសន្តិភាពនៅកម្ពុជា ។ 17ឆ្នាំក្រោយមកអង្គការ " ខារ៉ាត " បាននិយាយថា នៅតែគ្មានសន្តិភាពដដែល ។

**Commemorating the 1991 Paris Peace Agreement For Cambodia**

Today, October 23, we, Cambo dian Americans in the Washington, D.C area, are commemorating the "Paris Peace Agreement" that was signed seventeen years ago, October 23, 1991, by nineteen countries including neighbor countries Vietnam, Thailand, and Laos. Parts of the Agreement are to

- recognize and to respect, the sovereignty, independence, territorial integrity and inviolability, neutrality and national unity of Cambodia
- allow all Cambodians to enjoy the rights and freedom embodied in the Universal Declaration of Human Rights and other relevant international human rights instruments.

Today, we, joining with other Cambodians worldwide, appeal to those 19 signatory countries including -Vietnam, Thailand, Laos, and Cambodia - to abide, conform, conduct, and observe these above terms that they signed on October 23, 1991 in Paris. Especially at this present moment when there is a dangerous border conflict with Thailand. Thailand is currently violating Cambodian territory surrounding the historical Preah Vihear temple which the International Court in the Hague decided in the verdict in 1962 that the temple belongs to Cambodia. Presently, the situation is very precarious and dangerous in which the fighting flared up causing the loss and suffering of human life and properties; a conflict that can potentially become regional.

Vietnam has not respected Cambodia sovereignty, independence, and territorial integrity by forcing Cambodia to accept the incompatible border treaties made under Vietnam occupation of Cambodia. Recently, Vietnam kidnapped across the border a Samaritan Cambodian Buddhist monk, Venerable Tim Sakhorn, from Pagoda in a Cambodian village and imprisoned him in Vietnam in June 2007 by fabricating and accusing him of inciting violence in Vietnam. In reality, all Venerable Tim Sakhorn did, was to shelter and provide food to the fleeing Buddhist monks Khmer Krom and their supporters who tried to escape from persecutions and oppressions in demanding religious freedom from the Communist Vietnam. Vietnam also has been interfering in Cambodia internal affairs by sending millions of illegal Vietnamese immigrants to destabilize Cambodian economic and social fabric. In addition, Vietnam never honestly and sincerely cooperate and implement the term of the Agreement regarding the withdrawal and non-return of foreign forces, advisers, and military personnel as stipulated in Part I, Article 8. Through its disguised military personnel, advisers, secret and intelligent agents, Vietnam is fully able to influence and dictate the current Cambodian government which it installed in 1979 when it illegally invaded Cambodia to implement and execute its hegemony goal of conquering Cambodia and transform it to Vietnam.

Even though Part III, Article 15, 2a stipulated that Cambodia undertakes to ensure respect for and observance of human rights and fundamental free dom in Cambodia and to support the rights of all Cambodian citizens to undertake activities that would promote and protect human rights and fundamental freedoms, Cambodia has not taken enough steps to honor those stipulations. According to the U.S. State Department in 2008, Cambodia's "human rights record remained poor… security forces committed extrajudicial killings and acted with impunity… government restricted freedom of speech and the press…Political activists continued to be the victims of killings…" Land grabbing are everywhere causing tremendous suffering of poor people, peasants and farmers. Corruption is rampant as Mr. Yash Gai, a former Special Representative of the Secretary-General for human rights in Cambodia, said, "the rights situation was getting worse" in December, 2007 when he joined with U.S. Ambassador Mussomeli and 500 local rights activists in a rally marking international Human Rights Day demanding the Cambodian govern- ment to end corruption, halt land theft of the dispossessed, and to stop the arrest of protestors.

We, Cambodians, would like to appeal to his and her excellencies, UN Secretary-General, UN Security Council members, the Presidents of the "Paris Peace Agreement", the Foreign Affair Ministers of the 19 signatory countries to reconvene to reevaluate and to follow up the efficacy, effectiveness, and to remedy the shortcoming of the Agreement. Cambodian people always greatly appreciate and are profoundly grateful of the effort and commitment of the international community that took over TWELVE YEARS at the cost of TWO BILLIONS dollars to provide peace and prosperity to Cambodian people. Cambodian people always trust and hope that the kindness and the good nature of the international community will redeem and reclaim the goal, meaning, and purpose of the Agreement.

Respectfully Yours,

Tung Yap
President, Cambodian Americans for Human Rights and Democracy
Email: tung@CAHRAD.org
Website: www.CAHRAD.org

នាទី ប្រវត្តិសាស្ត្រ

ទំព័រហ្វីឡាដែលហ្វីយ៉ា

# ពីរដ្ឋបាលកុលសម្ព័ន្ធមករដ្ឋាភិបាលសម័យ

**ដោយ : ពិនសំខុន** ***តពីលេខមុន***

**ឆ្នាំ 1959**

13 មករា : សម្តេចសីហនុ ប្រកាសគម្រោងឃុបឃិតទម្លាក់ព្រះអង្គ ដោយទីក្រុងបាងកក និងដោយមានជំនួយពី សម សារី ។

19 មករា : ការសម្ពោធអាកាសយានដ្ឋានពោធិចិនតុង ដែលជាផ្លូវអាកាសអន្តរជាតិ សង់ដោយប្រទេសបារាំង ។

17 កុម្ភៈ : ប្តូររដ្ឋាភិបាលថ្មីមួយទៀត ដឹកនាំដោយ នរោត្តម សីហនុ :

**រដ្ឋាភិបាល នរោត្តម សីហនុ (17.2.1959-13.6.1959)**

- នាយករដ្ឋមន្ត្រី : នរោត្តម សីហនុ
- ឧបនាយរដ្ឋមន្ត្រី-រដ្ឋមន្ត្រីការបរទេស : សឺន សាន
- ឧបនាយករដ្ឋមន្ត្រី-រដ្ឋមន្ត្រីមហាផ្ទៃ-យុត្តិធម៌-ព័ត៌មាន-ផែនការ និងបោសសំអាតទូទៅ : ញឹក ជូឡុង
- ទេសរដ្ឋមន្ត្រី-ប្រតិភូអមទីស្តីការគណៈរដ្ឋមន្ត្រី : ជា ជិនកុក
- ទេសរដ្ឋមន្ត្រីទទួលបន្ទុកការពារជាតិ : លន់ ណុល
- ទេសរដ្ឋមន្ត្រីទទួលបន្ទុកសន្តិសុខជាតិ និងការពារលើផ្ទៃប្រទេស : គូ រុន
- រដ្ឋមន្ត្រីហិរញ្ញវត្ថុ : ទ្រឿង កាង
- រដ្ឋមន្ត្រីសាធារណការ និងទូគមនាគមន៍ : ផ្លែក ឆាត
- រដ្ឋមន្ត្រីកសិកម្ម : លឹម ត្រី
- រដ្ឋមន្ត្រីពាណិជ្ជកម្ម និងឧស្សាហកម្ម : អេង ហ៊ុន
- រដ្ឋលេខាធិការព័ត៌មាន និងទេសចរណ៍ : ទីប ដុង
- រដ្ឋលេខាធិការអប់រំជាតិ-វិចិត្រសិល្បៈ-កីឡា និងយុវជន : ចៅ សេង
- រដ្ឋលេខាធិការការងារ និងសង្គមកិច្ច : យឹម ឌិត
- រដ្ឋលេខាធិការផែនការ : ហ៊ូ យន់
- រដ្ឋលេខាធិការធម្មការ-ពុទ្ធិកៈសិក្សា និងទំនាក់ទំនងជាមួយសភា : អ៊ឹង ហុងសាត
- រដ្ឋលេខាធិការសាធារណសុខាភិបាល : យូ គីមយាន
- អនុរដ្ឋលេខាធិការផែនការទទួលបន្ទុកផ្នែកផលិតកម្ម និងបរិក្ខារ : ឌី បែល ឡុង
- អនុរដ្ឋលេខាធិការយុត្តិធម៌ទទួលបន្ទុកបោសសំអាតទូទៅ : ហ៊ូ នឹម
- អនុរដ្ឋលេខាធិការមហាផ្ទៃ : អ៊ុច វ៉ែន
- អនុរដ្ឋលេខាធិការកសិកម្ម : ស្រ៊ុន សាមី

19 កុម្ភៈ : តាមការណែនាំរបស់ធានាគារជាតិ រដ្ឋាភិបាលខ្មែរបង្កើតផែនការគណនីយទូទៅ ( Plan Comptable General ) ។

20 កុម្ភៈ : ដាក់ទូតជាមួយប្រទេសថៃឡើងវិញ ដោយជំនួយរបស់សហរដ្ឋអាមេរិក បន្ទាប់ពីបានផ្តាច់ទូតចំនួនបីខែមក ។

22 កុម្ភៈ : ផែនការឃុបឃិត ក្បត់នឹងសម្តេច នរោត្តម សីហនុ ដោយ ដាប ឈួន ចៅហ្វាយខេត្តសៀមរាម បានត្រូវរកឃើញ ដាប ឈួន ត្រូវគេសម្លាប់បាន នៅថ្ងៃទី3 ខែមិនា ប្រទេសសៀម-យួនខាងត្បូង និងសហរដ្ឋអាមេរិក ត្រូវបានចោទប្រកាន់ថា បានចូលដៃនឹងផែនការនោះ ។

នៅខែកុម្ភៈនោះដែរ សៀវ ហេង ត្រូវបានរកឃើញថា ជាចារកិច្ចឱ្យក្រុមកុម្មុយនីស្ត PRPK ផង ឱ្យ សីហនុ ផង តាំងពីឆ្នាំ1955 មកម្ល៉េះ ។ សៀវ ហេង ដែលជាអគ្គលេខាបក្ស បានចុះចូលនឹងរដ្ឋាភិបាល តែពុំមានឃើញបង្ហាញសមាសភាពនៃចលនារបស់ខ្លួនទេ ពេលនោះឈ្មោះ នួន ជា ដែលជាក្មួយបង្កើត ក្នុងចលនាពុំត្រូវបញ្ចេញទេ។ គេដឹងថា ចាប់តាំងពីពេលនោះមក បណ្តាញក្រុមកុម្មុយនីស្តតាមស្រុកភូមិ ត្រូវបានជីកឫស ។

13 មិថុនា : ប្តូររដ្ឋាភិបាលទី14 របស់សង្គម ដឹកនាំដោយ នរោត្តម សីហនុ ។

**រដ្ឋាភិបាល នរោត្តម សីហនុ ( 13.6.1959 - 19.4.1960 )**

- នាយករដ្ឋមន្ត្រី : នរោត្តម សីហនុ
- ឧបនាយករដ្ឋមន្ត្រី- រដ្ឋមន្ត្រីការបរទេស : សឺន សាន
- ឧបនាយករដ្ឋមន្ត្រី-រដ្ឋមន្ត្រីអប់រំជាតិ-ផែន-ការ និងទេសចរណ៍ : ញឹក ជូឡុង
- ទេសរដ្ឋមន្ត្រីប្រតិភូអមទីស្តីការគណៈរដ្ឋមន្ត្រីទូលបន្ទុកមហាផ្ទៃ : ជា ជិនកុក
- ទេសរដ្ឋមន្ត្រីទទួលបន្ទុកការពារជាតិ : លន់ ណុល
- ទេសរដ្ឋមន្ត្រីទទួលបន្ទុកសន្តិសុខជាតិ និងការពារលើផ្ទៃប្រទេស : គូ រុន
- រដ្ឋមន្ត្រីសាធារណការ និងទូគមនាគមន៍ : ផ្លែក ឆាត
- រដ្ឋមន្ត្រីយុត្តិធម៌ និងបោសសំអាតទូទៅ : លឹម ត្រី
- រដ្ឋលេខាធិការកសិកម្ម : យឹម ឌិត
- រដ្ឋលេខាធិការសាធារណសុខាភិបាល : ហ៊ូ យន់
- រដ្ឋលេខាធិការមហាផ្ទៃទទួលបន្ទុកទំនាក់ទំនងជាមួយសភា : ស គីម កួយ
- រដ្ឋលេខាធិការធម្មការ និងពុទ្ធិកៈសិក្សា : សូ ណែម
- រដ្ឋលេខាធិការការងារ និងសង្គមកិច្ច : ហង់ ផាន់
- រដ្ឋលេខាធិការព័ត៌មាន : ឡុង បូរ៉េត
- អនុរដ្ឋលេខាធិការផែនការ ទទួលបន្ទុកផ្នែកផលិតកម្ម និងបរិក្ខារ : ឌី បែលឡុង
- អនុរដ្ឋលេខាធិការអប់រំជាតិ : ភី ធៀនឡាយ
- អនុរដ្ឋលេខាធិការហិរញ្ញវត្ថុ : ស៊ឹម ញ៉ុក
- អនុរដ្ឋលេខាធិការបោសសំអាតទូទៅ : ឡេង សារ៉ង ។

22 កក្កដា : សម្ពោធផ្លូវជាតិលេខ4 ពីភ្នំពេញទៅក្រុងព្រះសីហនុ ឈ្មោះថា " ផ្លូវអាមេរិកាំង " ដោយសារសងឡើងដោយសហរដ្ឋអាមេរិក ។

3 សីហា : នរោត្តម សីហនុ ទៅព្រៃនគរ ចរចាជាមួយប្រធានាធិបតី ង៉ោ ឌិនយៀម យួនទារយកកោះក្បែរឆ្នេរសមុទ្រពីខ្មែរ ។

31 សីហា : គ្រាប់បែក បានផ្ទុះក្នុងវាំងព្រះបាទសុរាម្រិត ព្រះមហេសី កុសុមៈ និង នរោត្តម សីហនុ បានគេចផុតពីការប៉ុនប៉ងធ្វើឃាតនេះ តែព្រះអង្គម្ចាស់ " មតិរីវ៉ាន់ " នាយកពិធីការក្នុងវាំង ត្រូវបានសុគតជាមួយបុគ្គលិកវាំងពីររូបទៀត ។ ការប៉ុនប៉ងនោះ គេចាត់ទុកថា ជាស្នាដៃរបស់ខ្មែរសេរី ឬ សម សារី ។

22 កញ្ញា : ខៀវ សំផន បានបង្កើតកាសែតជាភាសាបារាំងមួយ មានឈ្មោះ " អុបសែវ៉ាទ័រ " ( OBSERVATEUR ).

***នៅមានត***

---

នាទី ព្រះពុទ្ធសាសនា

# សមាធិវិបស្សនា

## ការរីកចំរើននៃព្រះធម៌

***តពីលេខមុន***



លោក ហ្គោអ៊ែនកា ថ្នាក់ដឹកនាំជាន់ខ្ពស់ នៃចលនាវិបស្សនា

**• ប្រទេសជប៉ុន :**

ការធ្វើអំណោយថាសលកុមប៉ាក់ CD-ROM ព្រះត្រៃបិដករបស់វិទ្យាស្ថានស្រាវជ្រាវវិបស្សនា បានប្រព្រឹត្តធ្វើឡើងនៅក្នុងឱកាសសន្និសីទព្រះពុទ្ធសាសនាអន្តរជាតិ នៅទីក្រុងតូក្យូ ។ អំណោយនេះ ជាការបង្ហាញពីសកម្មភាពនៃមជ្ឈមណ្ឌលវិបស្សនានៅប្រទេសចំពោះអ្នកប្រាជ្ញ ដែលចេះល្បីល្បាញខាងភាសាបាលី និងជួយពង្រឹងស្ថានភាពមជ្ឈមណ្ឌលជាទីកន្លែងចំរើនកម្មដ្ឋានយ៉ាងហ្មត់ចត់មួយដែលមានការបង្រៀនប្រតិបត្តិបច្ចេកទេសវិបស្សនាពិប្រាកដ ។

**• ប្រទេសចិន :**

ការខំប្រឹងរៀបចំធម្មសិក្សានៅពេលថ្មីៗនេះ បាននាំឱ្យមានលទ្ធផលល្អ គឺធម្មសិក្សា១០ថ្ងៃជាលើកដំបូង បានប្រព្រឹត្តទៅចប់សព្វគ្រប់នៅហុងកុង នៅចុងឆ្នាំ១៩៩៧ ។ គេបានយកសម្ភារៈថតបញ្ចូលសម្លេងជាភាសាចិនកង់តុង ដែលទើបនឹងបានធ្វើហើយនៅពេលថ្មីៗនេះ មកប្រើជាលើកដំបូងដែរ ។

**• ប្រទេសម៉ុងហ្គោលី :**

គេបានរៀបចំធ្វើធម្មសិក្សា១០ថ្ងៃ ចំនួនពីរដងជាលើកដំបូងដោយប្រើសម្ភារៈសំរាប់បង្រៀនជាពីរភាសា ដែលគេបានរៀបចំធ្វើជាពិសេស ។

**• ប្រទេសអៀរ៉ង់ :**

សិស្សមួយក្រុមចំនួន ៤៨នាក់ បានធ្វើដំណើរទៅធម្មគិរី ដើម្បីចូលរួមក្នុងធម្មសិក្សា១០ថ្ងៃ នៅចំពោះមុខលោក ហ្គោឥនកា ។ គេប្រើសម្ភារៈសំរាប់បង្រៀនជាភាសាហ្វារស៊ី ( Parsie ) ជាលើកដំបូង ។

**• ប្រទេសរុស្ស៊ី :**

គេកំពុងថតបញ្ចូលសម្លេងធ្វើសម្ភារៈសំរាប់បង្រៀន ដើម្បីប្រើប្រាស់ក្នុងធម្មសិក្សា១០ថ្ងៃជាភាសារុស្ស៊ី ហើយអ្នកទំនាក់ទំនងវិបស្សនាអន្តរជាតិម្នាក់ត្រូវបានតែងតាំងរួចហើយ សំរាប់ប្រទេសទាំងឡាយណា ដែលជាអតីតសហភាពសូវៀត ។

**• ប្រទេសអ៊ីស្រាអែល :**

ក្រោយពីការបញ្ចាំងខ្សែភាពយន្តវីដេអូមួយឈ្មោះថា "ទុកពេលជូនវិបស្សនា ( Doing time, Doing Vipassana )" តាមទូរទស្សន៍ជាតិអ៊ីស្រាអែលរួចមកមជ្ឈមណ្ឌលទូទៅមានការចាប់អារម្មណ៍លើវិបស្សនាច្រើនណាស់ ។ ក្នុងឆ្នាំ ១៩៩៧ គេបានរៀបចំធម្មសិក្សា១០ថ្ងៃ ចំនួន៥ដង ហើយមនុស្សរាប់រយនាក់ បានចុះឈ្មោះក្នុងបញ្ជីបំរុងក្នុងធម្មសិក្សាលើកក្រោយ ។

**• ប្រទេសបារាំង:**

នៅមជ្ឈមណ្ឌល"ធម្មមហិ(Dhamma Mahi)" គេបានសង់បន្ទប់តូចៗបានចំនួន១៨បន្ទប់រួចហើយ បន្ទប់តូចៗចំនួន១២ទៀតនឹងត្រូវសង់ហើយនៅអនាគតត្រកាលយ៉ាងខ្លី។ គេបានរៀបចំបន្ទប់ថតសម្លេងមួយរួចស្រេចហើយ សម្រាប់ថតបញ្ចូលសម្លេងក្នុងសម្ភារៈសម្រាប់បង្រៀនភាសាផ្សេងៗ។

សហគមន៍ខ្មែរនៅប្រទេសបារាំង បានទិញកម្មសិទ្ធមួយនៅខាងកើតទីក្រុងប៉ារីស។ គេបានរៀបចំឱ្យមានការចំរើនកម្មដ្ឋានរួមមួយទៀងទាត់នៅទីនោះ។ គេអាចមើលទំព័រអន្តរបណ្តាញ (In ternet Homepage) បានចូលតាមពាក្យគន្លឹះ : htt//www.dhamma.org ។

**• ប្រទេសអង់គ្លេស**

គេកំពុងធ្វើការអភិវឌ្ឍន៍គម្រោងការណ៍យូរអង្វែងមួយនៃមជ្ឈមណ្ឌល"ធម្មទីប(Dhamma Dipa)" គេបានចាប់ផ្តើមសង់សំណង់ខ្លះហើយ ។

**• ប្រទេសអ៊ីតាលី :**

គេបន្តការស្វែងរកយ៉ាងសកម្មនូវទីកន្លែងមួយដើម្បីធ្វើជាមជ្ឈមណ្ឌល ឬជាធម្មគ្រីហារ ។ ដំណឹងចុងក្រោយបានឱ្យដឹងថា គេបានរកឃើញកន្លែងមួយសំរាប់ធ្វើធម្មសិក្សាហើយ ។

**• ប្រទេសអូទ្រីស :**

គេបានរៀបចំធម្មសិក្សា១០ថ្ងៃមួយ ជាលើកដំបូងរួចហើយ ។

**• ប្រទេសកាណាដា :**

សិស្សទាំងឡាយនៅព្រីទីសកូឡុមប៊ីយ៉ា (British Columbia) បានទិញដីមួយកន្លែងសំរាប់ធ្វើមជ្ឈមណ្ឌលថ្មីនៅភាគខាងលិចនៅប្រទេសកាណាដា ហើយសព្វថ្ងៃនេះ គេកំពុងរៀបចំធ្វើសំណង់ផ្សេងៗទៀត ។

**• សហរដ្ឋអាមេរិក :**

គេកំពុងធ្វើកម្មវិធីមួយសំរាប់ចាប់ផ្តើមរៀបចំធម្មសិក្សាមួយនៅក្នុងពន្ធនាគារនៃប្រទេសអាមេរិកាំងខាងជើង ។ កាលពីខែវិច្ឆិកា ១៩៩៧ ធម្មសិក្សាដំបូងនៅក្នុងពន្ធនាគារបស្ចឹមប្រទេសត្រូវបានរៀបចំឡើងដោយជោគជ័យ នៅក្នុងគ្រឹះស្ថាននៃពន្ធនាគារ នៅរដ្ឋវ៉ាស៊ីងតោន សហរដ្ឋអាមេរិក ហើយធម្មសិក្សាស្ត្រីមួយទៀតក៏ត្រូវបានរៀបចំឡើងនៅកន្លែងដដែល កាលពីខែកុម្ភៈ ១៩៩៨ ។ គេកំពុងធ្វើគំរោងរៀបចំធម្មសិក្សាថ្មីទៀត ហើយគេកំពុងធ្វើខ្សែភាពយន្តមួយអំពីរឿងធម្មសិក្សាទាំងឡាយនេះ ។

**• ទ្វីបអាមេរិខាងត្បូង :**

ជាសរុបសិស្ស ៥០០នាក់បានចូលរួមក្នុងធម្មសិក្សា១៣ដង ក្នុង៦ប្រទេស ។ គំរោងការសំរាប់ឆ្នាំ១៩៩៨ មានការរៀបចំធម្មសិក្សានៅ១០ប្រទេស ។

**• ប្រទេសវេនេស៊ុយអេឡា (Vénézuéla) :**

គេបានរៀបចំធម្មសិក្សាជាលើកទីមួយសំរាប់កូនក្មេង នាទ្វីបអាមេរិកាំងខាងត្បូង នៅក្នុងប្រទេសនេះ ។

**• ប្រទេសប្រេស៊ីល (Brésil):**

គេបានធ្វើខ្សែ អាត់វិដេអូ " ធម្មគិរី (Hill of Dhamma)" ជាភាសាព័រទុយហ្គោស័រួចហើយ ។ សព្វថ្ងៃគេមានខ្សែអាត់វីដេអូនេះ សំរាប់ការផ្សាយ ។ គេបានបង្កើតវិបស្សនាតាមអន្តរបណ្តាញ (Internet) ជាភាសាអេស្ប៉ាញ៉ុល ដោយភ្ជាប់ជាមួយទំព័របណ្តាញ (Homepage) សំរាប់សិស្សចាស់ ។

**នៅមានត**

# ប្រាសាទជួបពល និងរឿងរ៉ាវ អច្ឆរិយ ពីអតីតកាល

**ខេត្តតាកែវ, ខ្មែរប៉ុស្តិ៍ : ចាន់ កុសល**

•••តាកែវ គឺជាខេត្តមួយដែលមានវ័យចំណាស់ក្នុងចំណោមខេត្ត-ក្រុងទាំង24 ដែលសំបូរទៅ ដោយធនធានធម្មជាតិ ប្រាង្គប្រាសាទបុរាណ បានបន្សល់ទុកតាំងពីសម័យនគរភ្នំចេន-ឡា និងមហានគរ ។

សម្បត្តិមរតកវប្បធម៌ទាំងនោះ ខ្លះនៅមានគុណភាពល្អ និងខ្លះទៀតត្រូវខូចខាតអស់មួយភាគធំទៅហើយ ដែលបង្កប់ទៅដោយអាថ៌-កំបាំង និងជំនឿចំពោះបារមីវត្ថុស័ក្តិសិទ្ធិជាទីចាប់អារម្មណ៍ពីសំណាក់អ្នកទេសចរជាតិ និងអន្តរជាតិថែមទៀតផង ។

ណាមួយមានគំនិតមិនល្អប្រាកដជាស្លាប់យ៉ាងវេទនានៅក្នុងរូងនោះមិនខានឡើយ ។

លោកព្រឹទ្ធាចារ្យបានបន្តទៀតថា ក្នុងសម័យប៉ុល ពត មានពួកទាហានមកបាញ់ពស់វែករនាមមួយគូនេះយកទៅទទួលទានមុននឹងពស់នេះងាប់វាបានប្រកាច់ពេញព្រះវិហារបណ្តាលឱ្យឈាមខ្ទាតប្រឡាក់ជញ្ជាំងស្ទើរសព្វកន្លែង ។ នៅពេលពស់នេះងាប់ពួកទាហានរាប់រយនាក់បាននាំគ្នាមកសែងយកទៅធ្វើម្ហូប ហើយបន្ទាប់ពីទទួលទានរួចអ្នកទាំងនោះ ក៏ស្លាប់យ៉ាងវេទនាបំផុត ចំណែកពស់ត្បាល់ ដែលរស់នៅទីនោះលែងមាននរណាហ៊ានមកបាញ់ទៀតឡើយ ហើយ



ប្រាសាទជួបពល ដែលមានបារមីអច្ឆរិយ

ចំណែកប្រាសាទជួបពល ដែលស្ថិតនៅក្នុងបរិវេណវត្តបារាយណ៍ ឃុំបារាយណ៍ ស្រុកដូនកែវ ចម្ងាយប្រមាណ3គីឡូម៉ែត្រពីទីរួមខេត្តតាកែវ បានរងនូវការបំផ្លិចបំផ្លាញស្ទើរអស់ប៉ុន្តែវាបានឆ្លុះបញ្ចាំងនូវរឿងរ៉ាវអច្ឆរិយពីអតីតកាល និងបារមីស័ក្តិសិទ្ធិរហូតដល់សព្វថ្ងៃ។

លោកព្រឹទ្ធាចារ្យ ហូរ អាយុ85ឆ្នាំ បានរៀបរាប់ឱ្យដឹងថា ប្រាសាទជួបពល បានកសាងក្នុងរជ្ជកាលព្រះបាទឥសានវរ្ម័នទី1 (គ.ស 616-635) នាសម័យចេនឡា ធ្វើពីឥដ្ឋ មានរាងការ៉េជ្រុងនីមួយៗ មានប្រវែង7ម៉ែត្រ កំពស់13ម៉ែត្រ តែផ្នែកខាងលើនៃប្រាសាទ ត្រូវរងនូវការបំផ្លិចបំផ្លាញអស់ហើយ ដែលសព្វថ្ងៃត្រូវបានព្រះសង្ឃកសាងសំណង់វត្តអារាមសំរាប់គោរពបូជាយ៉ាងច្រើន ហើយនៅជុំវិញបរិវេណប្រាសាទមានគូទឹកព័ទ្ធជុំវិញ មានអំណោយផលផ្នែកកសិកម្មយ៉ាងខ្លាំងសំរាប់ប្រជាកសិករ ។

លោកព្រឹទ្ធាចារ្យ ហូរ បន្តថា កាលពីសម័យមុនៗនៅបរិវេណប្រាសាទ និងព្រះវិហារមានសុទ្ធតែព្រៃដុះជុំជិត មិនសូវមាននរណាហ៊ានចេញ-ចូលក្រៅពីព្រះសង្ឃ និងអ្នកសច្ចំនោះ ទេ ពីព្រោះនៅក្រោមប្រាសាទមានរូងក្រោមដីជ្រៅ ហើយមានសត្វពស់វែករនាមមួយគូទំហំប៉ុនដើមត្នោត និងពស់ត្បាល់រាប់រយក្បាលរស់នៅក្នុងរូងនោះ ដែលមានពេលខ្លះសត្វពស់ទាំងនោះបាននាំគ្នាមកលេងនៅលើព្រះវិហារជារៀងរាល់ថ្ងៃ ប៉ុន្តែមិនដែលចឹកសំលាប់មនុស្សទេ ។ រូងដ៏ធំនៅក្រោមប្រាសាទនោះ មានតែអ្នករក្សាសីលបរិសុទ្ធទេ ទើបអាចឆ្លងកាត់បាន គឺគ្រាន់តែអុជទៀនបំភ្លឺ ។ ចំណែកសត្វពស់ទាំងនោះមិនចឹកមនុស្សរក្សាសីលទាំងនោះទេ ប៉ុន្តែបើអ្នកគេជឿថា ទីនោះពិតជាមានបារមីពូកែស័ក្តិសិទ្ធប្រាកដមែន ។

ព្រះតេជគុណ អ៊ូក សុវណ្ណឌី ព្រះចៅអធិការវត្តបារាយណ៍មានសង្ឃដីកាថា នៅឆ្នាំ1994 ព្រះសង្ឃគណៈកម្មការអាចារ្យវត្ត និងពុទ្ធបរិស័ទជិតឆ្ងាយបានមូលមតិគ្នារុះរើព្រះវិហារចាស់ចេញពីព្រោះវាមានសភាពទ្រុឌទ្រោមខ្លាំងពេក ដោយសង់ព្រះវិហារថ្មីនៅលើទីតាំងចាស់ដដែល ។

ចំណែកពស់ត្បាល់ ដែលវាធ្លាប់វាមកលេងក៏បាត់ស្រមោលលែងឃើញចាប់តាំងពីពេលនោះរហូតមក រីឯរូងនៅក្រោមប្រាសាទជួបពលក៏ត្រូវបានគេសន្ទប់ជិតទៀត ដោយរៀបចំសាងសង់រោងបារមីនៅទាំង4ទិសធំៗសំរាប់ធ្វើការបួងសួងសុំសេចក្តីសុខសប្បាយទៀតផង ។

ប្រាសាទបុរាណចំណាស់ ដែលស្ថិតនៅក្នុងបរិវេណវត្តបារាយណ៍សព្វថ្ងៃកំពុងទទួលបានការគាំទ្រពីសំណាក់ពុទ្ធបរិស័ទជិតឆ្ងាយនាំគ្នាគោរពបូជាតាមទំនៀមទំលាប់ព្រះពុទ្ធសាសនា និងធ្វើការបួងសួងចំពោះវត្ថុស័ក្តិសិទ្ធិនៅទីនោះជាហូរហែ ។ ចំណែកភ្ញៀវទេសចរមួយចំនួនក៏បានទៅទស្សនាប្រាសាទនោះ ដើម្បីស្វែងយល់ពីកេរដំណែលរបស់បុព្វបុរសខ្មែរ ដែលភ្ញៀវមួយចំនួនបានសំដែងនូវអារម្មណ៍សោកស្តាយចំពោះការខូចខាតនៃសំណង់ប្រាសាទនេះយ៉ាងខ្លាំង ។

កេរដំណែលចាស់ថ្មី នៅបរិវេណប្រាសាទនេះ ក៏បានធ្វើឱ្យមនុស្សម្នាពីគ្រប់មជ្ឈមដ្ឋាននាំគ្នាទៅកំសាន្តជាហូរហែរនៅថ្ងៃបុណ្យប្រពៃណីម្តងៗ ពីព្រោះវាមានធម្មជាតិស្រស់ត្រកាល និងបង្កប់ទៅដោយជំនឿចំពោះវត្ថុស័ក្តិសិទ្ធិយ៉ាងជ្រាលជ្រៅ ៕

# ផ្ទះនៅសម័យបារាំងក្លាយជា ភូមិវប្បធម៌ធម្មជាតិ

**បាត់ដំបង, ខ្មែរប៉ុស្តិ៍ : ម៉ី សម្ផស្ស**

•••ខ្មែរយើងជាជាតិសាសន៍មួយដែលមានភាពឧស្សាហ៍ព្យាយាមមានគំនិតច្នៃប្រឌិតខ្ពស់ផ្នែកសំណង់ស្ថាបត្យកម្ម ប្រាង្គប្រាសាទវត្តអារាម និងលំនៅឋាននានា តាំងពីសម័យ



បុរាណមកម្ល៉េះ ។

ចំណែកផ្ទះបុរាណមាន៦ប្រភេទ គឺផ្ទះខ្មែរបិត កន្តាំង រោងដោល រោងឡើង និងកឹង ហើយផ្ទះទាំងនេះកសាងឡើងតាំងពីសម័យបារាំងដែលមានសេសសល់នៅភូមិវត្តគរ ឃុំវត្តគរ ស្រុកបាត់ដំបង ខេត្តបាត់ដំបង ។

កេរដំណែលសម័យបារាំងទាំងនេះ ត្រូវបានអាជ្ញាធររៀបចំជាភូមិវប្បធម៌ធម្មជាតិសំរាប់ទាក់ទាញភ្ញៀវទេសចរទាំងក្នុង និងក្រៅប្រទេសឱ្យទៅទស្សនា និងសំរាកលំហែកាយជាហូរហែ ហើយធ្វើឱ្យអ្នកស្រុកមានជីវភាពធូរធារមួយកំរិតថែមទៀតផង ។

*** ប្រភពនៃផ្ទះបុរាណខ្មែរ :**

បើតាមឯកសាររបស់លោកបណ្ឌិត មីសែលត្រាណេ អ្នកជំនាញវប្បធម៌ខ្មែរបានបញ្ជាក់ថាផ្ទះខ្មែរមានកំណើតរាប់ពាន់ឆ្នាំមកហើយច្រើនសង់ពីឈើប្រក់ស្លឹកខ្ពស់ផុតពីដីបែរមុខទៅទិសខាងកើត និងមានជង្រុកស្រូវជាប់ពីខាងក្រោយដើម្បីការពារទឹកជំនន់ សត្វសាហាវ និងចោរ-កម្ម ។

ក្នុងឯកសារបានបញ្ជាក់ថា ផ្ទះរោងឡើងជាគំរូមេដំបូងគេ ដែលជនជាតិខ្មែរ និងជនជាតិ

(តទៅទំព័រទី២០)



## បណ្ណបញ្ជាកាសែតខ្មែរប៉ុស្តិ៍

ខ្ញុំចង់ឱ្យ " ខ្មែរប៉ុស្តិ៍ " ផ្ញើរកាសែតជាភាសាខ្មែរ ដែលសំបូរដោយព័ត៌មានក្នុងសហគមន៍ខ្មែរនៅបរទេស មកឱ្យខ្ញុំជាប្រចាំ រៀងរាល់ពេល ដែលកាសែតនេះចេញផ្សាយ មួយខែពីរដង ។

ឈ្មោះ និងអាស័យដ្ឋានរបស់ខ្ញុំ :

ឈ្មោះ :........................................................

អាស័យដ្ឋាន :..................................................

..........................................................U.S.A.

ទូរស័ព្ទ :......................................................

អ៊ីមែល :.......................................................

ខ្ញុំផ្ញើរភ្ជាប់ជាមួយនូវ សែក ឬ មានីអដ័រ មក U.A.M.G ចំនួនមួយខែតម្លៃ ៥ ដុល្លារ ×........(ចំនួនមួយខែ) =..................

U.A.M.G 5730Rising Sun Avenue Philadelphia,PA 19120

**Phone : (215) 722-2226**

## (តមកពីទំព័រទី០១) ពុះផ្ទះចែកគ្នាព្រោះអស់ជំនឿនឹង...

វាជារឿងមួយទឹកស្នាទមិនដល់សោះសំរាប់គ្រួសារកសិករ ដែលរស់នៅតាមស្រុកស្រែចំការ គ្រាន់តែមានទំនាស់ផ្លូវចិត្តនឹងគ្នាបានសំរេចចិត្តដ៏ឃោឃៅ ដោយពុះផ្ទះជាពីរចែកគ្នា ។

ការសំរេចចិត្តបែបនេះ វាមិនត្រឹមឱ្យពួកគេខាតបង់នូវទ្រព្យសម្បត្តិកិត្តិយសប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបង្ហាញពីគំរូអាក្រក់ជូរជាតិ ដែលមនុស្សម្នាពុំធ្លាប់ជួបទាល់តែសោះ ។

ប្តី-ប្រពន្ធ ដែលមានទំនាស់នេះ រស់នៅភូមិជាច ឃុំជាច ស្រុកកំចាយមារ បានសំរេចចិត្តពុះផ្ទះចែកគ្នាកាលពីថ្ងៃទី18 កញ្ញា ដែលធ្វើឱ្យអ្នកភូមិ មានការផ្អើលឆោឡោយ៉ាងខ្លាំង ។

បុរសជាប្តីឈ្មោះ មឿន រីម រីឯប្រពន្ធឈ្មោះ ញាញ់ អាយុប្រហែលជា 40ឆ្នាំ មានកូនពីរនាក់ ។ ប្តី-ប្រពន្ធទាំងពីរនាក់នេះ មានទំនាស់ជាមួយគ្នាយូរហើយ គឺប្តីមានជំងឺប្រចាំកាយ ហើយប្រពន្ធ មិនសូវអើពើ ។ ខ្លះទៀតថា ទំនាស់នេះ ផ្តើមចេញពីបុរសជាប្តី ដែលមានការប្រចណ្ឌហួសហេតុធ្វើឱ្យប្រពន្ធអត់ទ្រាំលែងបាន ។

ចំណែកលោក វង់ ម៉ន មេឃុំជាច បានឱ្យដឹងថា គ្រួសារទាំងពីរនេះ បានប្តឹងលោកឱ្យដោះស្រាយដែរ ហើយលោកបានជំរុញឱ្យពួកគេឡើងតុលាការតាមផ្លូវច្បាប់ ប៉ុន្តែពួកគេឯកភាពសំរេចពុះចែកផ្ទះជាពីរ ។

លោក វង់ ម៉ន បានបញ្ជាក់ថា ក្នុងនាមលោកជាអាជ្ញាធរពុំមានសិទ្ធិហាមឃាត នោះទេ ហើយលោកក៏ពុំដឹងមូលហេតុ នៃទំនាស់ពិតប្រាកដនោះដែរ ៕

ចំណែកលោក អ៊ុក វ៉ាន់ដេត មេធាវីការពារសិទ្ធិមនុស្សបានមានប្រសាសន៍ថា ការលែងលះ គ្នាប្តី-ប្រពន្ធ ត្រូវតែឡើងដល់តុលាការ ទើបស្របតាមផ្លូវច្បាប់ ហើយមិនមានបញ្ហាទៅថ្ងៃក្រោយ ។ ចំពោះទ្រព្យសម្បត្តិ ដែលភាគីទាំងសងខាងរកបាន ពួកគេមានសិទ្ធិចែកគ្នាដោយពុំចាំបាច់ឆ្លង តុលាការឡើយ ។

ការផ្តាច់ចំណងមេត្រីភាពរវាងប្តី-ប្រពន្ធ ដោយពុះចែកផ្ទះជាពីរបែបនេះ វាជាគំរូមួយអាក្រក់ខ្លាំងណាស់ សំរាប់សង្គមខ្មែរ ។ ដូច្នេះអាជ្ញាធរ គួរតែមានវិធានការទប់ស្កាត់ចៀសវាងរឿងរ៉ាវបែបនេះ កើតឡើងបន្តទៀត ដែលជះឥទ្ធិពលអាក្រក់ដល់មនុស្សជំនាន់ ក្រោយ ៕

## (តមកពីទំព័រទី០១) ថ្ងៃទី4 ខែវិច្ឆិកា ឆ្នាំ2008...

នៅមានប្រៀបលើលោក ចន ម៉ាកេន ចំនួន 43% ទល់នឹង 52% (27/10/ 2008) ក៏ប៉ុន្តែ លោក ចន ម៉ាកេន នៅតែនិយាយថា " លោក នឹងឈ្នះឆ្នោត " ពីព្រោះពិន្ទុនេះនៅកៀកគ្នាខ្លាំងណាស់នៅឡើយ ។

ប្រជាពលរដ្ឋខ្មែរ នៅ ហ្វីឡាដែលហ្វីយ៉ា ហាក់ដូចជាស្វាហាបក្នុងការគាំទ្រគណបក្សប្រជាធិបតេយ្យ រីឯអ្នកចូលចិត្តគណបក្សសាធារណរដ្ឋពុំសូវឃើញបង្ហាញខ្លួនគាំទ្រគណបក្ស ដែលខ្លួនស្រឡាញ់នោះទេ ។

នៅថ្ងៃទី4 តុលា ខាងមុខនេះ ចាប់ពីម៉ោង 8 យប់នោះទៅ គេអាចដឹងថា ប្រធានាធិបតីថ្មីរបស់សហរដ្ឋអាមេរិកហើយ ។ បន្ទាប់ពី រ៉ូណាល់ រ៉េហ្គាន់ - ពី ជច ប៊ុស - ពី គ្លីនតុន និង ជច ប៊ុស ជាកូន តើនរណានឹងក្លាយជាប្រធានាធិបតីថ្មី ៕





# One-Million-Thumb-Prints Campaign

# INVITATION

**PLEASE JOIN TOGETHER AND BRING YOUR FRIENDS**

**The Commemorating of 17th Anniversary of Paris Peace Agreement**

**23 October 1991 – 23 October 2008**

**Presided By: Mr. SOURN SEREY RATHA, Chief Mission of CACJE**

**To dedicate to millions of Khmers Solder who made the ultimate sacrifice for the defense of Cambodia's sovereignty, territorial integrity, freedom and democracy.**






**Date: Sunday November 2nd 2008 From: 9:00am to 12:30pm**

**State of California: Cambodian Old Temple (វត្តចាស់ក្រុងស្តុកតុន)**

**3732 East Carpenter Road, Stockton CA. 95215.**

**Contact: (209) 762 7686, (916) 529 3887**

**Date: Saturday November 8th 2008, From: 9:00am to 12:30pm**

**State of Minnesota: Munisotaram Temple (វត្តមុនីសោតារាម)**

**2925 220th Street East, Hampton, MN 5503.**

**Contact: (651) 463 3101, (952) 288 9231, (651) 239 5556**

**រៀបចំដោយៈ**

**គណៈកម្មាធិការប្រព្រឹត្តិកម្មខ្មែរ ដើម្បីយុត្តិធម៌ និងសមធម៌ (CACJE)**

**និង សម្ព័ន្ធដើម្បី កម្ពុជាសេរី (AFC) ប្រចាំសហរដ្ឋអាមេរិក ក្រុងរដ្ឋ CA & MN**

# អ្នកភូមិតិរច្ឆានរំលឹកពីរឿងរ៉េស៊ីដង់បាដេស

**កំពង់ឆ្នាំង, ខ្មែរប៉ុស្តិ៍ : គីម សារឿន**

•••គ្រោះធម្មជាតិបានគំរាមកំហែង ចំពោះជីវភាពរស់នៅរបស់ពលរដ្ឋខ្មែរយ៉ាងធ្ងន់ធ្ងរ ធ្វើឱ្យពួកគាត់មានការអស់សង្ឃឹមនឹងជីវិត ហើយគ្រួសារខ្លះ បានលះបង់មនោសញ្ចេតនា ប្តី-ប្រពន្ធ រហូតដល់ឈឺមិនហ៊ានដកលុយមកព្យា-បាលជំងឺ ។


ចេតិយ រ៉េស៊ីដង់បាដេស


ខ្លោងទ្វារវត្តបល្ល័ង្ករង្សី ហៅវត្តក្រាំងលាវ

ម្យ៉ាងទៀត ពួកបារាំងបានធ្វើការគំរាមកំហែងបំបិទសិទ្ធិសេរីភាព ចាប់ដាក់ខ្នោះធ្វើទារុណកម្មបង្ខំឱ្យបង់ពន្ធមិនមានការយោគយល់ឡើយ ។ សកម្មភាពឃោរឃៅរបស់រ៉េស៊ីដង់-បាដេស បានជំរុញឱ្យអ្នកភូមិក្រាំងលាវ និងអ្នកក្លាហានឯទៀត រៀបចំជាគំរោងការណ៍សំលាប់បាដេស នៅថ្ងៃទី18 មេសា 1925 ប៉ុន្តែក្រោយមកភូមិនេះ ត្រូវប្តូរមកជាភូមិតិរច្ឆានបង្ខំឱ្យសង់ចេតិយធ្វើបុណ្យ សុំខមាទោសបាដេស និងមិនឱ្យមានសិទ្ធិសេរីភាពធ្វើអ្វីឡើយ ។

ព្រឹត្តិការណ៍ជាប្រវត្តិសាស្ត្រ នៅភូមិក្រាំងលាវ ឃុំក្រាំងលាវ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង រហូតមកដល់ពេលនេះ មានរយៈពេល 83ឆ្នាំហើយ ដែលកូនខ្មែរទូទាំងប្រទេសមានការចងចាំមិនភ្លេចឡើយ ។ ការប្រឆាំងចំពោះបាដេសនេះ វាផ្តើមចេញពីការកេណ្ឌឱ្យធ្វើទាហានការដំឡើងពន្ធសព្វសារពើគ្រោះទុរភិក្ស គ្រប់ទិសទី និងបារាំងប្រើអំណាចធ្ងន់ធ្ងរពេកមកលើរាស្ត្រខ្មែរដូចសត្វធាតុ ។

ក្រោមគំនិតផ្តួចផ្តើមរបស់ជួន និងនៅបានបំផុសដល់មិត្តភក្តិរួមអាវុធ និងអ្នកភូមិក្រាំងលាវឱ្យប្រឆាំងនឹងរ៉េស៊ីដង់បាដេស ប្រចាំខេត្តកំពង់ឆ្នាំង ហើយអ្នកទាំងពីរដឹងថា រឿងនេះមានស្លាប់ មានរស់ ហើយត្រូវតាំងចិត្តថា "អញសំលាប់បារាំង បារាំងនឹងសំលាប់អញវិញ " ។ បើបងប្អូននៅណាអាឡោះអាល័យបងប្អូនប្រពន្ធ-កូនសុំកុំចូលរួមឱ្យសោះ ប៉ុន្តែអ្នកក្រាំងលាវទាំងនោះមិនរាថយទេ ។

បន្ទាប់ពីរៀបចំគំរោងការណ៍រួចហើយ ក៏មានការឈ្លោះប្រកែកគ្នារវាងនាង នី និង នាងប៊ី ជាមួយបាដេស ហើយបាដេស ចីសួន និងឡាច ត្រូវបានក្រុម បាតុករសំលាប់ដូចបំណង នៅសាលាឃុំក្រាំងលាវ ថ្ងៃទី18 ខែ មេសា ឆ្នាំ1925 ។

ប៉ុន្តែជ័យជំនះ ដែលទទួលបានមួយដង្ហើមចង្រិតនេះ ត្រូវអាជ្ញាធរខ្មែរក្រោមអំណាចបារាំងបង្ក្រាបឱ្យបែកបាក់ខ្មែរអស់ដោយមេដឹកនាំខ្លះត្រូវចាប់ដាក់គុក ខ្លះទៀតត្រូវយកទៅធ្វើទារុណកម្មនៅកោះត្រឡាច ចំណែកប្រជាជនរត់ចោលផ្ទះសំបែងភូមិស្រុក ។

លើសពីនេះទៀត ភូមិក្រាំងលាវបានប្តូរឈ្មោះជា " ភូមិតិរច្ឆាន " ដែលមានន័យថា " ភូមិសត្វ " ធ្វើចេតិយជានិមិត្តរូបសុំទោសបាដេស, ធ្វើបុណ្យអធិកអធម និងតំរូវមិនឱ្យមានសិទ្ធិក្នុងការផ្លាស់ប្តូរលំនៅឋានទៅរស់នៅទីកន្លែងផ្សេងនោះទេ ។

ទាក់ទិននឹងការផ្ទុះកំហឹងរបស់ប្រជាជននៅភូមិក្រាំងលាវ ចំពោះរ៉េស៊ីដង់បាដេសនោះ លោក សំ យ៉ុ អ្នកស្រាវជ្រាវព្រឹត្តការណ៍ ថ្ងៃទី18 មេសា 1925 បានឱ្យដឹងថា កាលសម័យនោះ សាលាឃុំក្រាំងលាវស្ថិតនៅក្នុងបរិវេណវត្តបល្ល័ង្ករង្សី ដែលមេឃុំតែងកេណ្ឌអ្នកស្រុកមកជួបជុំគ្នានៅទីនោះ ដើម្បីបង់ពន្ធឱ្យបារាំង ហើយមុនពេលដែលមានព្រឹត្តការណ៍នោះ បាដេស មកពីទារពន្ធឃុំព្រៃ ក៏ចូលឃុំក្រាំងលាវបន្តទៀត ។

លោក សំ យ៉ុ សព្វថ្ងៃរស់នៅឃុំក្រាំងលាវ បានបន្តថា នៅពេលនោះ បាដេស បានចាប់មនុស្ស 8គ្រួសារដាក់ខ្នោះ ពីព្រោះពួកគេគ្មានលុយបង់ពន្ធ ដោយមានមនុស្សជាច្រើនមកពពាក់ពពូន ដើម្បីរង់ចាំស្តាប់ពីហេតុការណ៍ និងក្រុមអ្នកក្លាហានផងដែរ ។ ខណៈនោះ នាង ប៊ី ដែលមានប្តីជាប់ខ្នោះសុំយកបាយឱ្យប្តីទទួលទានក៏ទាស់សំដីជាមួយអ្នកបកប្រែត្រូវបារាំងបញ្ជាឱ្យបាញ់ ហើយនាង ប៊ី ក៏រត់គេចចេញ ចំណែកក្រុមអ្នកក្លាហានដឹកនាំដោយ ជួន និងនៅ ក៏សំរុកចូលទៅចាប់ឡាចអ្នកកាន់កាំភ្លើង ចីសួន និងវាយដំ បាដេស រហូតដល់ស្លាប់ ។

លោក សំ យ៉ុ បានបន្តថា បក្សពួកបាដេស ត្រូវអ្នកស្រុកចោមរោមវាយដំទាំងកំហឹង និងកាប់ស្ទើរសុះសាច់ គឺក្នុងហេតុការណ៍នោះ អ្នករត់រួចមានតែអ្នកដាំបាយបារាំងម្នាក់ប៉ុណ្ណោះ ។ ការរួចខ្លួនអ្នកដាំបាយនេះ បានទៅរាយការណ៍ឱ្យថ្នាក់លើមកចាត់វិធានការណ៍ចំពោះក្រុមបាតុករ ដែលដឹកនាំដោយ ជួន និង នៅព្រម ទាំងក្រុមអ្នកស្រុកនៅចំណុចត្រពាំងស្រែវ៉ា ចំងាយប្រមាណ5គីឡូម៉ែត្រពីកន្លែងកើតហេតុ។

អ្នកចេះចាំរឿងរ៉ាវប្រវត្តិសាស្ត្ររូបនេះបានបន្តថា ក្រោយពីអាជ្ញាធរបំបែកក្រុមបាតុករ ហើយព្រះរាជប្រកាសរបស់ទ្រង់ស៊ីសុវត្ថិ បានតំរូវឱ្យប្តូរឈ្មោះភូមិក្រាំងលាវ ជាភូមិតិរច្ឆានវិញ ឱ្យកសាងចេតិយ និងរកលុយធ្វើបុណ្យ ដែលមានលោក100អង្គយ៉ាងអធិកអធម ។ ព្រះរាជប្រកាសនេះ ជាបន្ទុកមួយដ៏ធ្ងន់ធ្ងរសំរាប់ប្រជា-ពលរដ្ឋក្រីក្រ ហើយត្រូវរកលុយមកសាងសង់ចេតិយធ្វើបុណ្យបន្ថែមទៀត ។

កាលនោះ អ្នកស្រុកដោយខ្លាចបារាំងខ្លាំងពេក ក៏រត់ចោលផ្ទះសំបែងស្ងាត់ភូមិ ខ្លះត្រូវគេចាប់ដាក់គុកនៅខេត្ត និងអ្នកខ្លះទៀតដាក់គុកនៅកោះត្រឡាច ។

លោក សំ យ៉ុ បានបន្តថា ការឈឺចាប់របស់អ្នកស្រុកយើងធ្ងន់ធ្ងរណាស់ ប៉ុន្តែយើងដូរបានមកវិញនូវតំលៃសេរីភាពយ៉ាងត្រចះត្រចង់ និងបង្ហាញពីគំរូវីរភាពដ៏អង់អាចក្លាហានសំរាប់កូនខ្មែរជំនាន់ក្រោយ ។ ចេតិយនេះ វាបានក្លាយជាពន្លកនៃការតស៊ូ ដើម្បីប្រជាធិបតេយ្យជាប្រវត្តិសាស្ត្ររបស់អ្នកក្រាំងលាវផងដែរ ។

លោក សំ យ៉ុ ក៏បានបន្តថា សព្វថ្ងៃនេះ កូនចៅអ្នកក្រាំងលាវមួយចំនួនក៏បានភ្លេចអស់នូវរឿងរ៉ាវប្រវត្តិសាស្ត្រនេះហើយ ប៉ុន្តែគេក៏មានមោទនភាពសំរាប់ខ្លួនឯងដែរ ត្រូវបានគេចារក្នុងទំព័រប្រវត្តិសាស្ត្រមនុស្សជាតិ ដើម្បីសេរីភាព និងមានអ្នកទេសចរជាតិអន្តរជាតិមួយចំនួនបានមកទស្សនាជាហូរហែ ។

ជាមួយគ្នានេះដែរ ព្រះតេជគុណ ចាប សឿន គង់នៅវត្តបល្ល័ង្ករង្សី ហៅវត្តក្រាំងលាវ បានមានសង្ឃដីកាថា ចេតិយរបស់ បាដេស នេះ សង់តាំងពីអាត្មាមិនទាន់កើតម្លេះ ហើយអាត្មាបានដឹងរឿងរ៉ាវតាមរយៈចាស់ទុំ ដែលចូលរួមបាតុ-កម្ម និងការសិក្សារៀនសូត្រនៅសាលា ។ សព្វថ្ងៃនេះ អាត្មាសង្កេតឃើញមានក្រុមនិស្សិត និងអ្នកទេសចរមកថតរូប និងសួរនាំពីប្រវត្តិរបស់ បាដេស ។ ក្នុងចេតិយមិនមានតំកល់សពទេ គឺគេធ្វើជានិមិត្តរូប និងសរសេរឈ្មោះអ្នកចូលរួមបាតុកម្មប៉ុណ្ណោះ ។

ព្រះតេជគុណ ចាប សឿន បន្តថា អាត្មាបានទទួលដំណឹងថា អាជ្ញាធរគ្រោងនឹងរៀបចំជួសជុលចាក់ដីក្បែរចេតិយឱ្យធំទូលាយ និងឱ្យក្លាយជាតំបន់ទេសចរណ៍ប្រវត្តិសាស្ត្រទៀតផង ។


លោក សំ យ៉ុ អ្នកស្រាវជ្រាវព្រឹត្តការណ៍ភូមិក្រាំងលាវ

មន្ត្រីមន្ទីរទេសចរណ៍ខេត្ត កំពង់ឆ្នាំង ក៏បានអះអាងថា ចេតិយ បាដេស ជាទីតាំងប្រវត្តិសា-ស្ត្រដ៏ សំខាន់មួយរបស់ខេត្តដែលភ្ញៀវទេសចរជិតឆ្ងាយប្រាថ្នាចង់ឃើញចង់ស្គាល់នឹងភ្នែកឮនឹងត្រចៀក ។ ជាពិសេសចង់ឃើញអ្នកចូលរួមធ្វើបាតុកម្ម និងក្រុមគ្រួសាររបស់គេ ប្រឆាំងនឹង បាដេស ដើម្បីទាមទារនូវសិទ្ធិសេរីភាពក្នុងនាមជាម្ចាស់ប្រទេសម្ចាស់អំណាច ៕




# អតីតអ្នកទោសខ្មែរក្រហម នៅសល់តែសំបកខ្លួន

**កំពង់ឆ្នាំង, ខ្មែរប៉ុស្តិ៍ : គឹម សារឿន**

•••ក្នុងរបបប៉ុល ពត ពួកវាបានកំទេចរាល់ហេដ្ឋារចនាសម្ព័ន្ធរបស់ជាតិឱ្យធ្លាក់ដល់កំរិតក្រោមសូន្យ ហើយជម្លៀសប្រជាជនពីទីក្រុង



ស្ត្រីឈ្មោះ ឆាយ យោន កំពុងផ្តល់បទសម្ភាសន៍

ទៅជនបទបង្ខំឱ្យធ្វើការងារធ្ងន់ហួបចុកតិចតួចស្ថិតនៅក្រោមការតាមដានរបស់អង្គការមហាអស្ចារ្យមហាលោតផ្លោះ ។

ពួកអាវខ្មៅបានចាប់ផ្សឹកព្រះសង្ឃ លែងឱ្យមានសាសនា និងចោទព្រះសង្ឃថា ជាព្រូនសង្គម ជាមនុស្សខ្ជិលច្រអូស ចាំជញ្ជក់ឈាមប្រជាពលរដ្ឋ ។ ជាពិសេសនោះ ពួកអង្គការខ្មែរក្រហម បានប្រែក្លាយទីវត្តអារាមឱ្យទៅជាកន្លែងធ្វើទារុណកម្មសួរចំលើយអ្នទោស និងកាប់សំលាប់រង្គាលមនុស្សខ្លាំងណាស់ ។

អ្នកទោសដែលពួកវាចាប់យកទៅធ្វើទារុណកម្មទាំងនោះ ភាគច្រើនជាមន្ត្រីរាជការ គ្រូបង្រៀន ទាហាន ប៉ូលិស ខ្លះត្រូវគេចោទថាមានបងប្អូនប្តីសីធ្វើការពីជំនាន់មុននាំមកសួរចំលើយរួច ទើបសំលាប់ចោលដូចសត្វធាតុ ។

អ្នកទោសដែលពួកខ្មែរក្រហមចាប់យកទៅធ្វើទារុណកម្ម ភាគច្រើនជាមនុស្សដែលជម្លៀសមកពីខេត្ត-ក្រុងផ្សេងៗទូទាំងប្រទេសដែលមានទាំងចាស់ក្មេង-ស្រីប្រុសលាយឡំគ្នា ហើយក្នុងចំណោមនោះក៏មានអ្នករស់នៅតាមមូលដ្ឋានផងដែរ ។

លោកយាយ ឆាយ យោន អាយុ71ឆ្នាំ អតីតអ្នកទោសនៅវត្តសម្តេចមុនី សព្វថ្ងៃរស់នៅភូមិត្រពាំងពោធិ៍ ឃុំខុនរ៉ង ស្រុកបរិបូរណ៌ ខេត្តកំពង់ឆ្នាំ បានរៀបរាប់ទាំងការឈឺចាប់ថា បន្ទាប់ពីថ្ងៃរំដោះ 17 មេសា 1975 គ្រួសាររបស់គាត់ដែលត្រូវអង្គការបង្ខំឱ្យចាកចេញពីភ្នំពេញ ក៏នាំគ្នាមករស់នៅស្រុកកំណើត គឺជិតមន្ទីរឃុំឃាំងខាងលើ ។

លោកយាយ ឆាយ យោន ដែលសព្វថ្ងៃមានជំងឺប្រចាំកាយ និងនិយាយភ្លេចភ្លាំងខ្លះផងនោះ បានបន្តថា ពេលមករស់នៅស្រុកកំណើតមិនទាន់បានប៉ុន្មានថ្ងៃផង ពួកវាក៏មានការសង្ស័យថា ប្តីរបស់គាត់ធ្វើទាហានសម័យលន់ នល់ ក៏ចាប់យកទៅដាក់គុក រួចយកទៅសំលាប់ចោលបាត់គ្មានដំណឹង ។ ក្រោយមកទៀត ពួកវាចាប់យកកូនប្រុសគាត់២នាក់យកទៅធ្វើទារុណកម្ម រហូតដល់ថ្ងៃមួយពួកវាចាប់គាត់មកធ្វើទារុណកម្មដាក់ខ្នោះជើងទាំងយប់ទាំងថ្ងៃ ។

ស្ត្រីអ្នកទោសរូបនោះ បានបន្តថា ក្នុងគុកនោះ គឺពួកវាចាប់អ្នកទោសពីតំបន់ផ្សេងៗ រាប់រយនាក់មកដាក់ខ្នោះជើង 6ជួរទល់មុខគ្នា និងយកកុដិវត្តសម្តេចមុនី ជាកន្លែងវាយធ្វើទារុណ-



យាយ ឆាយ យោន រស់នៅក្នុងខ្ទមកំសត់

កម្មគ្រប់រូបភាព ។ សំរាប់រូបគាត់ ក្នុងមួយថ្ងៃត្រូវគេវាយ ៣ដងនឹងដំបងឫស្សីរហូតដល់សន្លប់ ទើបគេអូសយកទៅដាក់ខ្នោះនៅកន្លែងដើមវិញ ដោយគ្រាន់តែសួរថា ប្តីអ្នកធ្វើទាហានឬ ? ប៉ុន្តែសំរាប់ការមិនព្រមឆ្លើយត្រូវវាវាយរាល់ថ្ងៃ ។

អតីតអ្នកទោសរូបនេះ បានបញ្ជាក់ថា ក្រោយពីយើងងើបពីសន្លប់ វាយកទៅឆក់ខ្សែភ្លើងធ្វើឱ្យឈឺចុកចាប់ខ្លាំងណាស់ គឺជារៀងរាល់ថ្ងៃត្រូវឈាមហូរចេញពីក្នុងខ្លួន មិនដែលខកខាននោះទេ ។

ចំពោះអ្នកទោសដែលពាក់អាវខ្មៅនាំមកសុទ្ធតែប្លែកៗមុខ មានក្មេង ចាស់ ប្រុស ស្រី ហើយប្រុសៗត្រូវវាធ្វើទារុណកម្មខ្លាំង សួរចំលើយ ហើយទើបនាំយកទៅសំលាប់ហើយនាំអ្នកថ្មីចូលមក ។

អ្នកទោសខ្លះត្រូវគេចាក់ នឹងកាំបិតត្រង់ក្បាលពោះ នៅពេលព្រឹកល្ងាច និងយប់ហើយ អ្នកខ្លះត្រូវគេយកទៅកប់ទាំងរស់ដោយគ្រាន់តែជីកដីកប់ និងដំថ្មសង្កត់ពីលើយ៉ាងអណោចអធម ។

លោកយាយ យោន បន្តថា មិនថាយប់ ឬថ្ងៃនោះទេ ឮតែសំលេងស្រែកយំថ្ងូចថ្ងូរពីការឈឺចាប់របស់អ្នកទោស ហើយពួកគេដែលចូលមកទីនេះហើយ គឺគ្មានសំណាងនឹងវិលត្រឡប់ចេញទៅវិញបាននោះទេ ។

ប៉ុន្តែសំរាប់រូបគាត់ចាត់ទុកថាជាសំណាងមួយ ហើយនៅថ្ងៃនោះ វាយគាត់រួចយកខ្សែចងផ្តោបនឹងដើមដូងឱ្យសន្លប់បំរុងយកទៅកប់ស្រាប់តែពួកទាហានយួនមកដល់សល់តែគាត់2នាក់ប៉ុណ្ណោះដែលមានជីវិតរស់នៅ ។

លោកយាយ យោន បានបន្តថា ចំពោះការហូបចុកដេកនៅមិនខុសប្លែកពីសត្វធាតុទេ គឺវាឱ្យយើងទទួលទានដើមចេកបុកជាមួយអំបិលគ្មានជាតិ ជៅស្អីទេ ហើយអ្នកទោសវាដាក់ឱ្យហូបនឹងត្រឡោកដូង គឺវាអន់ជាងសត្វទៅទៀត ចំណែកការដេកលាយឡំទៅដោយក្លិនស្អុយអាចមិ ឈាមក្រាលលើ ឥដ្ឋគួរឱ្យខ្លាច មិនខុសពីឋាននរគនោះទេ ។

អតីតអ្នកទោសរូបនេះ បានបញ្ជាក់ទាំងទឹកភ្នែកថា នៅពេលដែលគាត់រួចពីក្រញាំដៃពួកបិសាចហើយ ក៏ស្វះស្វែងរកកូនទាំង៨នាក់ ប៉ុន្តែត្រូវគេប្រាប់ថា ពួក ប៉ុល ពត សំលាប់ចោលសល់ ។ ចាប់តាំងពីពេលនោះមកគាត់គ្មានអ្វី ទេក្រៅពីសំបកខ្លួន ដែលមានជំងឺប្រចាំកាយសតិបញ្ញានៃការចងចាំ ក៏បាត់អស់ ហើយរស់នៅក្បែរផ្ទះកូនក្មួយជួយឧបត្ថមបាយសំលនៅពេលខ្លះគេជួយរៃអង្គាសអ្នកភូមិ ដើម្បីទិញថ្នាំមកព្យាបាលពេលឈឺម្តងៗ ។ បើនិយាយាឱ្យខ្លីទៅ គឺរស់ដោយសារកូនក្មួយ និងអ្នកស្រុកចិញ្ចឹមប៉ុណ្ណោះ ហើយផ្ទះសំបែងខ្ទមស្លឹកនោះ ពេលភ្លៀងខ្យល់មកម្តងៗលិចទឹកទទឹកជោគរកកន្លែងជ្រកមិនឃើញផង ។



លោក ស៊ុន ខាន អតីតមេគុម្ពិខុនរ៉ង



លោក ប៊ុន សុខ គណៈកម្មាធិការវត្តសម្តេចមុនី

អតីតកន្លែងប្រមូលផ្តុំអ្នកទោសគ្មានកំហុសទៅសួរចំលើយនោះ ត្រូវបានអ្នកស្រុករៀបរាប់យ៉ាងរន្ធត់នូវសំរែកនៃការឈឺចាប់ ការវាយដំ កាប់សំលាប់ និងភស្តុតាងដែលពួកអាវខ្មៅបានបន្សល់ទុកគួរឱ្យឈឺចាប់ខ្លោចផ្សារខ្លាំងណាស់ ។

លោក ប៊ុន សុង អាចារ្យវត្តសម្តេចមុនី បានឱ្យដឹងថា កាលសម័យនោះ ក្នុងព្រះវិហារត្រូវពួក ប៉ុល ពត ដាក់ខ្នោះជើងអ្នកទោសដែលចាប់មកពីតំបន់នានា6ជួរទល់មុខគ្នា ដោយធ្វើទារុណ-កម្មនៅកុដិខាងជើងដូចជា ព្យួរកឡើងលើចងជើង យកក្បាលជ្រលក់នឹងពាង លាមក, គាប ដៃជើងសួរចំលើយ, វាយនឹងឫស្សីពីងពុង, ចាក់នឹងចំពុះទុង, រុំកៅស៊ូវាយឆក់នឹងខ្សែភ្លើងជាដើម ។

លោក ប៊ុន សុង បន្តថា ក្រោយថ្ងៃរំដោះ 7 មករា 1979 លោកបានចូលមករៀបចំវត្តនេះឡើងវិញ ហើយបញ្ជីឈ្មោះអ្នកទោស ដែលពួករបបអាវខ្មៅបានសំលាប់ចំនួន30,000នាក់ ដែល

(តទៅទំព័រទី១៩)


## Reasons Why You Want to Put

The Advertisement with the Khmer Post
In Philadelphia

**បុព្វហេតុដែលនាំឱ្យលោកអ្នកផ្សាយពាណិជ្ជកម្មនៅ "ខ្មែរប៉ុស្តិ៍"**

The Khmer Post is the only Cambodian media that available to reach out over 30,000 Cambodian readers who live in Philadelphia.



"ខ្មែរប៉ុស្តិ៍" គឺជាប្រព័ន្ធផ្សព្វផ្សាយខ្មែរតែមួយដែលចែកផ្សាយដល់អ្នកអានខ្មែរប្រមាណ ៣ ម៉ឺននាក់ កំពុងរស់នៅហ្វីឡាដែលហ្វីយ៉ា

One phone call away to grow your business, 20% discount when you sign up for a contract of year by calling this number (267) 253-3947.

លេខទូរស័ព្ទដែលធ្វើឱ្យពាណិជ្ជកម្មលោកអ្នករីកដុះដាល គឺ :
(267) 253-3947
យើងខ្ញុំចុះថ្លៃជូន ២០ % បើលោកអ្នកផ្សាយ ១ ឆ្នាំ

**Growing your business. Advertise yourself.**

## (តមកពីទំព័រទី១៤) ផ្ទះនៅសម័យបារាំងក្លាយជា...

ដទៃទៀតយកទៅកែច្នៃតាមការនិយមរបស់ខ្លួន ។

លោក ជីវ តាក្វាន់ អ្នកប្រវត្តិសាស្ត្រចិន ដែលមកទស្សនាប្រទេសកម្ពុជាក្នុងសតវត្សទី១២ នាសម័យមហានគរ បានសរសេរក្នុងកំណត់ហេតុមួយថា លំនៅឋានរបស់ខ្មែរសម័យនោះជាវាំង ឬដំណាក់ព្រះរាជាមានក្បាច់ចំលាក់ល្អណាស់ អគារទាំងនោះប្រក់ក្បឿង សំណ និងលាបពណ៌ល្អឆើតឆាយ ។

លោក ជីវ តាក្វាន់ បានបញ្ជាក់ថា មន្ត្រី និងរាស្ត្រ លំនៅឋានធ្វើអំពីឈើប្រក់ស្លឹក មិនសូវមានជញ្ជាំងត្រឹមត្រូវទេ គឺផ្ទះខុសប្លែកពីសែស្រឡាយព្រះរាជា ។

ចំណែកផ្ទះនៅសម័យអាណានិគមនិយមបារាំងក៏មានសេសសល់ច្រើនដែរ ដែលផ្ទះខ្លះមានអាយុជាង១០០ឆ្នាំ តែទ្រង់ទ្រាយនៅល្អ ហើយត្រូវបានអាជ្ញាធររៀបចំជាភូមិវប្បធម៌ធម្មជាតិសំរាប់ទាក់ទាញភ្ញៀវទេសចរពីគ្រប់ទិសទី ។

***ម៉ូដផ្ទះបុរាណមានអាយុជាង១០០ឆ្នាំ :**

ក្នុងចំណោមផ្ទះបុរាណទាំង២៩ខ្នង ដែលនៅសេសសល់ពីសម័យបុរាណនោះ គឺមានតែផ្ទះពីរទេ ដែលភ្ញៀវទេសចរចេញចូលច្រើនជាងគេ និងមានលក់ម្ហូបអាហារទទួលឱ្យស្នាក់នៅថែមទៀតផង ។

លោក យី សារិទ្ធ អាយុ៦២ឆ្នាំ ដែលជាម្ចាស់ផ្ទះបុរាណបានរៀបរាប់ថា ផ្ទះនេះកសាងឡើងតាំងពីឆ្នាំ១៩០៧ម្ល៉េះ ខណៈពេលដែលលោកម្ចាស់កថាថនឈុំ ចេញទៅរស់នៅប្រទេស


លោក យី សារិទ្ធ អាយុ៦២ឆ្នាំ នៅវត្តគរ

សៀម (សម័យបាត់ដំបងលោកម្ចាស់) គឺលោកតារបស់លោកឈ្មោះថា "ហ្លួងស្នេហា ឬនាមដើមតាប់" ។ ផ្ទះនេះកសាងតាមបែបម៉ូដខសងដែលមាន២ខ្នង គឺខាងមុខជាផ្ទះខសងមានដំបូលពីរជាន់ដូចព្រះវិហារ ។

លោក យី សារិទ្ធ បានបន្តថា នៅខាងចុងព្រំពុំមានរូបនាគ ឬគ្រុឌទេ ពីព្រោះជាផ្ទះរបស់ប្រជាជន ហើយផ្ទះនេះសង់ពីឈើប្រក់ក្បឿងជញ្ជាំងបាយអរ ដោយត្បាញឫស្សីលាយកំបោរនិងខ្សាច់ ស្ករក្រហមបូកបញ្ចូលគ្នា ។ ផ្ទះទី១មានទំហំទទឹង៩ម៉ែត្រ និងបណ្តោយជាង២០ម៉ែត្រសសរ២៤ដើម ។

ចំណែកតួផ្ទះខាងក្រោយនេះមានអាយុ១១០ឆ្នាំ មានសសរ១៥ដើម ពីព្រោះវាមានទំហំ៤ល្វែង សុរបទាំងផ្ទះបាយផង គឺមានសសរ៥២ដើម ។

អ្នកទទួលមរតកផ្ទះបុរាណនេះ បានបន្តថា នៅសម័យប៉ុល ពត ក្រុមគ្រួសារលោកត្រូវគេជម្លៀសចេញ ហើយអ្នកស្រុកភូមិគេមកស្នាក់នៅ និងក្រោយមកទៀត គេយកដាក់កន្លែងចិញ្ចឹមកុមារតូចៗ ពីព្រោះផ្ទះនេះមានសសរច្រើនងាយស្រួលក្នុងការចងអង្រឹង ។ ចាប់តាំងពីសាងសង់មកផ្ទះនេះទើបតែជួសជុលម្តង គឺពីសសរជាប់ដីដាំមកតំកល់តាងវិញ ដោយគ្រាន់តែជួសជុលក្បឿងបន្តិចបន្តួចប៉ុណ្ណោះ នៅឆ្នាំ ១៩៦៣។

***ភ្ញៀវទាំងខ្មែរ និងបរទេស :**

លោក យី សារិទ្ធ បានបន្តថា ចាប់តាំងពីថ្ងៃរំដោះ៧មករា ១៩៧៩មក ផ្ទះរបស់គាត់ពុំមានផ្លាស់ប្តូរអ្វីក្រៅពីជណ្តើរពុកផុយ និងចាក់សាបពីក្រោមផ្ទះកុំឱ្យជាប់ជើងប៉ុណ្ណោះ ។ ចំពោះភ្ញៀវភាគច្រើនជាជនជាតិបារាំង អាមេរិក ដាណឺម៉ាក អាល្លឺម៉ង់ កូរ៉េ គេចាប់អារម្មណ៍ផ្នែកខាងលើនៃផ្ទះ ។ ចាប់តាំងពីដើមឆ្នាំ២០០៨នេះ គឺភ្ញៀវទេសចរមកទស្សនាផ្ទះរបស់លោកជារៀងរាល់ថ្ងៃមានទាំងខ្មែរ និងបរទេស ។ សំរាប់ភ្ញៀវដែលមកមើលផ្ទះមានពីរប្រភេទ គឺទី១ ភ្ញៀវគ្រាន់តែមកមើលផ្ទះ និងភ្ញៀវមួយប្រភេទទៀត មកកំសាន្តទទួលទានសំរាប់ពួកយុវជនខ្មែរ ។

ក្នុងចំណោមពួកគេទាំងនោះ ខ្លះមកមើលផ្ទះច្រើនជាភ្ញៀវបរទេសដែលក្រុមហ៊ុនទេសចរណ៍ផ្សេងៗផ្ញើមកពីភ្នំពេញ ។ ចំពោះអ្នកដែលមកមើលផ្ទះ ហើយសំរាកនោះមានចំនួនតិចទេ ប៉ុន្តែបើសំរាកក្នុង១យប់តំលៃ៥ ដុល្លារ ។

***ភ្ញៀវមានអារម្មណ៍សប្បាយរីករាយ :**

ចំពោះភ្ញៀវភាគច្រើនមកស្នាក់នៅមិនថាយប់ ឬថ្ងៃនោះទេ គឺពួកគាត់មានអារម្មណ៍សប្បាយរីករាយក្នុងចិត្ត គ្មានអារម្មណ៍ភ័យខ្លាចនោះទេ ដោយសារផ្ទះរបស់លោកស្ងប់ស្ងាត់ និងមានការធានាសុវត្ថិភាពពីអាជ្ញាធរមូលដ្ឋានផងដែរ ។ ភ្ញៀវទាំងនោះមិនថា មកដេក ឬមកទស្សនាទេ ពួកគេហាក់បីដូចជាចាប់អារម្មណ៍ចំពោះផ្ទះបុរាណ និងដំណាំផ្លែឈើជុំវិញផ្ទះខ្លាំងណាស់ នេះជាការឱ្យដឹងពីម្ចាស់ផ្ទះ ។

ជាមួយនឹងការមកទស្សនារបស់ភ្ញៀវនេះ លោក យី សារិទ្ធ ម្ចាស់ផ្ទះបុរាណបានបញ្ជាក់ថា ភ្ញៀវក៏បានបរិច្ចាគជាលុយកាក់សំរាប់អភិរក្សផ្ទះ ដែលខាងស្រុកគេដាក់ហិបនៅលើផ្ទះសំរាប់សន្សំ ។ ភ្ញៀវទាំងនោះបន្ទាប់ពីមើលផ្ទះរួច ហើយ

(តទៅទំព័រទី២១)

## (តមកពីទំព័រទី០៤) នាវាចម្បាំងពិឃាតអាមេរិក...

មុខនោះទេ គឺជាសំលេងម៉ាស៊ីនបញ្ឆេះ ដើម្បីបង្កើតជាចរន្តអគ្គិសនីសំរាប់ប្រើប្រាស់នៅលើនាវាទាំងមូលដូចជា ប្រព័ន្ធម៉ាស៊ីនត្រជាក់ និងមុខងារសំខាន់ៗមួយចំនួនទៀតនៅក្នុងនាវានោះ។

ក្រោយពីការទទួលការស្វាគមន៍យ៉ាងរាក់ទាក់ពីសំណាក់លោកឧត្តមនាវិក ហ្សាល វីល្លៀម និងក្រុមនាវិកផ្សេងៗទៀតដែលបំរើការនៅលើនាវានេះរួចមក លោកឧត្តមនាវិកបានអនុញ្ញាតិឱ្យក្រុមអ្នកកាសែតទាំងអស់បានដើរទស្សនាលើនាវានេះទាំងមូល ដោយមានការពន្យល់យ៉ាងក្បោះក្បាយពីសំណាក់ក្រុមនាវិកនៅលើនាវានេះ ។

វាហាក់បីដូចជាស្មុគស្មាញណាស់នៅពេលដែលបានចូលទៅមើលផ្នែកខាងមុខបញ្ជារបស់នាវា ដែលមានឧបករណ៍បញ្ជាតូចៗយ៉ាងច្រើនស្មុគស្មាញ មើលមិនយល់សំរាប់អ្នកធម្មតា ហើយបើតាមការពន្យល់របស់មន្ត្រីនាវិកម្នាក់ក៏បានឱ្យដឹងថា យ៉ាងហោចណាស់ក៏មានមនុស្សចំនួន 4នាក់ដែរ សំរាប់បញ្ជាផ្នែកខាងមុខនាវានេះ ដើម្បីឱ្យនាវាបានបើកទៅមុខរួច ។

លោក John Johnson អ្នកនាំពាក្យស្ថានទូតអាមេរិកប្រចាំនៅកម្ពុជា ដែលបានអមដំណើរដោយក្រុមអ្នកកាសែតទៅមើលនាវាពិឃាតនេះ បានមានប្រសាសន៍ពីគោលបំណងនៃការចូលសំចតនាវានេះថា ទី1 គឺដើម្បីពង្រឹងទំនាក់ទំនងទ្វេភាគីរវាងកម្ពុជា-អាមេរិក ពិសេសផ្នែកយោធា ។ លោកបានបន្តថា ទី2 គឺផ្តល់ឱកាសដល់មន្ត្រីយោធាខ្មែរ ដើម្បីពិភាក្សាគ្នាអំពីសន្តិសុខក្នុងតំបន់ និងទី3 គឺផ្តល់ឱកាសដល់គ្រូពេទ្យខ្មែរ និងអាមេរិកធ្វើការរួមគ្នា ដើម្បីធ្វើការព្យាបាលរួមគ្នាទៅដល់ប្រជាពលរដ្ឋនៅក្នុងក្រុងព្រះសីហនុ ។

សម្រាប់លោក ស្បោង សារ៉ាត់ អភិបាលក្រុងព្រះសីហនុ ដែលបានទទួលស្វាគមន៍ចំពោះការចូលចតនាវាពិឃាតនេះ បានថ្លែងថា នេះជា


សកម្មភាពនាវិក នៅលើកប៉ាល់ចម្បាំងអាមេរិក

លើកទី3ហើយ ដែលនាវាទ័ពអាមេរីនរបស់អាមេរិកបានចូលចតនៅលើផ្ទៃទឹកសមុទ្រ នា-ក្រុងកំពង់សោម ។ លោកបន្តថា រាល់ការចូលចតម្តងៗមេបញ្ជាការពលទាហានទាំងអស់តែងតែយកចិត្តទុកដាក់ឧបត្ថម្ភគាំទ្រដល់សង្គមកិច្ច និងការងារមនុស្សធម៌ ដូចជា ការព្យាបាលជំងឺ ការជួសជុលសាលារៀន ។ល។

ថ្លែងនៅក្នុងឱកាសនៃការចូលសំចតនាវាអាមេរីន MUSTIN នេះ លោកមេបញ្ជាការ ហ្សាល វីល្លៀម បានមានប្រសាសន៍ថា ដំណើរទស្សនកិច្ចរបស់នាវា MUSTIN នៅពេលនេះបានជួយបង្កើននូវឱកាសជាច្រើនដល់កងនាវាចរទ្វេភាគីនៃកងទ័ពទាំងពីរដើម្បីបណ្តុះបណ្តាល និងសហប្រតិបត្តិការរួមគ្នាជាមិត្តភ័ក្តិ និងដៃគូ ។ លោកមេបញ្ជាការបានបន្តថា ដំណើរទស្សនកិច្ចនេះបានផ្តល់ទីតាំងដ៏ល្អសំរាប់ធ្វើការផ្លាស់ប្តូរទស្សនៈលើបញ្ហាផ្សេងៗស្តីពីបញ្ហាសន្តិសុខដែនទឹក ដែលជាបញ្ហាដ៏សំខាន់សំរាប់ប្រទេសទាំងពីរ ។

ចំណែកលោកស្រី Pipeper Cambel ភារធារីប្រចាំស្ថានទូតអាមេរិកនៅកម្ពុជាបានថ្លែងថា កម្មវិធីផ្សេងៗដែលពាក់ព័ន្ធនិង ទស្សនកិច្ចនេះគឺជាសញ្ញាមួយនៃការប្តេជ្ញាចិត្តរបស់យើង ដើម្បីពង្រឹងនូវការទំនាក់ទំនងរបស់ប្រទេសទាំងពីរលើគ្រប់វិស័យ ។

គួរបញ្ជាក់ថា នាវាឈ្មោះ USS MUSTIN ត្រូវបានយកឈ្មោះតាមលោកវរនាវីឯក អាមេរិកម្នាក់ឈ្មោះ Henry C. Mustin បង្កើតឡើងនៅឆ្នាំ1874 និងបានទទួលមរណភាព នៅក្នុងឆ្នាំ1923 ។ លោកបានទទួលសញ្ញាបត្របណ្ឌិតសភាកងទ័ពជើងទឹកអាមេរិកនៅឆ្នាំ1899 ។

នាវាពិឃាត USS MUSTIN ត្រូវបានដាក់ឈ្មោះជាកិត្តិយសដោយរូបលោក Henry C. Mustin ដែលបានទទួលរង្វាន់ផ្កាយចំនួន 13 នៃការប្រយុទ្ធក្នុងសង្គ្រាមលោកលើកទី2 ។

នាវាពិឃាតនេះត្រូវបានដាក់ឱ្យប្រើប្រាស់នៅក្នុងទីក្រុង Sandiego រដ្ឋ California កាលពីថ្ងៃទី26 ខែកក្កដា ឆ្នាំ2003 ។ នៅលើនាវានេះអាចផ្ទុកនាយទាហានចំនួន32 កូនទាហានចំនួន348នាក់ ។

នាវាពិឃាត USS MUSTIN នេះបានចូលចតនៅក្នុងផ្ទៃសមុទ្រកម្ពុជាចំនួន5ថ្ងៃ គឺចាប់ពីថ្ងៃទី 11 ដល់ 15 ខែតុលា ៕

## (តមកពីទំព័រទី១៩) ជាប់គុកជាង៣ឆ្នាំព្រោះតែអង្គរ...

ប៉ុន្តែគាត់មិនហ៊ានទៅជិតទេ ពីព្រោះខ្លាចគេចាប់យកទៅសំលាប់ ។ គាត់នឹកម្ដាយ និងចង់ឃើញម្ដាយខ្លាំងណាស់ ប៉ុន្តែអារម្មណ៍ភ័យខ្លាចបានបង្អាក់សេចក្ដីនឹករលឹកឱ្យដកថយមកវិញ ។

ស្ត្រី ឈុន បុល បានបន្តថា កាលនោះគាត់មានអារម្មណ៍ឈឺចាប់ និងស្ទើរវិកលចរិតទៅហើយ ពីព្រោះម្ដាយត្រូវជាប់គុកឪពុក និងបងប្អូនប្រុសស្រី3នាក់ទៀតត្រូវពួកវាសំលាប់ចោលលាង4-5ថ្ងៃទើបហើយ ។ នៅកន្លែងនោះ មានខ្នោះ ញញួរ ប្រដាប់ឆក់ផ្លឹងជនរងគ្រោះ និងបញ្ជីអ្នកទោសដែលត្រូវគេសំលាប់ប្រមាណជាង3ម៉ឺននាក់ ។ គាត់បានឱ្យអ្នកស្រុកប្រមូលភស្តុតាងទាំងនោះទុកនៅលើសាលាឆាន់ ប៉ុន្តែក្រោយមកខាងអាជ្ញាធរមកសុំយកទៅបាត់អស់ ។

លោក ស៊ុន ង៉ាន បញ្ជាក់ថា ពេលនេះលោក បានឮតាមវិទ្យុ និងឃើញតាមទូរទស្សន៍


លោកយាយ អ៊ុំ បូរ និងកូន ស្រី ឈុន បុល

អស់ គឺគាត់គ្មានសង្ឃឹមថា បានជួបមុខម្ដាយទៀតទេ ប៉ុន្តែសំណាងហើយដែលបានរួចខ្លួននោះ។

ឈុន បុល បានបញ្ជាក់ថា ម្ដាយរបស់គាត់ទោះបីជារួចផុតពីសេចក្ដីស្លាប់មែន ប៉ុន្តែសតិបញ្ញារបស់គាត់ភ្លេចភ្លាំងនិយាយមិនសូវដឹងខុសត្រូវទេ ហើយគាត់វង្វេងវង្វាន់ច្រើនណាស់ ។ ចំណែកឯសុខភាពរបស់គាត់ឈឺលស់ថ្ងៃតិចណាស់ គឺគាត់រស់ដោយសារថ្នាំប៉ុណ្ណោះ ។

ទោះបីជាការឈឺចាប់បានកន្លងផុតទៅជាច្រើនឆ្នាំហើយក៏ពិតមែន ប៉ុន្តែក្នុងអារម្មណ៍របស់ស្ត្រីទាំងពីរនាក់ដែលបាត់បង់សាច់ញាតិបានអំពាវនាវឱ្យតុលាការខ្មែរក្រហមជួយរកយុត្តិធមិផង។ ពួកគាត់ទាំងពីរនាក់ចង់ប្ដឹងពួកខ្មែរក្រហមទាំងនេះដែរ ប៉ុន្តែមិនសូវចេះច្បាប់មិនដឹងជាទៅកន្លែងណា ឬអ្នកណាឱ្យជួយក្នុងរឿងនេះទេ ។

ទាក់ទិនទៅនឹងការលើកឡើងរបស់អតីតអ្នកទោសខ្មែរក្រហម ដែលបានអះអាងថា ពួកខ្មែរក្រហមយកវត្តសម្ដេចមុនី ធ្វើជាកន្លែងធ្វើទារុណកម្ម និងប្រមូលផ្ដុំអ្នកទោសមុនពេលយកទៅសំលាប់នោះ លោក ស៊ុន ង៉ាន អាយុ 83ឆ្នាំ ជាគណៈកម្មការវត្តសម្ដេចមុនី និងជាអតីតមេឃុំ ខុនរ៉ង បានឱ្យដឹងថា នៅសម័យប៉ុល ពត គាត់ត្រូវគេចាត់ឱ្យដើររកត្រីសំរាប់សហករណ៍ ហើយដើរកាត់ផ្លូវក្បែរៗនេះ ឮសំឡេងស្រែកយំទាំងយប់ទាំងថ្ងៃគួរឱ្យព្រឺឆ្អឹងខ្នងខ្លាំងណាស់ ។

លោក ស៊ុន ង៉ាន បានបន្តថា ជារៀងរាល់ថ្ងៃគាត់ឃើញពួកឈ្លបចងមនុស្សបណ្ដើរទាំងខ្សែៗយកទៅដាក់ខ្នោះ ស្ទួរចំលើយក្នុងព្រះវិហារ ដោយក្នុងនោះគេរៀបដាក់ខ្នោះជើង វាយស្ទួរចំលើយប្រមាណពី20ទៅ50នាក់ ។ នៅសម័យអាវខ្មៅនោះគាត់ត្រូវគេសំលាប់ទាំងប្រពន្ធ និងកូនពីរនាក់មិនដឹងមូលហេតុច្បាស់លាស់ ដោយគ្រាន់តែចោទថា ខ្មាំងក្បត់នឹងអង្គការ ។

អតីតលោកមេឃុំ ខុនរ៉ង រូបនេះបានបន្តថា ក្រោយថ្ងៃរំដោះ 7មករា គាត់ត្រូវបានគេចាត់តាំងឱ្យធ្វើជាមេឃុំ ហើយគាត់ក៏ដឹកនាំអ្នកភូមិទៅសំអាតវត្តនេះសំរាប់គោរពបូជា ដោយក្នុងព្រះវិហារនោះមានឈាមកកកំរាស់មួយតឹកដុសថា សាលាក្ដីខ្មែរក្រហមកំពុងធ្វើការស្រាវជ្រាវដើម្បីកាត់ទោសមេដឹកនាំជាន់ខ្ពស់ក្នុងរបបវាលពិឃាត ហើយលោកចង់ឃើញតុលាការខ្មែរក្រហមនេះ កាត់ទោសស្វែងរកយុត្តិធមិឱ្យបានឆាប់ ។ នៅថ្ងៃកាត់ទោសនោះ បើខាងអង្គការ ឬសាលាក្ដីមកដឹកពួកគាត់ទៅធ្វើជាសាក្សី គឺគាត់នឹងទៅចូលរួមផងដែរ ។

សព្វថ្ងៃនេះមានអង្គការសមាគមជាតិ-អន្តរជាតិជាច្រើនបាននឹងកំពុងតែធ្វើការតាមដានយ៉ាងយកចិត្តទុកដាក់ចំពោះដំណើរការសាលាក្ដីខ្មែរក្រហម ហើយពួកគេបានប្រមូលឯកសារ និងជួយសំរួលដល់ជនរងគ្រោះឱ្យដាក់ពាក្យបណ្ដឹងទៅសាលាក្ដីខ្មែរក្រហម ។

ចំណែកលោក សំ មនោរម្យ មន្ត្រីសំរបសំរួលពាក្យបណ្ដឹងនៃសមាគមអាដហុក បានឱ្យដឹងថា បុគ្គលិករបស់លោកនៅគ្រប់ខេត្ត-ក្រុង បាននឹងកំពុងបំពេញការងារនេះ ហើយពួកគេជួយរៀបចំពាក្យបណ្ដឹងសំណងជំងឺចិត្តឱ្យជនរងគ្រោះប្ដឹងទៅសាលាក្ដីខ្មែរក្រហម ។ រហូតមកដល់ពេលនេះ ខាងសមាគមបានទទួលពាក្យបណ្ដឹងជាង 200ពីជនរងគ្រោះ ហើយក្នុងនោះ យើងបានជួយជនរងគ្រោះឱ្យប្ដឹងទៅសាលាក្ដីខ្មែរក្រហម ដោយផ្ទាល់បានជាង20ករណីផ្នែករដ្ឋប្បវេណី ។

ចាប់តាំងពីសាលាក្ដីខ្មែរក្រហមបង្កើតឡើង ដែលមានរយៈពេលជាងពីរឆ្នាំមកនេះ តុលាការបាននាំខ្លួនមេដឹកនាំសំខាន់ៗមកឃុំឃាំង គឺ1-អ៊ុង ជឿន ហៅតាម៉ុក (ស្លាប់), 2-កាំង ហ្គេចអ៊ាវ ហៅឌុច មេគុកទួលស្លែង, 3-នួន ជា អតីតប្រធានសភា និងអនុលេខាមជ្ឈឹមបក្ស, 4-ខៀវ សំផន អតីតប្រមុខរដ្ឋកម្ពុជាប្រជាធិបតេយ្យ, 5-អៀង សារី អតីតរដ្ឋមន្ត្រីក្រសួងការបរទេស និង អៀង ធីរិទ្ធ អតីតរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច។

ប៉ុន្តែអ្វីដែលគួរឱ្យស្ដាយនោះ តុលាការកូនកាត់នេះមានលេចឮរឿងអាស្រូវជាប់ពាក់ព័ន្ធនឹងអំពើពុករលួយ និងជួបវិបត្តិខ្វះខាតថវិកាក្នុងដំណើរទៅមុខ ។ ទោះជាយ៉ាងណាប្រទេសមហាអំណាចមួយចំនួនក៏បានផ្ដល់ជំនួយជាបន្តបន្ទាប់ ហើយតំរូវឱ្យតុលាការនេះធ្វើកំណែទំរង់ភាពមិនប្រក្រតីឱ្យបានប្រសើឡើងវិញ ៕

## (តមកពីទំព័រទី២០) ផ្ទះនៅសម័យបារាំងក្លាយជា...

ពួកគាត់បន្តដំណើរទៅកាន់តំបន់ទេសចរណ៍ធម្មជាតិក្នុងខេត្តដែលក្រុមហ៊ុនជាអ្នកធានារ៉ាប់រង ។

*** ផ្ទះបុរាណរួមចំណែកលើកកំពស់ជីវភាព :**

កេរដំណែលរបស់បុព្វបុរសខ្មែរតាមរយៈផ្ទះបុរាណនេះ មិនត្រឹមតែធ្វើឱ្យភ្ញៀវទេសចរចំរុះជាតិសាសន៍បានស្គាល់ពីទឹកដៃដ៏ខ្ពស់រស់រវើករបស់បុព្វបុរសខ្មែរផ្នែកសំណង់ស្ថាបត្យកម្មប៉ុណ្ណោះទេ ប៉ុន្តែក៏បានជួយទ្រទ្រង់ជីវភាពរស់នៅរបស់អ្នកស្រុកមួយកំរិតផងដែរ ។

អ្នកស្រី ស្វាយ ចាន់ថា អនុប្រធានការិយាល័យទេសចរណ៍ស្រុកបាត់ដំបង បានឱ្យដឹងថា ក្នុងចំណោមផ្ទះបុរាណទាំង២៩ខ្នង ដែលអាជ្ញាធរអភិរក្សជាផ្ទះបុរាណនេះ មានតែពីរខ្នងប៉ុណ្ណោះដែលភ្ញៀវចេញចូលទៅទស្សនាច្រើនជាងគេ ។ ផ្ទះម៉ូដប៉ិតរបស់អ្នកគ្រូ ប៊ុន រឿង កសាងនៅឆ្នាំ ១៩២០ និងផ្ទះខសងរបស់លោក យី សារិទ្ធ កសាងនៅឆ្នាំ១៩០៧ ហើយភ្ញៀវទេសចរដែលមកទស្សនាភូមិបុរាណក្នុង១ខែ ប្រមាណពី១៥០ ទៅ ៣០០នាក់ មាន : អាមេរិក ជប៉ុន បារាំង កូរ៉េ...។

អ្នកស្រីអនុប្រធានការិយាល័យទេសចរណ៍ស្រុកបានបន្តថា ភ្ញៀវដែលមកទស្សនា ខ្លះទំនាក់ទំនងតាមរយៈម្ចាស់ផ្ទះ ខ្លះទៀតតាមរយៈក្រុមហ៊ុនខាងក្រៅប្រទេស និងក្នុងប្រទេស បន្ទាប់ពីគេបានឃើញតាមរយៈអ៊ិនធើណេត ឬការផ្សព្វផ្សាយពាណិជ្ជកម្មរបស់ក្រសួងទេស-ចរណ៍។

ដោយឡែកលោក រ៉ុង ទុយ ប្រធានការិយាល័យទេសចរណ៍ស្រុកបានឱ្យដឹងថា ចំពោះផ្ទះបុរាណដែលបង្កើតឡើងតាំងពីឆ្នាំ២០០៦ នោះ បើម្ចាស់ផ្ទះសុំចង់កែច្នៃ ឬជួសជុល គឺត្រូវតែមកសុំការអនុញ្ញាត ហើយត្រូវតែរក្សារចនាប័ទដូចដើម ។ ម្ចាស់ផ្ទះមួយចំនួនទៀតដែលចង់រុះរើ ហើយកសាងថ្មីខាងសមត្ថកិច្ចយើងមិនអនុញ្ញាតឱ្យធ្វើនោះទេ ហើយក្នុងនោះក៏មានផ្ទះមួយចំនួនគេបានរចនាតាំងពីមុនបង្កើតភូមិនេះម្លេះ ។

លោក រ៉ុង ទុយ បន្តថា ចំពោះគំរោងអភិរក្សនេះគ្រាន់តែជាជំហានសាកល្បងរបស់ស្រុក ដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រ-ជាពលរដ្ឋតាមមូលដ្ឋានប៉ុណ្ណោះ ដោយចំណូលទាំងនោះខាងអាជ្ញាធរមិនមានការលូកលាន់ ឬដកហូតអ្វីនោះទេ ។

ក្រៅពីភូមិទេសចរណ៍វប្បធមិផ្ទះបុរាណខេត្តនេះ នៅមានភូមិទេសចរណ៍ដំណាំស្រូវ ដែលភ្ញៀវធ្វើដំណើរតាមរទេះគោមានវាលស្រែធំល្វឹងល្វើយស្រូបយកខ្យល់អាកាសឃើញសន្ទូងស្រូវទុំដាច់កន្ទុយភ្នែក ។ លើសពីនេះទៀត នៅមានភូមិទេសចរណ៍ ចំការផ្លែឈើច្រើនស្មេកស្មុះពេញចំការ តាមបណ្ដោយស្ទឹងសង្កែ ក្នុងភូមិខ្សាច់ពោយ ។

បន្ទាប់ពីភ្ញៀវទេសចរណ៍ទស្សនា នៅតាមភូមិគំរូទាំងនេះរួចហើយ ពួកគាត់អាចបន្តដំណើរទៅតំបន់រមណីយដ្ឋានប្រវត្តិសាស្ត្រធម្មជាតិ និងរមណីដ្ឋានកែច្នៃ ដែលមានធម្មជាតិស្រស់ត្រកាល និងរឿងនិទានប្លែកៗទាក់ទងទៅនឹងជីវភាពរស់នៅរបស់អ្នកស្រុកទៀតផង ៕

U.S.A. AUTO GLASS

ហាងជួសជុលកញ្ចក់រថយន្ត

-ដាក់កញ្ចក់ឡានគ្រប់ធុន កញ្ចក់ថ្មី ឬ ចាស់
-ធានាគុណភាពដល់ទៅ ១ ឆ្នាំ
-យ៉ាងឆាប់រហ័ស រយៈពេលក្នុងថ្ងៃតែមួយ

បើលោកអ្នកមិនអាចអញ្ជើញមកហាងយើងខ្ញុំបាន ខ្ញុំបានអាចនៅប្ដូរកញ្ចក់ឡានដល់ផ្ទះ








We Specialized in:
Windshield Replace,
Windshield Repair
Door Glass Repair
Sun Roof + Side Mirror
Window Motor + Regulator
Window Tint
State inspection
Wiper Blades

WE'LL COME TO YOUR HOME OR BUSINESS

SAME DAY SERVICE
1 YEAR WARRANTY
NEW/USED GLASS

Monday-Friday 8 a.m. – 5 p.m. Saturday 8 a.m. – 2 p.m.

1822 South 7th Street.
Philadelphia, Pa 19148

Tel: 215.271.7190
Fax: 215.271.9150



# ហោរាសាស្ត្រប្រចាំខែ វិច្ឆិកា ថ្ងៃទី ០១-១៥



### ឆ្នាំជូត : (ពពួកទេវតាប្រុស ធាតុទឹក)

រាសីលោកអ្នកខ្ពស់ត្រដែត ។ រាល់កិច្ចការងាររកស៊ីជួញដូរមានការរីកចម្រើនលូតលាស់ទៅមុខជាលំដាប់ ។ ក្នុងរយៈពេលនេះ ទោះជាលោកអ្នកបានប្រកបកិច្ចការងារអ្វីក៏ដោយ ក៏មានអ្នកជួយជ្រោមជ្រែងយ៉ាងពេញទំហឹងដែរ ។ ចំពោះស្ត្រីភេទនៅលីវ និងត្រូវបានកម្លោះៗចោមរោមស្រលាញ់ រហូតអាចឈានដល់ការស្ដីដណ្ដឹងយកធ្វើជាគូអនាគតទៀតផង ៕



### ឆ្នាំមមី : (ពពួកទេវតាស្រី ធាតុភ្លើង)

រាសីលោកអ្នកល្អជាមធ្យម ។ រាល់កិច្ចការងាររកស៊ីជួញដូរមានការរីកចម្រើនលូតលាស់ទៅមុខដោយសន្សឹមៗ ។ ក្នុងរយៈពេលនេះ ថ្វីត្បិតតែមានផលចំណូលហូរចូលបានច្រើនក្រាស់ក្រែលគួរសមក្ដី តែពុំមានសល់អ្វីជាដុំកំភួនឡើយ ព្រោះចាយវាយខ្ជះខ្ជាយខ្លាំងពេក ។ ចំពោះគូស្នេហ៍ក្នុងរយៈពេលនេះ បើស្រលាញ់កុំទៅញឹក បើរពូកកុំទៅញយទើបចំណងស្នេហាអាចគង់វង្សបានយូរអង្វែង ៕



### ឆ្នាំឆ្លូវ : ( ពពួកមនុស្សប្រុស ធាតុដី )

រាសីលោកអ្នកឡើងខ្ពស់ត្រដែត ។ រាល់កិច្ចការងាររកស៊ីជួញដូរបានកាក់កបល្អណាស់ ។ ក្នុងរយៈពេលនេះ លោកអ្នកមានអារម្មណ៍ភ្លឺថ្លា គំនិតប្រាជ្ញាឈ្លាសវៃ ទោះប្រកបកិច្ចការងារអ្វីៗក៏ដោយ ក៏អាចទទួលបានផលសម្រេចសមតាមបំណងប្រាថ្នាទាំងអស់ ។ ចំពោះស្វាមីភរិយាវិញ មានភាពល្អកល្អឹនគ្នាណាស់ ហើយពិសេស នោះស្រលាញ់គ្នាលើសមុនទៅទៀត ៕



### ឆ្នាំមមែ : (ពពួកទេវតាស្រី ធាតុមាស)

រាសីលោកអ្នកស្រុតចុះខ្លាំង ។ រាល់កិច្ចការងាររកស៊ីជួញដូរជួបរឿងរកាំរកូសច្រើន ។ ក្នុងរយៈពេលនេះ លោកអ្នកអាចផ្អាករាល់កិច្ចការងារសំខាន់ៗមួយរយៈពេលសិន ព្រោះបើហ៊ានតែមានចិត្តមានះរឹងរូស គឺពិតជាស៊យធំអាចបង់ខាតទ្រព្យជាក់ជាមិនខាន ។ ចំពោះស្ត្រីភេទក្នុងរយៈពេលនេះ មិនត្រូវដើរផ្លូវឆ្ងាយដាច់សង្វែង តែម្នាក់ឯងឡើយប្រយ័ត្នបានជួបគ្រោះភ័យ ៕



### ឆ្នាំខាល : ( ពពួកយក្សស្រី ធាតុឈើ )

រាសីលោកអ្នកខ្ពស់ត្រដែត ។ រាល់កិច្ចការងាររកស៊ីជួញដូរមានការរីកចម្រើនលូតលាស់ទៅមុខជាលំដាប់ ។ ក្នុងរយៈពេលនេះ ឱកាសល្អៗបានមកដល់ហើយ ដូច្នេះលោកអ្នកត្រូវតែរវៀសរវៃញាប់ជើងញាប់ដៃបន្តិច ព្រោះពេលវេលា ជាមាសប្រាក់ធ្វើច្រើនបានច្រើន ។ ចំពោះគូស្នេហ៍ក្នុងរយៈខែនេះ មានភាពស្និទ្ធស្នាលដូចប្រក្រតី ៕



### ឆ្នាំវក : (ពពួកយក្សប្រុស ធាតុដែក)

រាសីលោកអ្នកល្អជាមធ្យម ។ រាល់កិច្ចការងាររកស៊ីជួញដូរបានកាក់កបល្អគ្រាន់បើ ក្នុងរយៈពេលនេះ អ្វីដែលលោកអ្នកត្រូវយកចិត្តទុកដាក់នោះ គឺនៅតែមានមនុស្សខិលខូចខ្លះប៉ងបំផ្លិចបំផ្លាញរាល់កិច្ចការងារ ដូច្នេះមុននឹងធ្វើអ្វីមួយ ឬមុននឹងធ្វើដំណើរទៅណាមកណា ចូរមានស្មារតីប្រុងប្រយ័ត្នជាប់ជានិច្ច ។ ចំពោះគូស្នេហ៍ក្នុងរយៈពេលនេះមានការយល់ចិត្តគ្នាល្អគ្មានបញ្ហាអ្វីកើតឡើងធំដុំទេ ៕



### ឆ្នាំថោះ : ( ពពួកមនុស្សស្រី ធាតុឈើ )

រាសីលោកអ្នកល្អជាមធ្យម ។ រាល់កិច្ចការងាររកស៊ីជួញដូរមានការរីកចម្រើនលូតលាស់ទៅមុខដោយសន្សឹមៗ ។ ក្នុងរយៈពេលនេះ ទោះជាលោកអ្នកបានប្រកបកិច្ចការងារអ្វីក៏ដោយ ត្រូវមានស្មារតីប្រុងប្រយ័ត្នជាប់ជានិច្ច ជាពិសេសមុននឹងចុះហត្ថលេខា ឬផ្ដិតស្នាមមេដៃផ្សេងៗ ចូរចេះពិនិត្យពិច័យឱ្យបានល្អិតល្អន់ ព្រោះកាលបើមានការភ្លាំងភ្លាត់តែបន្តិច អាចបង់ខាតផលប្រយោជន៍ច្រើន ៕



### ឆ្នាំរកា : (ពពួកយក្សប្រុស ធាតុដែក)

រាសីលោកអ្នកស្រុតចុះខ្លាំង ។ រាល់កិច្ចការងាររកស៊ីជួញដូរជួបរឿងរកាំរកូសច្រើន ។ ក្នុងរយៈពេលនេះ បើមានរឿងឈ្លោះប្រកែកកើតឡើង ចូរចេះអត់ធ្មត់ និងរម្ងាប់ចិត្តឱ្យបានត្រជាក់ ដាច់ខាតមិនត្រូវតបតទាំងកំហឹងទល់នឹងកំហាល់ឡើយ ទើបរឿងតូចមិនអាចក្លាយជារឿងធំបាន ។ ក្នុងរយៈពេលនេះ បើមានដំណើរទៅណាមកណា ចូរប្រយ័ត្នប្រយែងក្រែងជួបគ្រោះថ្នាក់ចរាចរ ៕



### ឆ្នាំរោង : (ពពួកទេវតាប្រុស ធាតុមាស)

រាសីលោកអ្នកឡើងខ្ពស់ត្រដែត ។ រាល់កិច្ចការងាររកស៊ីជួញដូរបានកាក់កបល្អណាស់ ។ ក្នុងរយៈពេលនេះ ទោះជាលោកអ្នកបានប្រកបកិច្ចការងារអ្វីក៏ដោយ ក៏អាចទទួលបានផលសម្រេចសមតាមបំណងប្រាថ្នាទាំងអស់ ។ បើជាអាជីវករ អ្នករកស៊ីជួញដូរ នឹងមានទំនិញលក់ចេញទិញចូលឥតទំនេរដៃ ព្រមទាំងមានទ្រព្យហូរចូលជាហូរហែទៀតផង ៕



### ឆ្នាំច : ( ពពួកយក្សស្រី ធាតុដី )

រាសីលោកអ្នកល្អធម្យម ។ រាល់កិច្ចការងាររកស៊ីជួញដូរបានកាក់កបល្អគ្រាន់បើ ។ ក្នុងរយៈពេលនេះរាល់ឧបទ្រពចង្រៃ និងរាល់ឧបសគ្គត្រូវបានសាបរលាបជាបណ្ដើរៗ ដូច្នេះ លោកអ្នកអាចប្រកបកិច្ចការងាររកស៊ីបានពេញដៃពេញជើង។ ចំពោះអ្នកជំនួញជួញដូរ បើមានប្រគល់ ឬទទួល នូវមុខទំនិញសព្វសារពើ ចូរចេះពិនិត្យគុណភាព និងរាប់ចំនួនឱ្យបានច្បាស់លាស់ ទើបពុំមានរឿងឆបោកកើតឡើង ៕



### ឆ្នាំម្សាញ់ : (ពពួកមនុស្សប្រុស ធាតុភ្លើង)

រាសីលោកអ្នកស្រុតចុះខ្លាំង ។ រាល់កិច្ចការងាររកស៊ីជួញដូរជួបនឹងបញ្ហាលំបាកៗច្រើន។ ក្នុងរយៈពេលនេះ ទោះជាលោកអ្នកបានប្រកបកិច្ចការងារអ្វីក៏ដោយ ចូរកុំមានការធ្វេសប្រហែសឱ្យសោះ ជាពិសេសចំពោះអាជីវករអ្នករកស៊ីប្ដូរប្រាក់ ឬលក់គ្រឿងអលង្ការមានតម្លៃផ្សេងៗ ត្រូវប្រយ័ត្នប្រយែងមានជនខិលខូចលួចបន្លំ ឬឆក់ប្លន់ ៕



### ឆ្នាំកុរ : (ពពួកមនុស្សស្រី ធាតុទឹក)

រាសីលោកអ្នកល្អជាមធ្យម ។ រាល់កិច្ចការងាររកស៊ីជួញដូរមានការរីកចម្រើនលូតលាស់ទៅមុខដោយសន្សឹមៗ ។ ក្នុងរយៈពេលនេះ បើជាបុគ្គលិកកម្មករដែលបំរើការងារនៅតាមក្រុមហ៊ុន ឬរោងចក្រនានា ចូរចេះដាក់ខ្លួនដាក់កាយ និងចេះធ្វើទំនាក់ទំនងល្អជាមួយនឹងចៅហ្វាយនាយ ឬថៅកែ ព្រមទាំងអ្នករួមការងារជាមួយ ទើបកិច្ចការងារអាចដំណើរការបានស្រួល ៕


## Buy something... Sell something...Announce something...advertise on the Khmer Post Classifieds!

### ប្រវត្តិសាស្ត្រនៃកម្ពុជា

លោក វ៉ាន់ឌីកាអុន ទើបនឹងសរសេរសៀវភៅប្រវត្តិសាស្ត្រនេះ ពីសម័យអានានិគមបារាំង មកដល់បច្ចុប្បន្នកាល ។ ភាគទី1 បាន សរសេចប់ចេញផ្សាយរួច ហើយនៅ ប្រទេសបារាំង ។ រីឯភាគទី2 នឹងចេញផ្សាយបន្តទៅទៀត នាពេលឆាប់ៗនេះ ។

រីឯប្រវត្តិសាស្ត្រកម្ពុជាបច្ចុប្បន្នមួយទៀត ជាថាស ស៊ីឌី ដែលរៀបរៀងដោយ ពិន សំខុន ហើយផ្សព្វផ្សាយនៅវិទ្យុ សម្លេងខ្មែរ-អាមេរិកាំង ។ ថាស ស៊ីឌី ចំនួនបួនម៉ោង ស្ដីពីប្រវត្តិកម្ពុជា ចាប់តាំងពីសម្ដេចនរោត្តម សីហនុ បានធ្លាក់ពីអំណាចនាឆ្នាំ1975 មកដល់ឆ្នាំ2004 ឆ្នាំដែលព្រះអង្គ បាន ដាក់រាជសម្បត្តិថ្វាយព្រះរាជបុត្រា របស់ព្រះអង្គព្រះនាម នរោត្តម សីហមុនី ។

ស៊ីឌីនេះ មានលក់នៅខ្មែរប៉ុស្តិ៍ និងនៅវិទ្យុសម្លេងខ្មែរ-អាមេរិកាំង តម្លៃ $30 ។

សូមទូរស័ព្ទមកសុបិន (267) 253 3947 ៕

### ច្បាប់ចេញពីក្រសួងការងារ និងឧស្សាហកម្ម

ស្ដីពីប្រាក់ម៉ោងតិចបំផុត ដែលអ្នកធ្វើការ ទាំងអស់ត្រូវទទួលពីម្ចាស់សហគ្រាស ដែលលោកអ្នកធ្វើការឱ្យនេះ MINIMUM WAGE RATE $7.15 ក្នុងមួយម៉ោង ចាប់ពីថ្ងៃទី1 កក្កដា 2007 ប្រាក់នេះនឹងឡើងតម្លៃទៅជា : $7.25 ក្នុងមួយម៉ោង ចាប់ពីថ្ងៃទី24 កក្កដា 2009 ទៅ ៕

### ជួសជុល ឬកែផ្ទះដោយឥតយកកម្រៃ

បើលោកអ្នកមានអាយុលើសពី 60ឆ្នាំហើយ ជាម្ចាស់ផ្ទះមួយនៅ ហ្វីឡាដែលហ្វីញ៉ា នេះ លោកអ្នកអាចមានសិទ្ធិសុំឱ្យគេជួយជួសជុលការខូចខាតក្នុងផ្ទះតិចតួច ដូចជា ជួសជុលបន្ទប់ទឹក, ធ្វើបង្អួច, កណ្ដឹងនៅទ្វារចូល, បង្កាន់ដៃ, សោទ្វារ ឬប្រដាប់ឱ្យសញ្ញាមានផ្សែងក្នុងផ្ទះ ។ល។

អង្គការ "PCA" សម្រាប់ជួយជួសជុលផ្ទះដល់មនុស្សចាស់ នឹងធ្វើជូនដោយមិនយកកម្រៃ ប្រសិនបើ ប្រាក់ចំណូលក្នុងផ្ទះលោកអ្នកមិនលើសពី $1276 ក្នុងមួយខែ សម្រាប់មនុស្សម្នាក់ ឬមិនលើសពី $1711 សម្រាប់ មនុស្សក្នុងផ្ទះ 2នាក់ ។ ទាក់ទង "PCA- Senior Housing Assistance Repair Program (SHARP) At (215) 765 9040 ៕

### រៀនវិជ្ជាពេទ្យ ហើយមានប្រាក់ឧបត្ថម្ភ

លោកអ្នកមានអាយុពី17 ដល់ 24ឆ្នាំ ហើយចង់រៀនវិជ្ជាសម្រាប់ធ្វើការនៅពេទ្យ ឬការងារទាក់ទងនឹងសុខភាព សូមទៅ The Philadelphia Job Corps Admissions Dept. 2810 20th Street ឬទូរស័ព្ទ 267 386 2888 គេមានផ្ដល់ : សៀវភៅរៀន ជួយតម្លៃធ្វើដំណើរ មានឱ្យខោអាវឯកសណ្ឋាន ។ សូមប្រញាប់ប្រញាល់ ទូរស័ព្ទថ្ងៃនេះ ។

The Philadelphia Job Corps Admissions Dept.

267-388-2888 ៕

**Your Advertisement Is Here For Less than $10 for two weeks!**

**Service**

**C.C. Building Services Metropolitan Area**



**CHEA CHHAY**

*PRESIDENT*

STAFFORD, VIRGINIA 22554

PHONE : (540) 720-4696

FAX : (540) 720-4697

CELL : (703) 606-9010

### Clip & Fax This Classified Coupon

Classified Advertising

Name your category: Sales, Services, Fund Raisers…etc.

Our rates: $5.00 for up to 22 words

15 cents each additional words

Send us your ad in one of the following ways:

1. by Fax to (215) 722-2226

2-by mail to the Khmer Post 5730 Rising Sun Avenue.

Philadelphia, Pa 19120 3-By phone (267) 253-3947

Payments methods: cash or checks.

Name:..................Address:..................

City:..................................................

tate:..............................Zip:...............

Phone:.....................Fax:....................

Your Advertisement Message:

.......................................................

.......................................................

.......................................................

អត់ពីលោកអ្នកទៅ តើធនធានណាជួយថែរក្សាកូនចៅលោកអ្នក ?

NEW YORK LIFE

១-វិញ្ញាបនបត្រធានារ៉ាប់រងសម្រាប់ជីវិត (Life Insurance)
២-សន្សំលុយសំរាប់ចូលនិវត្តន៍ (Retirement Planning)
៣-សន្សំលុយសម្រាប់កូនចូលរៀនមហាវិទ្យាល័យ (College Saving)
៤-រៀបចំទ្រព្យសម្បត្តិទុកឱ្យកូនចៅ (Estate Planning)



ខ្ញុំអាចជួយពន្យល់ដល់បងប្អូនដោយមិនយកកំរៃ

WUTHA CHIN MBA,
Agent New York Life
P. (610) 660 5897, Cell. P (267) 736 0445
wchin@ft.newyorklife.com


# វិធីសន្សំថាមពល
ENERGY SAVING ACTION



#1 បើអ្នកប្រើកំដៅ. ចូរអ្នកផ្ចិតកន្លែងដែលបែកក្រហែង និងប្រហោងនៅជាន់ទីមួយសិន ។ អ្នកអាចបិទផ្ចិតគ្រប់ប្រហោងក្នុងគេហដ្ឋានរបស់អ្នកដោយចំណាយបន្តិចបន្តួច ឬក៏គ្មានចំណាយសោះ ។ វត្ថុដែលអ្នកប្រើប្រាស់មិនសំខាន់ស្មើនឹងកាយវិការ ដែលអ្នកធ្វើនោះទេ ។ ចូររក្សាខ្យល់ក្តៅឱ្យនៅក្នុងនេះ ពីរបៀបសន្សំប្រាក់កាស ។

#2 ញាត់ និងបិទជិតគ្រប់ប្រហោង និងក្រហែងដែលមានលេចចេញខ្យល់ក្តៅ
បើមានខ្យល់ត្រជាក់ជុំវិញបង្អួច ទ្វារ និងកន្លែងដទៃទៀត ដូចជា : នៅតាមពិដានយ៉រខាងមុខ និងកែមក្រោមបង្អួចឆក ។ ចូរអ្នកផ្ចិតគ្រប់ប្រហោងដើម្បីទុកខ្យល់ត្រជាក់ខាងក្នុងនោះ អ្នកនឹងមានសភាពស្រួលខ្លួន

#3 ចូរផ្ចិតកន្លែងដែលលេចនៅជាន់ក្រោមដី មានអ្នកខ្លះនិយាយថា ខ្លួនមិនបានចុះទៅជាន់ក្រោមទេ ។ បើសិនជាអ្នកមិនផ្ចិតប្រហោង ឬក្រហែងនោះទេ អ្នកនឹងគ្មានសំណាងបានសន្សំប្រាក់ នឹងបានក្តៅស្រួលទេ ។

Nationalities Service Center


ឱសថស្ថានខ្មែរ

Sav-Mor PHARMACY
Sam EA R.Ph.
2232 S. 7th St. (7th & Wolf) Philadelphia, Pa 19148
Tel: 215.467.1220 Fax: 215.467.1447



បំរើលោកអ្នកដោយមិត្តភាព និងទាន់ចិត្ត
Fast and Friendly Service

- Sav-Mor គឺជាឱសថស្ថានបំរើ ការចែកចាយថ្នាំ ហើយអាចពន្យល់ពីរបៀបប្រើប្រាស់ថ្នាំ តាមវេជ្ជបញ្ជាជាភាសាខ្មែរបាន
- យើងទទួលយកនូវ MEDICARE MEDICAID និង INSURANCES ជាច្រើនទៀតផង យើងមានលក់កាត សំរាប់ទូរស័ព្ទទៅស្រុកខ្មែរ ឬទៅអន្តរជាតិ

Sav-Mor PHARMACY Tel: 215-467-1220



*Accept most insurance plans including Medicare & Medicaid
*Easy Prescription transfer
*Inside. Prepaid phone card. Call Cambodia.



ផ្កាយព្រឹក វីដេអូ
PKAY PREK VIDEO
(215) 455-2762
4935 OLD YORK RD. PHILADELPHIA, PA 19141





ជួលកុន លក់ឌីវីឌី និង ស៊ីឌី
MOVIE RENTAL
DVD & CD SALES
CAMBODIAN FORMAL DRESSES
WOMEN & BABY CASUAL WEARS



បន្ទប់បរិយាកាស
សូមពិសាភេសជ្ជៈមួយកែវ
នៅបារ៍ TIPSY



ធីបស៊ី នឹងនាំឱ្យលោកអ្នកចង់រាំកំសាន្ត
Live D.J. every Fri & Sat night from 9 p.m. – 2 p.m. (pool table)
Serve Chinese and American food open for Lunch and Dinner
មានក្រុមតន្ត្រីសម័យ ឬ DJ ចាក់ចម្រៀងពីរោះៗឱ្យស្តាប់
រៀងរាល់រាត្រី ថ្ងៃសុក្រ ថ្ងៃសៅរ៍ ពីម៉ោង ៩ យប់ ដល់ម៉ោង ២ ភ្លឺ
មានតុបុកប៊ីយ៉ាទៀតផង

Ralph Rinn
Tel: 215.305.5763
Cell: 267.968.3413
Michael Lay (General Manager)
215.409.4772
Email: tipsybar@gmail.com

Sun-Thu: 10 – 12 a.m.
Fri & Sat: 10 – 2 a.m.
Kitchen Open Daily
Sun-Sat: 10 – 11 p.m.
3904 Frankford Ave.
Philadelphia, Pa 19124



Since 1997
ក្រុមហ៊ុនទេសចរណ៍ខ្មែរ
ក្នុង និងក្រៅប្រទេស
LOW FARE TRAVEL, INC.
Domestic & International
OFFICE IN THE UNITED STATES
CALIFORNIA-FLORIA-ILLINIOS-N.COROLINA-MASSACHUSET
1800 s. 15TH Street. Philadelphia, Pa 19145 USA
តម្លៃចុះថោក ពិសេសទៅស្រុកខ្មែរ,ឡាវ និងវៀតណាម
Special offers to Cambodia/Lao, Thai, & Vietnam:

- Passport
- Passport
- Lawyer referrals

- China
- Eva
- All Nippon
- Korean
- Singapore
- Thai
- Northwest
- Cathay
- Asiana
- Japan

នៅលេងស្រុកខ្មែរ...
មានតម្លៃពិសេសជូនលោក លោកស្រី លោកយាយលោកតា បងប្អូន មីងមា ក្នុងឱកាសបុណ្យភ្ជុំបិណ្ឌ បុណ្យអុំទូក អកអំបុក និងសំពះព្រះខែ ។ សូមជ្រើសរើសយន្តហោះ ដែលលោក លោកស្រី លោកយាយ លោកតា បងប្អូន មីងមា ចង់ជិះធ្វើដំណើរតាមចំណង...





To book a reservation call @
PHONE 215-462-0886/CELL 215-833-3669
OFFICE HOURS
Monday-Friday 4-8 PM/EST
Saturday-Sunday 10-4 PM/EST

We're accepted all methods of payment. We're very proud to serve you for the last 11 years, and your business with is highly appreciated.

# Obama?

●●●លិនស៊ី ដឺរីង មេធាវី បានចោទសំនួរថា " អូបាម៉ា " ជានរណា ? គឺនៅពេលដែល ចន ម៉ាកេន លើកដំកើងសហគ្រាសខ្នាតតូច ហើយនិងលើកដំកើងតម្លៃនៃសង្គមគ្រួសារអភិរក្ស លោក បារ៉ាក់ អូបាម៉ា នៅតែមិនទាន់បង្ហាញសំបុត្រកំណើតដើម្បីបញ្ជាក់ថា លោក ជាណរណាពិតប្រាកដនៅឡើយទេ តើ លោក អូបាម៉ា ពិតប្រាកដជានរណា ?

តទៅនេះ ជាអត្ថបទ លិនស៊ី ដឺរីង ជាភាសាអង់គ្លេស ។

I had intended to write a simple article about how Sen. McCain's policies favor the small businesses that form the backbone of our country's economy. About how he favors the traditional family values which form the very fabric of our society. About how he has shown a concern our environment and how we can protect it for future generations. About how he initiated the legislation granting Cambodia "most favored nation" trade status. About how his wife has done extensive work in finding and defusing land mines in that same country. These things are true. You know this because McCain has a long track record of service in the Senate and reputation for doing what he thinks is right, regardless of the consequences to his career.

I was not going to write about Sen. Obama. However, a recent legal action has brought to light how little we know about this candidate.


លោក លិនស៊ីដឺរីង

Philip Berg, a Democrat, a former candidate for Governor of Pennsylvania, and a former Assistant Attorney General, has filed an action against Sen. Obama and the Democratic party in the Eastern District of Pennsylvania (Federal Court). The complaint basi- cally asks for proof that Obama is a "natural born" citizen of the United States and makes several allegations about Obama, which, if proven, would disqualify him as a candidate for President. The Obama campaign could have easily resolved this by providing a birth certificate; instead they chose to mount a costly legal defense.



The Obama campaign has previously posted a "certificate of live birth" on the internet. Posting a document on the internet is not the same thing as submitting the document to a court of law. Documents on the internet are often fabricated and can not be used to prove anything.

On Friday October 24, according to the Philadelphia Daily News, the case was dismissed on the grounds that Philip Berg did not have "standing" to bring the action. Since the court never evaluated any evidence, we still don't know a lot of basic information about Obama. Why didn't the campaign use this as an opportunity to educate us about their candidate? Why don't they submit documentation, like any other campaign? Obama won't be able to hide behind a website as President. Even at this late date, many people are still asking: who is Sen. Obama?

By Lindsay Doering

AMERICAN LEGION POST 153
PRESENTS



FRANTIC
DJ FRIDAY AND SATURDAY
FROM 9 P.M. – 3 A.M.
MEMBERS ONLY
SMOKING PERMITTED

សូមអញ្ជើញមកកំសាន្ត ពិសារគេសជ្ជៈ
រាំកំសាន្តនៅ "ក្រួចឆ្មារ"

2514 S. 24TH ST.
PHILA., PA 19145
215-551-1950

បន្ទូរបរិយាកាសយ៉ាងត្រជាក់ចិត្ត
បន្ទាប់ពីធ្វើការងារហត់នឿយ !

- កន្លែងកំសាន្តធំទូលាយ-ស្តាប់ភ្លេងយ៉ាងពិរោះអស្ចារ្យ ឬក៏បុកប៊ីយ៉ា ក៏មានជូនកំសាន្តដែរ ។
- យើងខ្ញុំរីករាយណាស់នឹងឃើញលោក-អ្នកអញ្ជើញមក !
- ថ្ងៃសុក្រ-សៅរ៍ ពីម៉ោង ៩ ដល់ម៉ោង ៣ ព្រឹក
- **DJ** នឹងបំពេញតអារម្មណ៍លោក-អ្នកតាមតន្ត្រីសំរាំងថ្មីៗ





ចង់ជួលសាល ឬចង់បានម្ហូប
ជប់លៀង យើងធ្វើជូនបាន !
HALL RENTAL & CATERING
AVALIABLEREASONABLE PRICE

Nationwide

Insurance & Financial Service
សេវាធានារ៉ាប់រង និងហិរញ្ញវត្ថុ
We offer Cheap Price for Every Client
យើងធ្វើជូនគ្រប់ភ្ញៀវដោយតម្លៃថោក

| | |
|---|---|
| Business Liability Insurance | ធានារ៉ាប់រងជំនួញលោកអ្នក |
| Home Insurance | ធានារ៉ាប់រងផ្ទះសម្បែង |
| Health Insurance | ធានារ៉ាប់រង សុខភាព |
| Auto Insurance | ធានារ៉ាប់រងរថយន្ត |
| Life Insurance | ធានារ៉ាប់រងជីវិត |

Discount 30% when you purchase
Home & Auto Insurance
ចុះតម្លៃ ៣០ % បន្ថែមបើលោកអ្នកទិញ
ធានារ៉ាប់រង ផ្ទះ និងរថយន្តរួមគ្នា

South Philadelphia office:
600 Washington Ave Suite #8
Philadelphia, Pa 19147
Tel: (215) 463-1257
Fax: (215) 463-2036

North Philadelphia office:
6603 Bustleton Ave.
Philadelphia, Pa 19149
Tel: (215) 335-2140
Fax: (215) 335-2147